**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ទំនាក់ទំនងសហព័ន្ធក្នុងនីតិគ្រួសារ

## (ចាប់ពីកំណកំណើត ដល់ក្រោយបញ្ចប់អាពាហ៍ពិពាហ៍)

ស្រាវជ្រាវចាប់ពីថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៨ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៨


រៀបរៀងដោយ៖

និស្សិតឈ្មោះ **ទៀ ប៊ុនស៊ុនន**

**យ៉ន សុចន្ត្រិរ័ត្ន**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ព្រុំ រិទ្ធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៣ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំឈ្មោះ **ទៀ ម៉ុនស៊ុនណុ** និង **យ៉ន សុចន្ថិរ័ត្ន** ជានិស្សិតឆ្នាំទី៤ ថ្នាក់L៤B២ នៃថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៤-២០១៨។

## **សូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**

**លោកឪពុក** និង **អ្នកម្តាយ** ដែលបានខិតខំបីបាច់ថែរក្សារូបកូនដោយសេចក្តីស្រឡាញ់ និងពោរពេញដោយទឹកចិត្តសន្តោសប្រណី ដែលមានតម្លៃមិនអាចកាត់ថ្លៃបាន តាំងពីតូចក្រូចឆ្មារ រហូតដល់កូនបានធំពេញវ័យ។ លោកទាំងពីររមែងតែងតែផ្តល់នូវដំបូន្មានល្អៗ និងបានអប់រំទូន្មានប្រៀនប្រដៅកូនឱ្យខិតខំកសាងខ្លួនក្លាយជាបុគ្គលដែលមានប្រយោជន៍ចំពោះគ្រួសារ និងសង្គមជាតិទាំងមូល។ ដោយមានការប្រឹងប្រែងរបស់លោកទាំងពីរ ទើបធ្វើឱ្យកូនអាចឈានមកដល់ថ្ងៃនេះ។

ទន្ទឹមនឹងនេះយើងខ្ញុំសូមថ្លែងអំណរគុណចំពោះ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ ដែលបានបង្ហាត់បង្រៀន និងផ្តល់ចំណេះដឹងដល់សិស្សានុសិស្សទាំងអស់ តាំងពីបឋមសិក្សា រហូតដល់កម្រិតឧត្តមសិក្សា។ ម្យ៉ាងវិញទៀត យើងខ្ញុំក៏មិនភ្លេចអរគុណដល់ បងប្អូន-មិត្តនិស្សិត និងមិត្តភក្តិទាំងអស់ ដែលបានចូលរួមជួយគាំទ្រ និងលើកទឹកចិត្ត ហើយក៏បានជួយផ្តល់ជាយោបល់ល្អៗដល់យើងខ្ញុំ។

## **យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេសចំពោះ**

- **ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែល **ឯកឧត្តមសាកលវិទ្យាធិការ** បានផ្តល់នូវឱកាសដល់ក្រុមយើងខ្ញុំធ្វើការស្រាវជ្រាវលើប្រធានបទខាងលើ និងទទួលបានឯកសារស្រាវជ្រាវល្អៗពីសាកលវិទ្យាល័យផងដែរ។

- **បណ្ឌិត ព្រុំ រិទ្ធី** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ ហើយលោកបានចំណាយពេលវេលាយ៉ាងមានតម្លៃក្នុងការកែលម្អ និងផ្តល់ជាអនុសាសន៍ស្ថាបនាសម្រាប់ក្រុមយើងខ្ញុំ ក្នុងការសរសេរសារណារហូតទទួលបានជោគជ័យ គួរជាទីមោទនៈ។

ជាអវសានកថា យើងខ្ញុំសូមប្រសិទ្ធិពរជ័យ សិរីសួស្តី ជ័យមង្គលវិបុលសុខ មហាប្រសើរ ជូនដល់ លោកឪពុក អ្នកម្តាយ ឯកឧត្តម ថ្នាក់ដឹកនាំ-លោកគ្រូ-អ្នកគ្រូ-សាស្ត្រាចារ្យទាំងអស់នៃសាកល-វិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បងប្អូន-មិត្តនិស្សិត និងជនរួមជាតិខ្មែរទាំងអស់ឱ្យជួបប្រទះតែពុទ្ធិពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

អាពាហ៍ពិពាហ៍ គឺជារឿងមួយដែលសំខាន់ណាស់ក្នុងលក្ខខណ្ឌនៃការកសាងសង្គមគ្រួសារ សម្រាប់ប្រជាពលរដ្ឋកម្ពុជា ដែលវាបានក្លាយជាប្រពៃណីតាំងពីបុរាណកាលមក រហូតដល់បច្ចុប្បន្ន នេះ។ ទន្ទឹមនឹងនេះការរៀបអាពាហ៍ពិពាហ៍ គឺជារឿងមួយដ៏មង្គល តែគេក៏សង្កេតឃើញមាននូវបញ្ហាមួយចំនួននឹងកើតឡើងក្នុងអំឡុងពេលនៃចំណងអាពាហ៍ពិពាហ៍។ បញ្ហាទាំងនេះ គឺបានកើតឡើងដោយសារកង្វះការយល់ដឹង និងការមិនគោរពនូវសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនក្នុងនាមជាសហព័ទ្ធ។ ហេតុដូចនេះហើយទើបរាជរដ្ឋាភិបាលបានខិតខំក្នុងការបង្កើតនូវច្បាប់ ដើម្បីចូលរួមជាចំណែកក្នុងការទប់ស្កាត់បង្ការ ក៏ដូចជារាំងនូវហានិភ័យដែលកើតមានឡើង និងចូលរួមជាចំណែកក្នុងការជួយដោះស្រាយបញ្ហាទាំងនោះផងដែរ។

ដើម្បីរួមចំណែកក្នុងការយល់ឲ្យបានកាន់តែស៊ីជម្រៅអំពីសិទ្ធិ និងកាតព្វកិច្ចរបស់សហព័ទ្ធ យើងខ្ញុំដែលជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានរៀបចំនូវការសរសេរ ជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ដោយបានជ្រើសរើសប្រធានបទស្ដីអំពី "**ទំនាក់ទំនងសហព័ទ្ធក្នុងនីតិគ្រួសារ**" ដើម្បីចូលរួមចំណែកឲ្យប្រជាពលរដ្ឋកម្ពុជា ក៏ដូចជាបងប្អូន-មិត្តនិស្សិត បានយល់កាន់តែយល់ច្បាស់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនក្នុងនាមជាសហព័ទ្ធនៅក្នុងចំណងអាពាហ៍ពិពាហ៍ ក៏ដូចជាក្រោយការបញ្ចប់នៃចំណងអាពាហ៍ពិពាហ៍។ យើងខ្ញុំទាំងពីរនាក់សង្ឃឹមយ៉ាងមុតមាំថា កម្រងសៀវភៅនេះនឹងផ្ដល់ជាអត្ថប្រយោជន៍បន្ថែមទៅដល់បងប្អូន មិត្តនិស្សិតជំនាន់ក្រោយ ក៏ដូចជាប្រជាពលរដ្ឋទូទៅដែលមានបំណងចង់ស្វែងយល់ និងជួយបង្កើនជាចំណេះដឹងរបស់ខ្លួនបន្ថែមទាក់ទងនឹងទំនាក់ទំនងរបស់សហព័ទ្ធក្នុងនីតិគ្រួសារ ឬអាចទុកជាឯកសារជំនួយសម្រាប់ការសិក្សាស្រាវជ្រាវនាពេលខាងមុខ។

ដោយហេតុថាអត្ថបទសិក្សាទាក់ទងទៅនឹងប្រធានបទ "**ទំនាក់ទំនងសហព័ទ្ធក្នុងនីតិគ្រួសារ**" អាចនឹងមានការកែប្រែមួយចំនួនលើលក្ខខណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាមួយចំនួន ដែលអាចនឹងនាំឲ្យមានការកែប្រែខ្លឹមសារខ្លះៗ។ ប៉ុន្តែយើងខ្ញុំនៅតែសង្ឃឹមយ៉ាងមុតមាំថា អត្ថបទសារណាបញ្ចប់ការសិក្សាមួយនេះ នឹងអាចយកមកធ្វើជាមូលដ្ឋានបានសម្រាប់ការសិក្សាស្រាវជ្រាវនាពេលបច្ចុប្បន្ន និងអនាគត។ យ៉ាងណាមិញដើម្បីបំពេញបន្ថែមនូវចំណុចខ្វះខាត បងប្អូន-មិត្តអ្នកអាន ក៏ចូលរួមក្នុងការកែលម្អក្នុងន័យស្ថាបនាក្នុងអត្ថបទស្រាវជ្រាវនេះបានផងដែរ។

ជាចុងក្រោយយើងខ្ញុំសូមថ្លែងអំណរអរគុណ យ៉ាងជ្រាលជ្រៅដល់អ្នកទាំងអស់គ្នាដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការអាន និងស្វែងយល់អំពីស្នាដៃរបស់យើងខ្ញុំ។ យើងខ្ញុំគោរពជូនពរ និងសូមប្រសិទ្ធិពរជ័យជូនដល់បងប្អូន មិត្តអ្នកអាន និងប្រជាពលរដ្ឋកម្ពុជាទាំងមូល ឱ្យជួបប្រទះតែសំណាងល្អ និងសមប្រកបក្នុងមុខរបរទទួលទានប្រចាំថ្ងៃ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១
ក. លំនាំបញ្ហា ........ ១
ខ. ចំណោទបញ្ហា ........ ២
គ. គោលបំណង និងសារសំខាន់នៃការស្រាវជ្រាវ ........ ២
ឃ. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ២
ង. វិធីសាស្ត្រស្រាវជ្រាវ ........ ៣
ច. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣
**ជំពូកទី១៖ ទំនាក់ទំនងសហព័ទ្ធអំឡុងពេលអាពាហ៍ពិពាហ៍** ........ ៥
**១.១. សញ្ញាណនៃទំនាក់ទំនងសហព័ទ្ធ** ........ ៥
១.១.១. អាពាហ៍ពិពាហ៍ និងទំនាក់ទំនងគតិយុត្ត ........ ៥
១.១.២. សញ្ញាណនៃទំនាក់ទំនងសិទ្ធិ និងកាតព្វកិច្ច ........ ៦
**១.២. សិទ្ធិសហព័ទ្ធអំឡុងពេលអាពាហ៍ពិពាហ៍** ........ ៦
១.២.១. សិទ្ធិប្រើប្រាស់នាមត្រកូល ........ ៧
១.២.២. សិទ្ធិសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ ........ ៨
១.២.៣. សិទ្ធិគ្រប់គ្រង ថែរក្សាកូន ........ ៨
១.២.៤. សិទ្ធិសហព័ទ្ធកំឡុងពេលអវត្តមានរបស់សហព័ទ្ធម្ខាងទៀត ........ ១០
១.២.៥. សិទ្ធិលើទ្រព្យសម្បត្តិរបស់សហព័ទ្ធ ........ ១១
១.២.៥.១. ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា ........ ១១
១.២.៥.២. ប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់ ........ ១៣
**១.៣. ភាតព្វកិច្ចសហព័ទ្ធអំឡុងពេលអាពាហ៍ពិពាហ៍** ........ ១៧
១.៣.១. កាតព្វកិច្ចសាមគ្គី ........ ១៨
១.៣.២. កាតព្វកិច្ចជួយសង្គ្រោះ ........ ១៨
១.៣.៣. បន្ទុកសោហ៊ុយអាពាហ៍ពិពាហ៍ ........ ១៩

១.៣.៤. កាតព្វកិច្ចសហព័ទ្ធចំពោះកូន ...................................................... ១៩

១.៣.៥. កាតព្វកិច្ចចំពោះបំណុល ............................................................... ១៩

**ជំពូកទី ២. ទំនាក់ទំនងសហព័ទ្ធក្រោយបញ្ចប់ចំណងអាពាហ៍ពិពាហ៍** ............ ២១

**២.១. អំពីការលែងលះ** ........................................................................ ២១

២.១.១. សញ្ញាណនៃការលែងលះ និង ការបញ្ចប់ប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិ ...................................................................................... ២១

២.១.១.១. សញ្ញាណនៃការលែងលះ ............................................................ ២១

២.១.១.២. សញ្ញាណនៃការបញ្ចប់ប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិ ................ ២១

២.១.២. មូលហេតុនៃការលែងលះ និង ការបញ្ចប់ប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិ ...................................................................................... ២២

២.១.៣. លក្ខខណ្ឌនៃការលែងលះ ............................................................ ២២

២.១.៣.១. លក្ខខណ្ឌតាមច្បាប់ ................................................................ ២២

២.១.៣.២. ការព្រមព្រៀងរបស់គូភាគី ........................................................ ២៥

២.១.៤. នីតិវិធីនៃការលែងលះ ................................................................ ២៥

២.១.៤.១. នីតិវិធីនៃការលែងលះ ករណីមានការព្រមព្រៀងគ្នា ........................ ២៥

២.១.៤.២. នីតិវិធីនៃការលែងលះ ករណីមានពាក្យបណ្ដឹងលែងលះ .................. ២៦

២.១.៤.៣. ទម្រង់នៃបណ្ដឹងលែងលះ .......................................................... ២៧

២.១.៤.៤. អ្នកមានសិទ្ធិប្ដឹងលែងលះ ....................................................... ២៧

២.១.៤.៥. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ........................................ ២៧

២.១.៤.៦. នីតិវិធីនៃការទាញហេតុផលផ្ទាល់មាត់ ........................................ ២៨

២.១.៥. ការចាត់ចែងរក្សាការពារ ............................................................ ២៨

២.១.៦. សេចក្ដីសម្រេចរបស់តុលាការ ...................................................... ២៩

**២.២. អានុភាពនៃការលែងលះ** ................................................................ ៣១

២.២.១. អានុភាពនៃការលែងលះទាក់ទងនឹងនាមត្រកូលសហព័ទ្ធ ........................ ៣១

២.២.២. អានុភាពនៃការលែងលះចំពោះកូន ................................................ ៣១

២.២.៣. អានុភាពនៃការលែងលះ និងបែងចែកទ្រព្យសម្បត្តិករណីមានកិច្ចសន្យាទ្រព្យសម្បត្តិ ឬ ព្រមព្រៀងគ្នា ..... ៣២
២.២.៤. អានុភាពនៃការលែងលះ និងបំណែងចែកទ្រព្យសម្បត្តិតាមផ្លូវច្បាប់ ..... ៣៣
២.២.៤.១. អំពីទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ ..... ៣៤
២.២.៤.២. អំពីទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ ..... ៣៤
២.២.៤.៣. អំពីបំណុលរួមរបស់សហព័ទ្ធ ..... ៣៥
២.២.៤.៤. លក្ខខណ្ឌជាមូលដ្ឋាននៃការវិនិច្ឆ័យរបស់តុលាការ ..... ៣៥
២.២.៥. អំពីអាហារកាតព្វកិច្ចរបស់សហព័ទ្ធ ..... ៣៧
២.២.៥.១. និយមន័យអាហារកាតព្វកិច្ច ..... ៣៨
២.២.៥.២. ទំហំ និងលំដាប់នៃជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច ..... ៣៨
២.២.៥.៣. អាហារកាតព្វកិច្ចក្រោយលែងលះ ..... ៣៨
២.២.៥.៤. អាហារកាតព្វកិច្ចចំពោះសហព័ទ្ធ ..... ៣៩
២.២.៥.៥. កម្រិត ឬ របៀបនៃការផ្គត់ផ្គង់អាហារកាតព្វកិច្ច ..... ៤០
២.២.៥.៦. ការផ្លាស់ប្តូរ ឬ លុបចោលទំនាក់ទំនងនៃអាហារកាតព្វកិច្ច ..... ៤០
២.២.៥.៧. ការហាមឃាត់នូវការចាត់ចែងសិទ្ធិទាមទារអាហារកាតព្វកិច្ច ..... ៤០
២.២.៥.៨. អំពីអាហារកាតព្វកិច្ចចំពោះកូន ..... ៤០
២.២.៥.៩. ទណ្ឌកម្មនៃការមិនផ្គត់ផ្គង់អាហារកាតព្វកិច្ច ..... ៤១
២.២.៦. បញ្ហាចោទក្នុងការបែងចែកទ្រព្យសម្បត្តិក្រោយពេលលែងលះ ..... ៤២
២.២.៦.១. បញ្ហាចោទលើសហព័ទ្ធ និងកូនៗ ..... ៤២
២.២.៦.២. បញ្ហាចោទលើការអនុវត្តជាក់ស្តែង ..... ៤២
**២.៣. អំពីការបាត់ខ្លួន** ..... ៤៣
២.៣.១. លក្ខខណ្ឌនៃការប្រកាសអំពីការបាត់ខ្លួនជាទូទៅ ..... ៤៣
២.៣.២. លក្ខខណ្ឌនៃការប្រកាសអំពីការបាត់ខ្លួនករណីពិសេស ..... ៤៣
២.៣.៣. ការដាស់តឿនជាសាធារណៈ ..... ៤៤
២.៣.៤. អានុភាពនៃការប្រកាសអំពីការបាត់ខ្លួន ..... ៤៤

២.៣.៤.១. អានុភាពចំពោះទំនាក់ទំនងគតិយុត្ត ....................................................... ៤៤

២.៣.៤.២. អានុភាពចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ .................. ៤៥

**២.៤. អំពីមរណភាពរបស់សហព័ទ្ធ** ....................................................... ៤៦

២.៤.១. និយមន័យសន្តតិកម្ម និង សន្តតិជន ....................................................... ៤៦

២.៤.២. ប្រភេទសន្តតិកម្ម ....................................................... ៤៦

២.៤.២.១. សន្តតិកម្មតាមច្បាប់ ....................................................... ៤៦

២.៤.២.២. សន្តតិកម្មតាមមតកសាសន៍ ....................................................... ៤៦

២.៤.៣ សិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធដែលបានទទួលក្រោយមរណភាពរបស់សហព័ទ្ធ ម្ខាងទៀត ....................................................... ៤៨

២.៤.៣.១. សន្តតិកម្មរបស់សហព័ទ្ធ ....................................................... ៤៩

២.៤.៣.២. ចំណែកនៃមរតករបស់សហព័ទ្ធជាមួយញាតិរបស់សហព័ទ្ធម្ខាងទៀត ៤៩

២.៤.៣.៣. សិទ្ធិនៃចំណែកមរតករបស់សហព័ទ្ធក្នុងភាគបម្រុង .......................... ៥០

២.៤.៣.៤. ករណីយកិច្ចសហព័ទ្ធចំពោះមតកជន ....................................................... ៥១

**សេចក្តីសន្និដ្ឋាន** ....................................................... ៥៣

**អនុសាសន៍** ....................................................... ៥៤

**ឯកសារយោង** .......................................................

**ឧបសម្ព័ន្ធ** .......................................................

# សេចក្តីផ្តើម

## ក. លំនាំបញ្ហា

ប្រជាពលរដ្ឋគ្រប់រូបអាចរស់នៅក្នុងសង្គមមួយប្រកបដោយ សុខសន្តិភាព សុវត្ថិភាព និង សុខុមាភាព បានរមែងសង្គមនោះមាន ច្បាប់ និងដំណើរប្រព្រឹត្តទៅនៃច្បាប់ប្រកបដោយសមភាព និងយុត្តិធម៌។ តួយ៉ាងកម្ពុជាជាប្រទេសប្រជាធិបតេយ្យមួយ ដែលមានការប្រកាន់នូវរបបរាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញ។[1] ប្រព័ន្ធច្បាប់បានដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងប្រជាពលរដ្ឋ និង រក្សាស្ថេរភាព នៃដំណើរប្រព្រឹត្តទៅក្នុងសង្គមកម្ពុជា។ ការគ្រប់គ្រងលើគ្រួសារ រួមទាំងទ្រព្យសម្បត្តិឯកជនរបស់ប្រជាពលរដ្ឋដោយផ្អែកលើមាត្រដ្ឋានច្បាប់ជាក់លាក់មួយចំនួន បានបង្កើតនូវភាពប្រត្យក្សមួយក្នុងការគ្រប់គ្រង និងថែរក្សាស្ថេរភាពក្នុងគ្រួសារ ក៏ដូចជាសង្គមកម្ពុជា។

ផ្តើមចេញពីភាពស្រុះស្រួលក្នុងគ្រួសារ ដែលជាមូលដ្ឋានក្នុងការរក្សាស្ថេរភាព និងការអភិវឌ្ឍសង្គមជាតិ។ គេសង្កេតឃើញថាវិវាទដែលកើតឡើងក្នុងគ្រួសារមួយចំនួនបានកើតចេញពីបញ្ហានៃការគ្រប់គ្រងទ្រព្យសម្បត្តិក្នុងគ្រួសារទាំងមូលទាំងមុន និងក្រោយជីវិតអាពាហ៍ពិពាហ៍។ ម្យ៉ាងវិញទៀត បញ្ហាប្រឈមដែលកើតមានឡើងអំឡុងពេលបាត់ខ្លួន និងអវត្តមានរបស់សហព័ទ្ធម្ខាងក៏បានក្លាយជាបញ្ហាចោទសម្រាប់ភាគីម្ខាងទៀតផងដែរ ទាក់ទងនឹងការគ្រប់គ្រងលើប្រព័ន្ធទ្រព្យសម្បត្តិក្នុងគ្រួសារ។ ហេតុនេះប្រធានបទ៖ "**ទំនាក់ទំនងសហព័ទ្ធក្នុងនីតិគ្រួសារ**" នឹងមានការលើកឡើងពីបញ្ហាប្រឈមភាពខ្វះចន្លោះ និងដំណោះស្រាយនានានៃការអនុវត្ត ក្នុងការដោះ-ស្រាយវិវាទដែលទាក់ទងទៅនឹងទំនាក់ទំនងសិទ្ធិ និងកាតព្វកិច្ចរបស់សហព័ទ្ធក្នុងប្រព័ន្ធ នៃច្បាប់ទាំងឡាយដែលមានជាធរមាននៅកម្ពុជា ដែលមានភាពទាក់ទងទៅនឹងទំនាក់ទំនងនៃចំណងអាពាហ៍ពិពាហ៍របស់សហព័ទ្ធ។

ជាការឆ្លើយតបនឹងបញ្ហាចោទទាក់ទងនឹងវិវាទខាងលើ តាមរយៈអង្គការនីតិបញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា បានបង្កើតឡើងនូវនិយាមគតិយុត្តមួយចំនួនដែលធ្វើការដោះស្រាយលើបញ្ហាខាងលើជាអាទិ៍ ការតាក់តែងឡើងនូវ ក្រមនីតិរដ្ឋប្បវេណី ច្បាប់ស្តីពីឯកពន្ធភាព ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារជាដើម។ ច្បាប់ទាំងនេះជាចម្លើយឆ្លើយតបទៅលើបញ្ហាចោទទាំងឡាយដែលកើតមានឡើងក្នុងសង្គមគ្រួសាររបស់ប្រជាជនកម្ពុជាទាំងមូល។ ច្បាប់ទាំងនេះមានសារៈសំខាន់ណាស់ក្នុងការរក្សា និងទប់ស្កាត់បញ្ហានានាដែលបម្រុងនឹងកើតមានឡើងស្របតាមស្តង់ដាច្បាប់យ៉ាងច្បាស់លាស់។

[1] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, មាត្រា១ (ពីពេលនេះតទៅហៅថា រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣)។

## ខ. ចំណោទបញ្ហា

បញ្ហាចោទដែលបានកើតឡើងទាក់ទងនឹងប្រធានបទមានដូចជា បញ្ហាប្រឈមនៃការយល់ដឹងពីបច្ចុប្បន្នភាពនៃច្បាប់របស់ប្រជាពលរដ្ឋកម្ពុជា ដំណើរការដោះស្រាយវិវាទទៅតាមស្ថានភាពច្បាប់ជាធរមាន និងលក្ខខណ្ឌដែលទាមទារឲ្យភាគីពាក់ព័ន្ធចូលរួមក្នុងការអនុវត្តជាអាទិ៍។

សំណួរជាច្រើនត្រូវបានចោទឡើងថា៖

- តើស្ថានភាពនៃការយល់ដឹងច្បាប់ជាទូទៅរបស់ប្រជាជនកម្ពុជាក្នុងនីតិគ្រួសារស្ថិតត្រឹមកម្រិតណា?
- តើច្បាប់ដែលចូលជាធរមានទាក់ទងនឹងនីតិគ្រួសារ នៅប្រទេសកម្ពុជាបានកំណត់ជាបទប្បញ្ញត្តិដូចម្តេចខ្លះសម្រាប់សហាព័ទ្ធ?
- ដើម្បីឲ្យការដោះស្រាយវិវាទប្រកបដោយតម្លាភាព សច្ចភាព និងយុត្តិធម៌ តើគូភាគីនៃវិវាទក្នុងនីតិគ្រួសារត្រូវគោរពនូវលក្ខខណ្ឌអ្វីខ្លះ?

## គ. គោលបំណង និងសារសំខាន់នៃការស្រាវជ្រាវ

គោលបំណងសំខាន់នៃការស្រាវជ្រាវ គឺការបង្ហាញឲ្យឃើញពីបញ្ហាចោទដែលកើតមានឡើង ក្នុងទំនាក់ទំនងនៃការគ្រប់គ្រងទ្រព្យសម្បត្តិ ដែលរួមមានសិទ្ធិ និងកាតព្វកិច្ចរបស់សហាព័ទ្ធក្នុងប្រព័ន្ធនៃនីតិគ្រួសារ។ បន្ថែមពីនេះទៀតការស្រាវជ្រាវលើប្រធានបទ ក៏បានលើកបង្ហាញពីដំណោះស្រាយនានាលើបញ្ហាប្រឈមទាំងឡាយ ដែលកើតមានឡើងក្នុងដំណើរការនៃការដោះ-ស្រាយវិវាទលើទំនាស់ ដែលទាក់ទងនឹងការគ្រប់គ្រងប្រព័ន្ធទ្រព្យសម្បត្តិក្នុងគ្រួសារ។

ម្យ៉ាងវិញទៀត ការស្រាវជ្រាវលើប្រធានបទខាងលើ ក៏បានក្លាយជាឯកសារយ៉ាងសំខាន់មួយផងដែរសម្រាប់ផ្តល់ជាប្រភពទិន្នន័យជូនដល់ បងប្អូន-សិស្ស-និស្សិត ជំនាន់ក្រោយឲ្យមានភាពងាយស្រួល ក្នុងការយកទិន្នន័យព័ត៌មានសំខាន់ៗសម្រាប់ជាឯកសារដល់ការធ្វើកិច្ចការស្រាវជ្រាវដែលទាក់ទងផងដែរ។ មួយវិញទៀតឯកសារស្រាវជ្រាវនេះក៏អាចឲ្យប្រជាពលរដ្ឋកម្ពុជា បានជ្រួតជ្រាបពីស្ថានភាពនៃការអនុវត្តច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ។

## ឃ. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទ "**ទំនាក់ទំនងសហាព័ទ្ធក្នុងនីតិគ្រួសារ**" នឹងស្រាវជ្រាវគ្របដណ្តប់ទៅលើទំនាក់ទំនងរបស់សហាព័ទ្ធលើប្រព័ន្ធទ្រព្យសម្បត្តិសហាព័ទ្ធ រួមទាំងសិទ្ធិ និងកាតព្វកិច្ចជាចាំបាច់របស់សហាព័ទ្ធដែលមានចាប់ពីពេលកកើតអាពាហ៍ពិពាហ៍ រហូតដល់ក្រោយការបញ្ចប់ចំណងដែលបានកំណត់ក្នុងប្រព័ន្ធនៃច្បាប់ដែលទាក់ទងនឹងការគ្រប់គ្រងគ្រួសារនៅកម្ពុជា។ បន្ថែមពីនេះទៀត

កិច្ចការស្រាវជ្រាវនៃប្រធានបទនេះនឹងផ្តោតសំខាន់លើ ទំនាក់ទំនងគតិយុត្តរវាងតែសហព័ទ្ធ ដែលជាប្រជាពលរដ្ឋខ្មែរ នឹងខ្មែរតែប៉ុណ្ណោះ។

ទន្ទឹមនឹងនេះ ប្រធានបទខាងលើ នឹងធ្វើការស្រាវជ្រាវទាក់ទងនឹងច្បាប់ដែលកំពុងមានជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាដូចជា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ច្បាប់ ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩ ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ច្បាប់ស្តីពីឯកពន្ធភាពឆ្នាំ២០០៦ រួមទាំងព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សាលក្រម សាលដីកា នានាដែលមានចែងទាក់ទងនឹងទំនាក់ទំនងរបស់សហព័ទ្ធក្នុងនីតិគ្រួសារ។ ក្នុងនោះកិច្ចការស្រាវជ្រាវក៏នឹងមានការប្រៀបធៀបលក្ខខណ្ឌមួយចំនួននៃច្បាប់ចាស់ និងច្បាប់ថ្មីផងដែរ។

## ខ. វិធីសាស្ត្រស្រាវជ្រាវ

ប្រធានបទខាងលើនេះ នឹងមានការលើកយកមកបង្ហាញនូវប្រភពឯកសារពីគ្រប់ទម្រង់ទាំងអស់រួមទាំងឯកសារច្បាប់ ឯកសារជាសៀវភៅបោះពុម្ព ឯកសារពីបណ្តាញផ្សព្វផ្សាយអ៊ីនធើណិត រួមផ្សំជាមួយនឹងទ្រឹស្តីបង្ហាត់បង្រៀន និង ពន្យល់បកស្រាយរបស់អ្នកវិជ្ជាជីវៈច្បាប់ និងសាស្ត្រាចារ្យនានាផងដែរ ក្នុងការបង្កើតជាឯកសារស្រាវជ្រាវនេះឡើង។ ការវិភាគលើឯកសារច្បាប់ដោយផ្អែកលើអត្ថិភាពជាធរមាននៃច្បាប់ដែលកំពុងមានអានុភាពអនុវត្ត រួមបញ្ចូលទាំងរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សាលដីកា សាលក្រម និងបទដ្ឋានគតិយុត្តនានាដែលកំពុងអនុវត្តលើដែនដីនៃប្រទេសកម្ពុជា។ បន្ថែមពីនេះទៀត ឯកសារស្រាវជាសៀវភៅសុទ្ធតែដកស្រង់ចេញពីសៀវភៅរបស់អ្នកនីតិនិពន្ធ ដ៏គួរឲ្យជឿជាក់ និងមានប្រភពស្រាវជ្រាវច្បាស់លាស់។

## ច. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ប្រធានបទស្រាវជ្រាវ "**ទំនាក់ទំនងសហព័ទ្ធក្នុងប្រព័ន្ធនីតិគ្រួសារ**" នឹងមានការលើកមកបង្ហាញនូវពីរជំពូកសំខាន់ៗគឺ៖

- **ជំពូកទី១. ទំនាក់ទំនងសហព័ទ្ធអំឡុងពេលអាពាហ៍ពិពាហ៍៖** នឹងមានការលើកបង្ហាញពីសញ្ញាណនៃទំនាក់ទំនងសហព័ទ្ធ សិទ្ធិ និងកាតព្វកិច្ចដែលសហព័ទ្ធមាន និងត្រូវបំពេញក្នុងកំឡុងពេលអាពាហ៍ពិពាហ៍ ដូចជាការចាត់ចែង និងចំណាយនានានៅក្នុងបន្ទុកគ្រួសារជាដើម។
- **ជំពូកទី ២. ទំនាក់ទំនងសហព័ទ្ធក្រោយបញ្ចប់ចំណងអាពាហ៍ពិពាហ៍៖** នឹងមានការបកស្រាយពីសិទ្ធិ និងកាតព្វកិច្ចដែលសហព័ទ្ធមាន និងត្រូវបំពេញក្រោយពេលបញ្ចប់នូវចំណងអាពាហ៍ពិពាហ៍តាមរយៈ ការលែងលះ ការបាត់ខ្លួន និង

មរណភាពរបស់សហព័ទ្ធរួមទាំងលក្ខខណ្ឌ និងនីតិវិធីនៃការលែងលះ អាហារកាតព្វកិច្ចចំពោះកូន និងសហព័ទ្ធជាអាទិ៍។

# ជំពូកទី១៖ ទំនាក់ទំនងសហព័ទ្ធអំឡុងពេលអាពាហ៍ពិពាហ៍

ក្រោយពីបង្កើតចំណងអាពាហ៍ពិពាហ៍រួចហើយ ចំណងគតិយុត្តនៃទំនាក់ទំនងរបស់សហព័ទ្ធក៏ត្រូវបានចាប់ផ្តើមឡើង។ ក្នុងនោះសញ្ញាណនៃទំនាក់ទំនងសហព័ទ្ធ សិទ្ធ និងកាតព្វកិច្ច ដែលមានទាក់ទងនឹងសហព័ទ្ធនឹងត្រូវលើកយកមកបកស្រាយ នៅតាមចំណុចនីមួយៗដូចខាងក្រោម៖

## ១.១. សញ្ញាណនៃទំនាក់ទំនងសហព័ទ្ធ

ចំណុចនៃសញ្ញាណនៃទំនាក់ទំនងសហព័ទ្ធ នឹងលើកមកបង្ហាញពីអានុភាពគតិយុត្តនៃចំណងអាពាហ៍ពិពាហ៍(១.១.១) និងសញ្ញាណនៃទំនាក់ទំនងសិទ្ធិ និងកាតព្វកិច្ច(១.១.២)។

### ១.១.១. អាពាហ៍ពិពាហ៍ និងទំនាក់ទំនងគតិយុត្ត

បុគ្គលពីរនាក់អាចមានទំនាក់ទំនងពិសេសរហូតដល់មានការបង្កើតគ្រួសារ លុះត្រាតែអ្នកទាំងពីរបានព្រមព្រៀងគ្នាដោយការស្ម័គ្រចិត្ត និងមានការទទួលស្គាល់ដោយច្បាប់ ដែលជាហេតុបង្កើតឲ្យមានទំនាក់ទំនងសហព័ទ្ធក្នុងនីតិគ្រួសារ។ ដើម្បីធ្វើការស្វែងយល់ឱ្យបានកាន់តែច្បាស់អំពីទំនាក់ទំនងមួយនេះ ចាំបាច់ណាស់ត្រូវយល់ពាក្យគន្លឹះមួយចំនួនជាមុនសិន ដូចជាពាក្យ «**សហព័ទ្ធ**» និងពាក្យ «**នីតិគ្រួសារ**»។ ពាក្យថា សហព័ទ្ធ មានន័យថាជាប្តី ឬប្រពន្ធ ឬ ទាំងប្តី ទាំងប្រពន្ធដែលទទួលបាននូវ ឋានៈជាសហព័ទ្ធនេះ ក្រោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាម ច្បាប់។[2] រីឯពាក្យ «**នីតិគ្រួសារ**» ជាវិធានគតិយុត្តដែលសិក្សាទៅលើទំនាក់ទំនងញាតិ។[3] ដូច្នេះ "**ទំនាក់-ទំនងសហ័ទ្ធក្នុងនីតិគ្រួសារ**" គឺសំដៅទៅលើប្តី ឬ ប្រពន្ធដែលទទួលនាមជាសហព័ទ្ធ ក្រោយការចុះសំបុត្រអាពាហ៍ពិពាហ៍ ដែលបង្កើតឱ្យមានទំនាក់ទំនងញាតិឡើង។

ប្រសិនបើបុរស និងនារីនោះបានរួមរស់នឹងបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី តែពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ នោះគេមិនបានចាត់ទុកជាសហព័ទ្ធដែលទទួលស្គាល់តាមផ្លូវច្បាប់នោះទេ។ បើសិនមានករណីដែលប្តីប្រពន្ធមានបញ្ហាមិនចុះសម្រុង ឈានដល់ការលែងលះតាមផ្លូវតុលាការ នោះតុលាការនឹងមាន ការពិបាកក្នុងការដោះស្រាយ ដោយហេតុផលអ្នកទាំងពីរមិនបានគោរពគោលការណ៍ច្បាប់ដែលចាំបាច់ត្រូវទៅចុះសំបុត្រអាពាហ៍ពិពាហ៍ ដូចដែលមានចែងក្នុងច្បាប់ជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

---

[2] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, សទ្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ២២ (ចាប់ពីពេលនេះតទៅហៅថា ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧)។

[3] រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត, *នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ* (ភ្នំពេញ៖ រោងពុម្ពជោគជ័យ, ២០១៧), ៨៤៣។

### ១.១.២. សញ្ញាណនៃទំនាក់ទំនងសិទ្ធិ និងកាតព្វកិច្ច

ហេតុដូចនេះមុននឹងអាចឱ្យបុគ្គលពីរនាក់ក្លាយជាប្ដីប្រពន្ធ គឺពួកគេបានឆ្លងកាត់នៅរឿងរ៉ាវជាច្រើនទម្រាំតែបានរួមរស់នៅជាមួយគ្នា តួយ៉ាងបន្ទាប់ពីរៀបអាពាហ៍ពិពាហ៍ហើយ ក៏ឃើញថាសហព័ទ្ធនៅតែមានទំនួលខុសត្រូវចំពោះសិទ្ធិ និងកាតព្វកិច្ចរបស់សហព័ទ្ធដែលមានអំឡុងពេលអាពាហ៍ពិពាហ៍ ក៏ដូចជាសិទ្ធិ និងកាតព្វកិច្ចក្រោយចំណងអាពាហ៍ពិពាហ៍ជាដើម។

បុគ្គលពីរនាក់បានបង្កើតចំណងអាពាហ៍ពិពាហ៍ ឃើញថាពួកគេចាប់ផ្ដើមបង្កើតឱ្យមាននូវសិទ្ធិ និងកាតព្វកិច្ចអំឡុងពេលនោះផងដែរ។ សួរថាតើសហព័ទ្ធមានសិទ្ធិ និងកាតព្វកិច្ចអ្វីខ្លះនៅក្នុងនីតិគ្រួសារ?

យោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក្រោយពីអាពាហ៍ពិពាហ៍មួយត្រូវបានបង្កើតឡើងហើយនោះ គូភាគីនៃអាពាហ៍ពិពាហ៍នឹងក្លាយខ្លួនទៅជាសហព័ទ្ធ ហើយក្នុងឋានៈជាសហព័ទ្ធនេះដែរ គឺផ្ដល់ឱ្យនូវសិទ្ធិ និងកាតព្វកិច្ចមួយចំនួនចំពោះខ្លួនឯង និងសហព័ទ្ធរបស់ខ្លួន។ លើសពីនេះទៅទៀត លក្ខខណ្ឌច្បាប់ ក៏បានជះឥទ្ធិពលទៅដល់ទ្រព្យសម្បត្តិ និងការគ្រប់គ្រងថែរក្សាកូនផងដែរ។

## ១.២. សិទ្ធិសហព័ទ្ធអំឡុងពេលអាពាហ៍ពិពាហ៍

ពេលដែលបុរស និងស្ត្រីក្លាយខ្លួនទៅជាសហព័ទ្ធ នោះសហព័ទ្ធត្រូវមានសិទ្ធិមួយចំនួនអំឡុងពេលអាពាហ៍ពិពាហ៍ដែលមិនដូចពេលដែលខ្លួននៅលីវឡើយ។ សិទ្ធិ និងកាតព្វកិច្ចរបស់សហព័ទ្ធ គឺត្រូវមានទំនួលខុសត្រូវខ្ពស់ដើម្បីកសាងគ្រួសារមួយដែលប្រកបទៅដោយសុភមង្គល។

ដោយហេតុថាប្រទេសនៅលើសកលោក គឺបានផ្ដល់សិទ្ធិឱ្យបុរស និងនារីមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់។ ប្រទេសកម្ពុជា ក៏មិនខុសពីបណ្ដាប្រទេសលើសកលោកដែរ ហេតុដូចនេះហើយសិទ្ធិសេរីភាពរបស់សហព័ទ្ធក៏មានសមភាពដែរ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងយ៉ាងច្បាស់ថា បុរស និងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសទាំងក្នុងជីវភាពអាពាហ៍ពិពាហ៍ និងគ្រួសារ។[4] ហេតុដូចនេះសហព័ទ្ធមានសិទ្ធិគ្រប់គ្រាន់ក្នុងការសម្រេចចិត្តនូវអ្វីដែលខ្លួនគិតថាពេញចិត្តនឹងធ្វើ។

[4] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣, មាត្រា ៤៥។

### ១.២.១. សិទ្ធិប្រើប្រាស់នាមត្រកូល

ប្ដី ប្រពន្ធដែលរៀបអាពាហ៍ពិពាហ៍រួចហើយ អាចមានសិទ្ធិក្នុងការប្រើនាមត្រកូលរបស់ប្ដី ឬប្រពន្ធ ឬអាចប្រើនាមត្រកូលដើមរៀងៗខ្លួន ដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍បាន។[5] បើទោះបីជាអ្នកទាំងពីរបានរៀបការជាមួយគ្នាក៏ដោយ ក៏អ្នកទាំងពីរនៅតែមានសិទ្ធិជ្រើសរើសនាមត្រកូលរបស់ខ្លួនឯងបាន។ សម្រាប់សង្គមខ្មែរបច្ចុប្បន្ន បើទោះបីជាសហាព័ទ្ធបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាក៏ដោយ ក៏សហាព័ទ្ធនៅតែប្រើប្រាស់នាមត្រកូលរបស់ខ្លួនដដែល។

ការផ្ដល់សិទ្ធិឱ្យសហាព័ទ្ធមានសិទ្ធិក្នុងការប្រើប្រាស់នាមត្រកូលរបស់ខ្លួន គឺជាការបង្ហាញឱ្យឃើញពីសមភាពរវាង ប្ដី និងប្រពន្ធ ដោយមិនប្រកាន់ ឬរើសអើងចំពោះសហាព័ទ្ធណាម្ខាងក្នុងការសម្រេចចិត្ត។ យ៉ាងណាមិញ ការដែលសហាព័ទ្ធ មិនប្រើប្រាស់នាមត្រកូលរបស់សហាព័ទ្ធម្ខាងទៀត ព្រោះ នាមត្រកូល គឺជាការបង្ហាញនូវវង្សត្រកូលរបស់គ្រួសារនីមួយៗ ដែលបានបន្សល់ទុកមកតាំងពីដើមមក ហើយក៏ចង់រក្សាមិនឱ្យបាត់បង់។ ហេតុដូចនេះ ច្បាប់នៃព្រះរាជាណាចក្រកម្ពុជាបានបើកសិទ្ធិសេរីភាពឱ្យសហាព័ទ្ធជ្រើសរើសនាមត្រកូល ដោយខ្លួនឯងបន្ទាប់ពីរៀបអាពាហ៍ពិពាហ៍រួច។ បន្ថែមពីលើនេះទៀតក៏មានគ្រួសារមួយចំនួនដែលមានឋានៈក្នុងសង្គមខ្មែរ បានយកនាមត្រកូលរបស់ប្ដីមកប្រើជានាមត្រកូលរបស់ខ្លួន (ប្រពន្ធ) បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍រួចផងដែរ។

បើក្រឡេកមកមើលប្រទេសជប៉ុន ដែលជាប្រទេសឧស្សាហកម្មជឿនលឿន តែបែរជានៅដើរតាមច្បាប់បុរាណរបស់ខ្លួនទៅវិញ ទាក់ទងទៅហ្នឹងនាមត្រកូលរបស់ប្ដីប្រពន្ធ។ ដោយហេតុថាសហាព័ទ្ធអាចទទួលបានអាពាហ៍ពិពាហ៍ស្របច្បាប់ លុះត្រាតែ ប្ដីប្រពន្ធ មាននាមត្រកូលដូចគ្នានៅពេលរៀបអាពាហ៍ពិពាហ៍ ដោយអាចយកនាមត្រកូលតាមប្ដី ឬប្រពន្ធណាម្ខាង។ ប្រសិនបើប្ដីប្រពន្ធនោះពុំមាននាមត្រកូលដូចគ្នា នោះអាពាហ៍ពិពាហ៍របស់អ្នកទាំងពីរមិនបានចាត់ទុកថាស្របច្បាប់នោះទេ។[6] ត្រង់ចំណុចនេះបង្ហាញឱ្យឃើញពីភាពខុសគ្នា រវាងប្រទេសកម្ពុជានិងជប៉ុន ត្រង់ប្រជាជនជប៉ុនត្រូវតែគោរពតាមច្បាប់ ប្រសិនបើចង់បានអាពាហ៍ពិពាហ៍ស្របច្បាប់មួយ ដោយមិនមែនផ្ដល់សិទ្ធិដូចកម្ពុជា ដែលអាចឱ្យភាគីដែលជាសហាព័ទ្ធហ្នឹងគ្នា មានសិទ្ធិគ្រប់គ្រាន់ក្នុងការជ្រើសរើសនាមត្រកូលរបស់ខ្លួន។

[5] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៦៥។

[6] *LookingTODAY*, "នៅជប៉ុន បើចង់រៀបការស្របច្បាប់ ទាល់តែប្ដីប្រពន្ធ មាននាមត្រកូលដូចគ្នា," 08 មករា ២០១៨, https://www.lookingtoday.com/art/24592.html (ចូលទស្សនាចុងក្រោយ ២៩ មិថុនា ឆ្នាំ២០១៨)។

### ១.២.២. សិទ្ធិសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ

កាលពីសម័យដើម សង្គមមិនបានឱ្យតម្លៃលើស្ត្រីភេទនោះទេ គឺស្ត្រីពុំមានសិទ្ធិសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ ឬការងារដែលខ្លួនឯងស្រឡាញ់ឡើយ គឺទុកឱ្យស្ត្រីនៅធ្វើការងារផ្ទះ និងមើលងាយស្ត្រីថាជាភេទទន់ខ្សោយ។ ដោយហេតុសម័យកាលចេះតែវិវត្តទៅមុខ នោះស្ត្រីត្រូវបានពិភពលោកចាប់ផ្តើមយកចិត្តទុកដាក់ និងបានបង្កើតច្បាប់ជាច្រើនដើម្បីការពារស្ត្រីភេទ ពីភាពមិនស្មើគ្នារវាងបុរស និងស្ត្រី និងបានលើកតម្កើងតម្លៃស្ត្រីភេទ ហើយជួយលើកស្ទួយឱ្យស្ត្រីខិតខំបង្ហាញពីសមត្ថភាពរបស់ខ្លួន។

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស គឺជាសេចក្តីប្រកាសមួយដែលបានគ្របដណ្តប់នូវកិច្ចការពារសិទ្ធិជាមូលដ្ឋានរបស់មនុស្សលើសកលលោក ដែលពិសេសជួយលើកតម្កើងឲ្យទទួលបាន សិទ្ធិសេរីភាពស្មើគ្នាក្នុងការជ្រើសរើសវិជ្ជាជីវៈ ដោយមិនប្រកាន់ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃទៀតឡើយ។[7] មិនត្រឹមតែមានច្បាប់សកលលោកទេ ដែលគិតគូរពីបញ្ហាសិទ្ធិសេរីភាពក្នុងការជ្រើសរើសរើសវិជ្ជាជីវៈដែលខ្លួនស្រឡាញ់ ព្រះរាជាណាចក្រកម្ពុជាក៏បានគិតគូរពីបញ្ហានេះផងដែរ។

ដូចនេះ ប្តីប្រពន្ធមានសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ ហើយអាចចូលរួមក្នុងសកម្មភាពនយោបាយ វប្បធម៌ សង្គម រៀងៗខ្លួនបាន។[8] ប្តី ឬ ប្រពន្ធ មានសិទ្ធិស្មើប្រពន្ធ ឬ ប្តីក្នុងការមាននូវវិជ្ជាជីវៈមួយដែលខ្លួនស្រឡាញ់ពេញចិត្តនឹងអាចធ្វើបាន ដោយពុំមានការហាមឃាត់ពីសហាព័ទ្ធណាម្ខាង។ ដោយមានការជំរុញនូវទឹកចិត្តដល់ស្ត្រីភេទ ទើបបច្ចុប្បន្នគេសង្កេតឃើញថាស្ត្រី ទទួលបាននូវសេរីភាពក្នុងការជ្រើសរើសការងារដែលខ្លួនស្រឡាញ់ ហើយមានស្ត្រីជាច្រើនដែលទទួលបានការងារដែលមានឋានៈខ្ពស់ក្នុងជួររាជរដ្ឋាភិបាល និងចូលរួមសកម្មភាពនានា ដែលអាចលើកទឹកចិត្តដល់ស្ត្រីដទៃទៀតដែលពុំទាន់មានភាពក្លាហាន ឱ្យខិតខំជម្នះភាពភ័យខ្លាចរបស់ខ្លួន មកមានទំនុកចិត្តក្នុងការផ្លាស់ប្តូរជីវិតរបស់ខ្លួន។

### ១.២.៣. សិទ្ធិគ្រប់គ្រង ថែរក្សាកូន

មនុស្សពីរនាក់សម្រេចចិត្តរៀបការជាមួយគ្នា គឺតែងប្រាថ្នាចង់បានសុភមង្គលក្នុងគ្រួសារ។ យ៉ាងណាមិញកូន គឺជាផ្នែកមួយនៃសេចក្តីសុខរបស់ឪពុកម្តាយ។ ប្រសិនបើអ្នកទាំងពីរមានកូន នោះពួកគេត្រូវមាន ទំនួលខុសត្រូវលើកូន គ្រប់គ្រងថែរក្សាកូន។ អ្នកមានអំណាចមេបា មានសិទ្ធិ

[7] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស, ១០ ធ្នូ ១៩៤៨, មាត្រា២។

[8] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៦៦។

និងករណីយកិច្ចអប់រំកូន។[9] ក្នុងនាមជាឪពុកម្តាយត្រូវមើលថែរក្សាកូន អប់រំ ចិញ្ចឹមបីបាច់កូនឱ្យក្លាយជាបុគ្គលល្អដែលធ្វើឱ្យអ្នកផងស្រឡាញ់រាប់អាន។

ឪពុកម្តាយមានសិទ្ធិគ្រប់គ្រង និងថែរក្សាកូននៅពេលដែលកូនរបស់ខ្លួន ស្ថិតនៅក្នុងភាពជាអនីតិជន។ ហេតុដូចនេះ កូនត្រូវទទួលបានការអនុញ្ញាតពីឪពុកម្តាយក្នុងការធ្វើសកម្មភាពមួយចំនួន ដែលមានភាពចាំបាច់។ ប្រសិនបើគ្មានការអនុញ្ញាតពីឪពុកម្តាយទេនោះ សកម្មភាពដែលអនីតិជនបានធ្វើនឹងអាចលុបចោលបាន ប្រសិនបើឪពុកម្តាយយល់ឃើញថាខាតប្រយោជន៍កូនរបស់ពួកគេ។[10] ក្នុងស្ថានភាពបែបនេះ គឺឪពុកម្តាយជាអ្នកមានអំណាចមេបាមកលើកូន ព្រោះកូនមិនទាន់គ្រប់វ័យនីតិភាព ដែលមិនទាន់អាចឯករាជ្យ និងម្ចាស់ការលើខ្លួនឯងបានឡើយ។

**ឧទាហរណ៍៖** កុមារាអាយុ ១៣ឆ្នាំ បានយកលុយឪពុកទៅទិញឡានបញ្ជាតម្លៃ ៥០$។ នៅពេលឪពុកម្តាយបានដឹង លោកទាំងពីរបានទៅជួបអ្នកលក់ហើយសុំលុបចោលការទិញរបស់កូន ខ្លួន។ ដោយហេតុថា កាលដែលកូនពួកគាត់ទៅទិញឡានបញ្ជា គឺត្រូវបាត់បង់លុយរបស់ពួកគាត់ ហើយស្ថានភាពក្នុងគ្រួសារក៏មិនល្អដូចនេះ លុយ៥០ដុល្លារ($) ពិតជាមានតម្លៃសម្រាប់ពួកគាត់ ដើម្បីទ្រទ្រង់ជីវភាពគ្រួសារ ដូច្នេះគាត់ចាំបាច់ត្រូវតែលុបចោលសកម្មភាព ដែលកូនគាត់បានទិញ ដែលពុំមានការអនុញ្ញាតពីគាត់។

ក៏ប៉ុន្តែនៅមានសកម្មភាពមួយចំនួនដែលកូនអាចទទួលបានសិទ្ធិ ឬឲ្យរួចផុតពីកាតព្វកិច្ច ឬសកម្មភាពដែលមានទំនាក់ទំនងនឹងជីវភាពរស់នៅប្រចាំថ្ងៃ។[11] ត្រង់ចំណុចនេះ គឺមានលក្ខណៈផ្ទុយពីករណីខាងលើ ព្រោះសកម្មភាពមួយចំនួនជាសកម្មភាពដែលពុំចាំបាច់មានការអនុញ្ញាតពីឪពុកម្តាយនោះទេ បើទោះជាកូនស្ថិតក្នុងភាពជាអនីតិជនក៏ដោយ។ ដូចនេះកូនមានសិទ្ធិក្នុងការធ្វើសកម្មភាពដែលមានលក្ខណៈចាំបាច់សម្រាប់សកម្មភាពប្រចាំថ្ងៃ ដោយមើលលើស្ថានភាពជាក់ ស្តែង។

**ឧទាហរណ៍៖** កុមារាអាយុ ១៣ឆ្នាំ បានទិញសៀវភៅសម្រាប់សិក្សា ដោយយកលុយដែលឪពុកម្តាយបានឱ្យទៅរៀន ហើយធ្វើការបញ្ជាទិញដោយពុំមានការអនុញ្ញាតពីឪពុកម្តាយរបស់ខ្លួន។ ដូចនេះ សកម្មភាពរបស់កុមារាអាចធ្វើបានដោយពុំចាំបាច់មានការអនុញ្ញាតពីឪពុកម្តាយ ព្រោះជាសកម្មភាពដែលបម្រើប្រយោជន៍នៃជីវភាពរស់នៅប្រចាំថ្ងៃរបស់កូនប៉ុណ្ណោះ។

[9] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ១០៨៣។
[10] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ១៨ វាក្យខណ្ឌ១។
[11] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ១៨ វាក្យខណ្ឌ២។

### ១.២.៤. សិទ្ធិសហព័ទ្ធកំឡុងពេលអវត្តមានរបស់សហព័ទ្ធម្ខាងទៀត

ក្នុងករណីដែលបុគ្គលណាម្នាក់ដែលបានចាកចេញពីលំនៅឋាន ឬ ទីសំណាក់ ហើយដែលគ្មានលទ្ធភាពនឹងត្រឡប់មកវិញដោយងាយស្រួលនោះ មិនបានចាត់តាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនទេ តុលាការអាចជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ឬ បង្គាប់ចាត់ចែងជាចាំបាច់ដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិនោះបាន តាមរយៈពាក្យសុំរបស់បុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ មេឃុំ ឬចៅសង្កាត់ដែលលំនៅឋានជននោះស្ថិតនៅ ឬតំណាងអយ្យការ។[12] ដូចនេះ បើសហព័ទ្ធណាម្ខាងបានអវត្តមាន នោះសហព័ទ្ធម្ខាងទៀត អាចទទួលសិទ្ធិក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ ដែលត្រូវបានជ្រើសតាំងដោយតុលាការ។

ការអនុញ្ញាតឱ្យសហព័ទ្ធម្ខាងទៀតគ្រប់គ្រង ទ្រព្យសម្បត្តិរបស់សហព័ទ្ធអវត្តមាន គឺដើម្បីបម្រើប្រយោជន៍ក្នុងក្រុមគ្រួសារ ជាពិសេសងាយស្រួលក្នុងការដោះស្រាយបញ្ហាចំពោះមុន ជាមួយម្ចាស់បំណុលជាដើម។ ករណីដែលតុលាការមិនអនុញ្ញាតឱ្យសហព័ទ្ធ ទទួលបានសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិទេនោះ ជាហេតុធ្វើឱ្យខូចប្រយោជន៍របស់សហព័ទ្ធ ក្នុងការដោះស្រាយជីវភាពប្រចាំថ្ងៃនឹងជះឥទ្ធិពលដល់គ្រួសារជាក់ជាមិនខាន។ ចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិ ត្រូវមានត្រឹមកម្រិតមួយដែលសហព័ទ្ធអាចធ្វើទៅបាន គឺបានន័យថាសហព័ទ្ធត្រូវប្រើប្រាស់ទ្រព្យសម្បត្តិ ក្នុងទំហំមួយដែលចាំបាច់ប្រើប្រាស់ប្រចាំថ្ងៃសម្រាប់គ្រួសារ។

ប្រសិនបើសហព័ទ្ធបានយកទ្រព្យនោះ ទៅប្រើប្រាស់សម្រាប់តែប្រយោជន៍ខ្លួនឯងនោះ សហព័ទ្ធ ត្រូវទទួលខុសត្រូវចំពោះការធ្វើឱ្យបាត់ប្រយោជន៍សម្រាប់គ្រួសារទាំងមូល។ បុគ្គលដែលអវត្តមាន ក៏មានសិទ្ធិទាមទារនូវទ្រព្យសម្បត្តិដែលសហព័ទ្ធខ្លួនយកទៅប្រើដើម្បីប្រយោជន៍ខ្លួនឯងក្រោយត្រលប់មកវិញ ឬបុគ្គលដែលអាចមានប្រយោជន៍ ក៏អាចទាមទារបានដែរ បើយល់ឃើញថាមានភាពចាំបាច់។

**ឧទាហរណ៍៖** លោក **ក** បានអវត្តមានពីផ្ទះ ហើយលោកស្រី **ខ** ទទួលសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិជំនួសលោក **ក** ដោយមានការប្រកាសពីតុលាការ ព្រោះលោក **ក** ពុំបានចាត់តាំងអ្នកគ្រប់គ្រងមុនពេលខ្លួនអវត្តមាន។ ដូចនេះតុលាការអាចធ្វើការប្រកាសឱ្យលោកស្រី **ខ** គ្រប់គ្រងទ្រព្យសម្បត្តិក្នុងគ្រួសារ ដោយហេតុថាកូនៗរបស់អ្នកទាំងពីរត្រូវការ ការចិញ្ចឹមបីបាច់ពីលោកស្រី **ខ**។ ចំពោះករណីនេះបើលោកស្រី **ខ** យកទ្រព្យទៅប្រើប្រាស់ដើម្បីដោះស្រាយជីវភាពគ្រួសារ នោះជាការត្រឹមត្រូវមួយ។ តែបើលោកស្រី **ខ** បានយកទ្រព្យទៅលេងល្បែង ហើយជំពាក់បំណុល គេនោះលោកស្រី **ខ** ត្រូវទទួលខុសត្រូវដោយខ្លួនឯង។ ហើយបើពេលដែលលោក **ក** វិលត្រឡប់មក

[12] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៣៧។

វិញ អាចទាមទារឲ្យលោកស្រី ខ សងនូវប្រាក់ដែលយកទៅលេងល្បែងបាន ព្រោះលោកស្រី ខ យកលុយទៅប្រើប្រាស់ដែលមិនបានបម្រើប្រយោជន៍ឱ្យគ្រួសារ គឺដើម្បីតែភាពសប្បាយរបស់ខ្លួន ប្រព្រឹត្តអំពើល្មើសច្បាប់និងបានធ្វើឱ្យខាតលុយផង។

### ១.២.៥. សិទ្ធិលើទ្រព្យសម្បត្តិរបស់សហព័ទ្ធ

ក្នុងនាមជាប្តីប្រពន្ធនឹងគ្នា គឺភាគីទាំងពីរមានសិទ្ធិក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិដែលខ្លួនមាន ក៏ដូចជាទ្រព្យសម្បត្តិរបស់សហព័ទ្ធខ្លួន ស្របទៅតាមបទប្បញ្ញត្តិច្បាប់ ដែលមានជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ដូចនេះប្រព័ន្ធទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធត្រូវបានក្រមរដ្ឋប្បវេណីបែងចែកជាពីរ ដើម្បីងាយស្រួលដោះស្រាយវិវាទក្នុងករណីដែលមានបណ្តឹងលែងលះកើតឡើង។ ប្រព័ន្ធទ្រព្យសម្បត្តិនោះមាន៖

- ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា(១.២.៥.១) និង
- ប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់(១.២.៥.២)។

#### ១.២.៥.១. ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា

ប្តីប្រពន្ធ អាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬក្រោយអាពាហ៍ពិពាហ៍[13] ដើម្បីបញ្ជាក់អំពីទំនាក់ទំនងនៃសិទ្ធិលើប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យារបស់ប្តីប្រពន្ធ ដោយមានការយល់ព្រមគ្នា មិនស្ថិតក្រោមការគាបសង្កត់ពីបុគ្គលណាមួយឡើយ។ ចំពោះការទៅចុះបញ្ជីប្រព័ន្ធទ្រព្យសម្បត្តិត្រូវស្ថិតក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌។[14] ប្តីប្រពន្ធ មានសិទ្ធិក្នុងការធ្វើកិច្ចសន្យាមុនពេលចាប់ផ្តើមអាពាហ៍ពិពាហ៍ក៏បាន ឬ អំឡុងពេលអាពាហ៍ពិពាហ៍ក៏បាន ហើយកិច្ចសន្យានោះអាចធ្វើការ កែប្រែពេលណាក៏បាន នេះជាសិទ្ធិរបស់សហព័ទ្ធ ក្នុងការសម្រេចចិត្តថាគួរកែប្រែ ឬ មិនកែប្រែ។ កាលដែលសហព័ទ្ធសម្រេចចិត្តក្នុងកែប្រែកិច្ចសន្យាទ្រព្យសម្បត្តិ ព្រោះទ្រព្យសម្បត្តិអាចមានការផ្លាស់ប្តូរទៅតាមស្ថានភាពជាក់ស្តែង។

ចំពោះការចុះកិច្ចសន្យាទ្រព្យសម្បត្តិ ចាំបាច់ត្រូវតែមានការចុះបញ្ជី និងធ្វើជាលាយល័ក្ខណ៍អក្សរ នៃកិច្ចសន្យាប្តីប្រពន្ធ ដោយផ្អែកតាមបទប្បញ្ញត្តិនៃមាត្រា ២៦ និង មាត្រា ២៨ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។ ប្រសិនបើការសន្យានោះមិនបានធ្វើជាលាយល័ក្ខណ៍អក្សរទេនោះ វានឹងមិនអាចយកមកធ្វើជាភស្តុតាងជាមូលដ្ឋានសម្រាប់ធ្វើការការតវ៉ាបានទេ។

[13] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៩៦៩។

[14] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខនស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១, មាត្រា ២៦ កថាខណ្ឌ១ (ចាប់ពីពេលនេះតទៅហៅថា ច្បាប់ស្តីពីការអនុវត្តក្រមឆ្នាំ២០១១)។

បើយោងតាមប្រសាសន៍របស់ឯកឧត្តម សួរ ចាន់ធី ដែលបានថ្លែង នាពេលធ្វើសន្និសីទ ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធជាលើកដំបូងថា៖

"ការផ្សព្វផ្សាយប្រកាសនេះគឺ ដើម្បីបង្ហាញអំពីទំនាក់ទំនង រវាងបុគ្គល និងបុគ្គល ដែលបានរៀបចំអាពាហ៍ពិពាហ៍ និងបុគ្គល ដែលត្រូវរៀបចំអាពាហ៍ពិពាហ៍ជាមួយគ្នា ដែលមាននូវធនធានទ្រព្យសម្បត្តិជាចលនវត្ថុក្តី ឬជាអចលនវត្ថុក្តី ដើម្បី បញ្ជាក់ឲ្យបានច្បាស់លាស់អំពីសិទ្ធិទៅលើទ្រព្យសម្បត្តិនោះថា តើធនធានទ្រព្យសម្បត្តិណា ខ្លះជារបស់រួម ហើយធនធានទ្រព្យសម្បត្តិ ណាខ្លះ ជាសិទ្ធិផ្តាច់មុខរបស់ភាគីណាមួយ ។

ការរៀបចំប្រកាសនេះឡើងគឺមានលក្ខណៈល្អ ដែលជាការវិវត្តន៍ មួយសម្រាប់ឲ្យប្រជាពលរដ្ឋអាចទទួលយកបាន ហើយរៀបចំនៅក្នុងក្រមរដ្ឋប្បវេណី សម្រាប់ផ្តល់ភាពងាយស្រួល ដល់ប្រជាពលរដ្ឋក្នុងការចុះបញ្ជី និងជួយការពារនូវទ្រព្យសម្បត្តិ ដែលគូភាគីបានរៀបការជាមួយគ្នា ព្រមទាំងបញ្ជាក់ឲ្យបានច្បាស់អំពីអ្វីដែលជាទ្រព្យសម្បត្តិរួម និង អ្វីដែលជាទ្រព្យសម្បត្តិដោយឡែកជាមួយគ្នា ដែលនីតិវិធីនេះធ្វើឡើងសម្រាប់ ការពារនៅពេលដែលគូភាគីទាំងពីរមានវិវាទកើតឡើង ដើម្បីងាយស្រួលក្នុងការដោះស្រាយតាមផ្លូវតុលាការ។

ប្រកាសទាក់ទងទៅនឹងនីតិវិធីចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធ គឺជាប្រកាសនីតិវិធីសម្រាប់គ្រប់គ្រងលើការចុះបញ្ជីកិច្ចសន្យា ទាំងឡាយណាដែលបង្កើតឡើង ដោយប្តីប្រពន្ធទាក់ទងនឹងទ្រព្យសម្បត្តិជាគោលការណ៍ប្រព័ន្ធទ្រព្យសម្បត្តិប្តីប្រពន្ធ តាមច្បាប់នៃប្រទេសកម្ពុជា គឺជាប្រព័ន្ធទ្រព្យសម្បត្តិរួម ដែលអនុញ្ញាតឲ្យប្តីប្រពន្ធមានកម្មសិទ្ធិរួមគ្នាលើកម្មសិទ្ធិទាំងអស់ ដែលពួកគាត់ទាំងពីរធ្វើលទ្ធកម្មនៅក្រោយពេលអាពាហ៍ពិពាហ៍។"[15]

❖ **អានុភាពនៃប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា៖**

- **អានុភាពចំពោះភាគីដែលជាសហព័ទ្ធ៖** នៅពេលដែលសហព័ទ្ធចុះកិច្ចសន្យា សរបញ្ជាក់ ឲ្យឃើញថាភាគីទាំងពីរ បានបែងចែកយ៉ាងជាក់លាក់នូវទ្រព្យសម្បត្តិរបស់ខ្លួន ថាទ្រព្យណាជាទ្រព្យរបស់ខ្លួន ហើយទ្រព្យណាជាទ្រព្យរបស់សហព័ទ្ធម្ខាងទៀត។ ហេតុដូចនេះ ភាគីណាម្ខាង មានសិទ្ធិលើទ្រព្យរបស់ខ្លួន តាមទំហំនៃកិច្ចសន្យា ដែលភាគីទាំងពីរបានកំណត់នៅក្នុងកិច្ចសន្យា។

**ឧទាហរណ៍៖** លោក **ក** បានយកទ្រព្យសម្បត្តិរបស់ខ្លួនទៅផឹកស៊ីសប្បាយ រហូតដល់ជំពាក់បំណុលលោក **គ**។ ដល់ថ្ងៃកំណត់សង លោក **គ** បានទៅទារលុយលោក **ក** តែលោក **ក** ពុំមាន

[15] អ៊ុន រិទ្ធី, "ផ្សព្វផ្សាយប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធជាលើកដំបូង," *AKP*, ២៤ កុម្ភៈ ២០១៤, http://www.akp.gov.kh/kh/archives/77159 (បានចូលទស្សនាចុងក្រោយ ២២ ខែមិថុនា ឆ្នាំ២០១៨)។

លុយសងទេ។ ក្នុងករណីនេះ លោកស្រី **ខ** ដែលជាប្រពន្ធលោក **ក** អាចធ្វើការសងបំណុលជំនួស ឬមិនសងក៏បាន ព្រោះបំណុលនោះជារបស់លោក **ក** ដោយហេតុថាអ្នកទាំងពីរបានចុះកិច្ចសន្យាទ្រព្យសម្បត្តិ។ ដូចនេះលោកស្រី **ខ** ពុំមានជំពាក់បំណុលលោក **គ** ទេ ហើយក៏មិនអាចរឹបអូសទ្រព្យសម្បត្តិ របស់លោកស្រី **ខ** ដែរ។

- **អានុភាពរបស់ភាគីចំពោះតតិយជន៖** ការចុះកិច្ចសន្យានេះមិនត្រឹមតែអាចបញ្ជាក់អំពីទ្រព្យសម្បត្តិរបស់សហព័ទ្ធនោះទេ គឺអាចទទួលបានប្រយោជន៍សម្រាប់ លក្ខខណ្ឌតតាំងជាមួយតតិយជនបាន។[16] ការចុះបញ្ជីទ្រព្យសម្បត្តិ ជាភស្តុតាងមួយសម្រាប់ភាគីទាំងសងខាង ធ្វើជាមូលដ្ឋានក្នុងការតវ៉ាជាមួយតតិយជន ឬ ភាគីពាក់ព័ន្ធនានា។

**ឧទាហរណ៍៖** លោក **ក** បានធ្វើជំនួញ ដែលមានម្ចាស់ភាគហ៊ុនច្រើននាក់ មិនយូរប៉ុន្មានជំនួញរបស់លោកបានខាតបង់ ហើយថែមទាំងជំពាក់បំណុលគេទៀត។ ដោយហេតុបំណុលលោក **ក** មានច្រើន ហេតុនេះលោក **ក** ត្រូវយកទ្រព្យសម្បត្តិរបស់ខ្លួន ដែលមានយកទៅសងគេ។ ក្នុងករណីនេះលោក **ក** អាចយកទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធទៅសងគេបាន តែចំពោះទ្រព្យផ្សេងទៀតរបស់ប្រពន្ធមិនអាចយកទៅសងទេ ព្រោះអ្នកទាំងពីរបានធ្វើការចុះកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធរួចហើយ។ ហើយប្រពន្ធលោក **ក** មានសិទ្ធិក្នុងការតតាំងជាមួយម្ចាស់បំណុលបាន បើសិនជាមានករណីចាំបាច់ដែលមានការទាមទារពីម្ចាស់បំណុល។

### ១.២.៥.២. ប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់

**ប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់** គឺមានលក្ខណៈខុសពីប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យាត្រង់ថា សហព័ទ្ធមិនបានរៀបចំកិច្ចសន្យាទ្រព្យសម្បត្តិ ឬមិនបានទៅចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិនៅក្រសួងយុត្តិធម៌នោះទេ ដែលជាហេតុនាំឲ្យមានការកំណត់ប្រព័ន្ធទ្រព្យសម្បត្តិដោយច្បាប់។ ប្តីប្រពន្ធ ត្រូវមានចំណែកបន្ទុកលើសោហ៊ុយដែលកើតចេញពីអាពាហ៍ពិពាហ៍ដោយពិចារណាទៅលើទ្រព្យសម្បត្តិ ប្រាក់ចំណូល និងស្ថានភាពផ្សេងៗទៀត។[17] ចំពោះប្រព័ន្ធទ្រព្យសម្បត្តិតាមច្បាប់ គឺបែងចែកជាពីរស្របទៅតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដោយមានទ្រព្យសម្បត្តិដោយឡែក(ក) និងទ្រព្យសម្បត្តិរួម(ខ)។

### ក. ទ្រព្យសម្បត្តិដោយឡែក

ទ្រព្យសម្បត្តិដោយឡែក ជាទ្រព្យដែលសហព័ទ្ធម្ខាងមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍

[16] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៩៧០។

[17] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៩៧១។

និងបានទទួលដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍។[18]

យោងទៅតាមមាត្រា ៩៧២ នៃក្រមរដ្ឋប្បវេណីបានចែងពី ទ្រព្យសម្បត្តិដោយឡែកដែលស្ថិតក្រោមកម្មសិទ្ធិរបស់សហព័ទ្ធណាម្នាក់ដូចខាងក្រោម៖

- ទ្រព្យសម្បត្តិ ដែលសហព័ទ្ធមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍។

**ឧទាហរណ៍៖** លោក **ក** បានទិញផ្ទះល្វែងនៅមុនពេលរៀបអាពាហ៍ពិពាហ៍ ដូចនេះទ្រព្យសម្បត្តិរបស់លោក **ក** ជាទ្រព្យដោយឡែកនៅពេលដែលលោករៀបអាពាហ៍ពិពាហ៍។

- ទ្រព្យសម្បត្តិ ដែលសហព័ទ្ធទទួលបាន ដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍។
  - ប្រទានកម្ម សំដៅលើកិច្ចសន្យាមួយ ដែលត្រូវមានអានុភាព ដោយភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ឲ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិ ដោយមិនយកថ្លៃ ហើយភាគីម្ខាងទៀតយល់ព្រម ទទួល។[19]

**ឧទាហរណ៍៖** ឪពុកម្តាយលោក **ក** បានឱ្យរថយន្តមួយគ្រឿងទៅលោក **ក** នៅក្នុងអំឡុងពេលដែលលោកបានរៀបអាពាហ៍ពិពាហ៍។

  - សន្តតិកម្ម គឺជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឲ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់។ [20]

**ឧទាហរណ៍៖** លោក **ក** ទទួលបានផ្ទះល្វែង និងដីមួយកន្លែងបន្ទាប់ពីឪពុកលោក **ក** បានទទួលមរណភាព តាមរយៈបណ្តាំមតកសាសន៍។

  - អច្ច័យទាន ជាប្រភេទប្រទានកម្ម ដែលម្ចាស់បណ្តាំធ្វើឱ្យមនុស្សម្នាក់ ឬ ច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈមតកសាសន៍។[21]

**ឧទាហរណ៍៖** លោក **ក** បានទទួលដីមួយហិចតាពីបងស្រីរបស់ខ្លួនតាមរយៈបណ្តាំរបស់បងស្រី មុនពេលគាត់ទទួលមរណភាព។

➢ **ការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិដោយឡែក**

ទ្រព្យសម្បត្តិដោយឡែក គឺមិនអនុញ្ញាតឲ្យសហព័ទ្ធណាម្ខាងមានសិទ្ធិ ក្នុងការចាត់ចែងលើទ្រព្យសម្បត្តិនោះបានឡើយ បើគ្មានការអនុញ្ញាតពីសហព័ទ្ធណាម្ខាង ដោយហេតុថាទ្រព្យនោះជា

[18] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ៨។
[19] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៥៦៩។
[20] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ២១។
[21] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ២៦។

ទ្រព្យរបស់ប្រពន្ធ ឬប្តីតែម្ខាង។ ក៏ប៉ុន្តែ សហព័ទ្ធអាចទទួលបានសិទ្ធិមួយចំនួនចំពោះទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធខ្លួន ដែលក្នុងនោះមាន សិទ្ធិអាស្រ័យនៅ សិទ្ធិប្រើប្រាស់ និងអាស្រ័យផល។

**សិទ្ធិអាស្រ័យនៅ៖** សហព័ទ្ធម្ខាងអាចអាស្រ័យនៅលើអចលនវត្ថុ ដែលជាទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធម្ខាងទៀត ហើយត្រូវបានប្រើសម្រាប់ការអាស្រ័យនៅរបស់គ្រួសារបាន។[22] ប្រពន្ធ ឬ ប្តី គឺមានសិទ្ធិរស់នៅលើអចលនវត្ថុរបស់សហព័ទ្ធម្ខាងទៀតបាន។

បើទោះជាក្នុងករណីដែលសហព័ទ្ធម្ខាង ដែលជាកម្មសិទ្ធិករនៃអចលនវត្ថុបានចាត់ចែងអចលនវត្ថុនោះ ក៏សហព័ទ្ធម្ខាងទៀតអាចនៅបន្តអាស្រ័យនៅលើអលចនវត្ថុនោះបានដែរ ឬមានន័យថា បើទោះបីការលក់ដូរនោះបានផ្ទេរកម្មសិទ្ធិទៅឲ្យអ្នកទិញក៏ដោយ ក៏អ្នកទិញមិនអាចអះអាងពីសិទ្ធិជាកម្មសិទ្ធិករ ហើយបណ្តេញសហព័ទ្ធដែលអាស្រ័យនៅលើអចនវត្ថុនោះបានឡើយ។[23]

**ឧទាហរណ៍៖** លោក **ក** និងលោកស្រី **ខ** បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ហើយលោក **ក** បានមករស់នៅ ផ្ទះរបស់លោកស្រី **ខ** ក្រោយរៀបការជាមួយគ្នា ដែលផ្ទះនោះជាទ្រព្យសម្បត្តិដោយឡែករបស់លោកស្រី **ខ**។

**សិទ្ធិប្រើប្រាស់ និងអាស្រ័យផល៖** ប្តីប្រពន្ធមានសិទ្ធិប្រើប្រាស់ អាស្រ័យផលក្នុងទំហំដែលអាចធ្វើបាន។ ក្នុងករណីដែលប្រពន្ធពុំមានលទ្ធភាពក្នុងការធ្វើការងារក្រៅ នោះប្រពន្ធមានសិទ្ធិធ្វើការងារ គេហកិច្ច ដែលការងារនេះ ត្រូវបានចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះដែរ។[24] ក្នុងនោះប្រពន្ធមានសិទ្ធិក្នុងការប្រើប្រាស់ អាស្រ័យផលលើទ្រព្យសម្បត្តិរួមបាន។ ទោះបីជាទ្រព្យសម្បត្តិរបស់សហព័ទ្ធ ជាទ្រព្យដោយឡែកក៏ដោយ ក៏សហព័ទ្ធម្ខាងអាចយកមកប្រើប្រាស់ក្នុងទំហំដែលចាំបាច់បានដែរ។

**ឧទាហរណ៍៖** លោក **ក** និងលោកស្រី **ខ** ជាសហព័ទ្ធហ្នឹងគ្នា ដោយមុនរៀបអាពាហ៍ពិពាហ៍ លោក **ក** បានទិញឡានមួយ ហេតុដូចនេះឡាននោះជាទ្រព្យសម្បត្តិដោយឡែករបស់លោក **ក**។ ក្រោយរៀបការហើយ លោកស្រី **ខ** អាចមានសិទ្ធិប្រើប្រាស់ឡានរបស់លោក **ក** បាន ដោយមានការអនុញ្ញាតពីលោក **ក**។

[22] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៧៧ កថាខណ្ឌ១។

[23] បាន លក្ខិណា និងរ៉ាត់ រ៉ាទី, "ទំនាក់ទំនងទ្រព្យសម្បត្តិនៃសហព័ទ្ធ និងអនីតិសង្វាស," (សារណាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៧), ទំព័រ ២៦។

[24] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៩៨០ កថាខណ្ឌ៣។

## ខ. ទ្រព្យសម្បត្តិរួម

ទ្រព្យសម្បត្តិរួម ជាទ្រព្យសម្បត្តិទាំងឡាយ ដែលប្តីប្រពន្ធទាំងសងខាង ឬតែម្ខាងទទួលបាន នៅក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដោយឡែក។[25] កាលបើប្តី ឬ ប្រពន្ធបានរកប្រាក់ចំណូលអំឡុងពេលអាពាហ៍ពិពាហ៍ ត្រូវបានចាត់ទុកជាទ្រព្យសម្បត្តិរួមរបស់អ្នកទាំងពីរ។

**ឧទាហរណ៍៖** លោក **ក** និងលោកស្រី **ខ** បានទទួលប្រាក់ឈ្នួលពីការជួលផ្ទះរបស់ពួកគាត់ ដោយផ្ទះនោះ ជាទ្រព្យដែលពួកគាត់បានទិញរួមគ្នា។

- **ការគ្រប់គ្រង និងប្រើប្រាស់ទ្រព្យសម្បត្តិរួម**

ប្តីប្រពន្ធ មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ ចំពោះទ្រព្យសម្បត្តិរួម។

**ឧទាហរណ៍៖** លោក **ក** និងលោកស្រី **ខ** បានទទួលប្រាក់ឈ្នួលពីការជួលផ្ទះ របស់ពួកគាត់។ ដូចនេះលុយដែលបានមកពីការជួលផ្ទះ គឺជាទ្រព្យរបស់អ្នកទាំងពីរ ហើយអ្នកទាំងពីរមានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់លុយនោះ។

សហព័ទ្ធមានសិទ្ធិប្រើប្រាស់ទ្រព្យសម្បត្តិរួម នៅក្នុងទំហំដែលចាំបាច់ ដោយផ្អែកលើការចាំបាច់នៅក្នុងជីវភាព។ ប្តី ឬប្រពន្ធមានសិទ្ធិគ្រប់គ្រាន់ក្នុងការប្រើប្រាស់ទ្រព្យដែលចាំបាច់ក្នុងជីវភាព ដូចជាការទិញម្ហូបសម្រាប់បរិភោគប្រចាំថ្ងៃ ការចំណាយនានាដែលត្រូវតែប្រើប្រាស់ប្រចាំថ្ងៃដែលមិនអាចខ្វះបាន។ ចំពោះសហព័ទ្ធ ដែលជាកម្មសិទ្ធិករអាចប្រើប្រាស់នូវទ្រព្យទៅតាមធម្មជាតិរបស់វា ដូចជាអាចរស់នៅក្នុងផ្ទះរបស់គាត់ ឬ ដាំដំណាំផ្សេងៗនៅលើដីកម្មសិទ្ធិរបស់គាត់បាន។[26]

**ឧទាហរណ៍៖** លោកស្រី **ខ** បានយកលុយទៅបង់ថ្លៃផ្ទះ និងទិញម្ហូប ដោយមិនចាំបាច់សុំការអនុញ្ញាតពីប្តី បើទោះបីទ្រព្យនោះជាទ្រព្យរួមក៏ដោយ ពីព្រោះសកម្មភាពនេះជាការចំណាយសម្រាប់ទ្រទ្រង់ជីវភាពក្នុងគ្រួសារ។

សហព័ទ្ធត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរួមដោយសហការគ្នា មានន័យថាសហព័ទ្ធត្រូវតែមានការយល់ស្រប និងព្រមព្រៀងគ្នាចំពោះការគ្រប់គ្រងទ្រព្យរួមនោះ។

[25] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, សន្ទានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ៨។

[26] ញឹក វុធ្វី, *មេរៀននីតិវិធីរដ្ឋប្បវេណី*, (ភ្នំពេញ), ៤៦។

**ឧទាហរណ៍៖** លោក **ក** មានបំណងចង់ទិញផ្ទះល្វែងមួយខ្នង ហេតុដូចនេះលោក **ក** ត្រូវមានការពិភាក្សា និងយល់ព្រមពីប្រពន្ធរបស់គាត់ជាមុនសិន ព្រោះលុយដែលត្រូវទិញផ្ទះនោះជាទ្រព្យរួមរបស់អ្នកទាំងពីរ។

➢ **ការចាត់ចែងទ្រព្យសម្បត្តិរួម**

ប្តីប្រពន្ធត្រូវចូលរួមគ្នាចាត់ចែងទ្រព្យសម្បត្តិដោយសហការគ្នា ក្នុងករណីគ្មានការយល់ព្រមពីប្តី ប្រពន្ធទាំងសងខាងទេ នោះទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធមិនអាចយកទៅលក់បានទេ ឬធ្វើការចាត់ចែងផ្សេងទៀតបានឡើយ។[27]

**ឧទាហរណ៍៖** លោក **ក** បានទិញផ្ទះមួយកន្លែងនៅភ្នំពេញជាមួយប្រពន្ធរបស់គាត់ គឺលោកស្រី **ខ** កាលពីឆ្នាំ២០០២។ នៅឆ្នាំ១០១៧ លោកស្រី **ខ** មានបំណងលក់ផ្ទះនោះ ហើយលោកស្រីត្រូវទទួលការយល់ព្រមជាមួយលោក **ក** ព្រោះផ្ទះនោះជាទ្រព្យសម្បត្តិរួមរបស់អ្នកទាំងពីរ ហេតុដូចនេះអ្នកទាំងពីរត្រូវចាត់ចែងរួមគ្នា បើលោក **ក** មិនយល់ស្របទេ នោះផ្ទះនោះមិនអាចលក់បានទេ ។

ប្រសិនបើមានស្ថានភាពមួយ មិនអាចជៀសវាងបានដោយសារតែភាពចាំបាច់ដែលត្រូវតែចាត់ចែង ទ្រព្យសម្បត្តិរួមនោះ សហព័ទ្ធអាចធ្វើការចាត់ចែងដោយមិនបាច់មានការអនុញ្ញាតពីសហព័ទ្ធម្ខាងទៀតបាន តែចាំបាច់ត្រូវទទួលបានការអនុញ្ញាតពីតុលាការ។

**ឧទាហរណ៍៖** លោកស្រី **ខ** មានបំណងចង់លក់រថយន្តម៉ាកកាំមេរី របស់ខ្លួន ដោយសារតែលោកស្រី **ខ** ត្រូវការលុយចាំបាច់ដើម្បីបង់ថ្លៃសិក្សាឲ្យកូនព្រោះដល់ថ្ងៃកំណត់ និងត្រូវផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារជាចាំបាច់។ ហេតុដូចនេះលោកស្រី **ខ** អាចស្នើសុំទៅតុលាការដើម្បីទទួលបានការអនុញ្ញាតពីតុលាការដើម្បីធ្វើការលក់រថយន្តនោះបាន។

## ១.៣. កាតព្វកិច្ចសហព័ទ្ធអំឡុងពេលអាពាហ៍ពិពាហ៍

ក្រោយពីរៀបអាពាហ៍ពិពាហ៍របស់បុរសនារី រួចមកឃើញថាអ្នកទាំងពីរ បានក្លាយទៅជាសហព័ទ្ធនឹងគ្នា ក្នុងនាមជាសហព័ទ្ធចាំបាច់ត្រូវបង្កើតគ្រួសារមួយឱ្យល្អនោះ សហព័ទ្ធត្រូវមានកាតព្វកិច្ចគោរពស្រឡាញ់គ្នាទៅវិញទៅមក ដើម្បីឱ្យគ្រួសារទទួលបានសុភមង្គល ក្នុងនោះដែលឃើញថា សហព័ទ្ធក៏ត្រូវឆ្លងកាត់នូវកាតព្វកិច្ចជាច្រើនទៀតដែរ។

[27] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៩៧៦ កថាខណ្ឌ១។

### ១.៣.១. ភាតព្វកិច្ចសាមគ្គី

ប្ដីប្រពន្ធ ត្រូវទទួលខុសត្រូវដោយសាមគ្គី ចំពោះកាតព្វកិច្ចដែលកំណត់ខាងក្រោមនេះ៖[28]

- សោហ៊ុយដើម្បីរក្សាជីវភាពរួមរបស់ប្ដីប្រពន្ធ និងសោហ៊ុយដើម្បីការអប់រំ ឬការព្យាបាល ថែទាំកូនជាអាទិ៍។ ប្ដីប្រពន្ធ ចាំបាច់ត្រូវមានកាតព្វកិច្ចក្នុង ការប្រើប្រាស់លុយរួមគ្នា ដើម្បីដោះស្រាយជីវភាពក្នុងគ្រួសារ និងការចំណាយលុយដើម្បីថែរក្សាកូន។

**ឧទាហរណ៍៖** លោក **ក** បានរៀបអាពាហ៍ពិពាហ៍ជាមួយលោកស្រី **ខ** កាលពីឆ្នាំ ២០១៥ ហើយឆ្នាំ២០១៧ អ្នកទាំងពីរបានធ្វើកម្ចីលុយពីធានាគារ ដើម្បីធ្វើអាជីវកម្ម ដូចនេះអ្នកទាំងពីរមានកាតព្វកិច្ចត្រូវធ្វើការសងប្រាក់ ធានាគាររួមគ្នាដោយហេតុថាអ្នកទាំងពីរបានទៅខ្ចីលុយជាមួយគ្នាក្នុងគោលបំណងដើម្បីពង្រឹងអាជីវកម្មរបស់ខ្លួន។

- សោហ៊ុយដើម្បីគ្រប់គ្រង និងរក្សាទ្រព្យសម្បត្តិរួម។

**ឧទាហរណ៍៖** លោក **ក** បានហៅជាងមកជួសជុលក្នុងផ្ទះ ដោយប្រើប្រាស់ទ្រព្យសម្បត្តិរួមអស់ទៅដល់ ៥០$។

- កាតព្វកិច្ច និងករណីយកិច្ចផ្សេងៗទៀត ដែលប្ដី ឬប្រពន្ធទាំងសងខាងបានព្រមព្រៀងតាមលិខិតជាលាយល័ក្ខណ៍អក្សរ ជាមួយម្ចាស់បំណុល នៅអំឡុងពេលអាពាហ៍ពិពាហ៍ ឬ កាតព្វកិច្ច និងករណីយកិច្ចផ្សេងៗទៀត ដែលប្ដី ឬប្រពន្ធណាម្ខាងបានទទួលបន្ទុក ដោយមានការយល់ព្រមតាមលិខិតជាលាយល័ក្ខណ៍អក្សរ ពីប្រពន្ធ ឬ ប្ដីម្ខាងទៀត នៅអំឡុងពេលអាពាហ៍ពិពាហ៍។

**ឧទាហរណ៍៖** លោក **ក** និងលោកស្រី **ខ** ជាប្ដីប្រពន្ធនឹងគ្នា ហើយអ្នកទាំងពីរបានទិញផ្ទះបង់ រំលស់ដោយមានការចុះកិច្ចសន្យា(លាយល័ក្ខណ៍អក្សរ) ទាំងពីរអ្នកប្ដីប្រពន្ធ ដូចនេះអ្នកទាំងពីរត្រូវ មានកាតព្វកិច្ចបង់រំលស់ផ្ទះនោះទាំងពីរអ្នក។

### ១.៣.២. ភាតព្វកិច្ចជួយសង្គ្រោះ

បុរសនារីក្លាយជាសហព័ទ្ធនឹងគ្នាហើយនោះ គឺពួកគេចាំបាច់ណាស់ត្រូវ រួមរស់ជីវភាពជាមួយគ្នា ហើយក៏ត្រូវសហការ សង្គ្រោះគ្នាទៅវិញទៅមកផងដែរ។[29] ហេតុដូចនេះក្នុងនាមខ្លួនជាសហព័ទ្ធនឹងគ្នា ចាំបាច់ណាស់ត្រូវចេះជួយគ្នាទៅវិញទៅមក ទោះក្នុងកាលៈទេសៈណាក៏ដោយ ដើម្បីឱ្យគ្រួសារមួយប្រកបទៅដោយសុភមង្គល និងមានការសាមគ្គីគ្នាផងដែរ។

[28] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៩៧៥។

[29] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៦៦។

### ១.៣.៣. បន្ទុកសោហ៊ុយអាពាហ៍ពិពាហ៍

ប្តីប្រពន្ធ ត្រូវមានចំណែកលើសោហ៊ុយដែលកើតចេញពីអាពាហ៍ពិពាហ៍ ដោយពិចារណាទៅលើទ្រព្យសម្បត្តិ ប្រាក់ចំណូល និងស្ថានភាពផ្សេងៗ។[30] បន្ទុកនៃសោយហ៊ុយដើម្បីថែទាំជីវភាពរួមនៃអាពាហ៍ពិពាហ៍ ដោយតម្រូវឲ្យប្តីប្រពន្ធចែករំលែកសោហ៊ុយទៅតាមទ្រព្យសម្បត្តិ ប្រាក់ចំណូល ឋានៈក្នុងសង្គម និងមុខរបររបស់ពួកគេ។ សោហ៊ុយអាពាហ៍ពិពាហ៍ទាំងនោះ មិនសំដៅលើត្រឹមតែសោហ៊ុយចាំបាច់ដែលចំណាយលើការស្លៀកពាក់ ម្ហូបអាហារ និងការស្នាក់នៅប៉ុណ្ណោះទេ តែរាប់បញ្ចូលទាំងសោហ៊ុយលើថ្លៃព្យាបាល ការសិក្សា និងថែទាំកូនផងដែរ។[31]

### ១.៣.៤. ភាតព្វកិច្ចសហព័ទ្ធចំពោះកូន

ក្នុងនាមជាឪពុកម្តាយ ដែលបានផ្តល់កំណើតឱ្យកូន លោកទាំងពីរចាំបាច់ណាស់ ត្រូវជាប់នូវកាតព្វកិច្ចចិញ្ចឹមបីបាច់កូនឱ្យបានល្អ។ ប្រសិនបើឪពុកម្តាយខ្វះនូវការយកចិត្តទុកដាក់អប់រំចិញ្ចឹមបីបាច់កូន នោះគេនឹងមិនអាចក្លាយជាបុគ្គលល្អក្នុងសង្គមជាតិឡើយ ដោយហេតុថាកូនខ្វះនូវភាពកក់ក្តៅ ការអប់រំ ការយកចិត្តទុកដាក់ពីឪពុកម្តាយ។ ហេតុនេះការមើលថែកូនពិតជាមានសារៈសំខាន់ណាស់សម្រាប់ក្រុមគ្រួសារ ក៏ដូចជាសង្គមជាតិ។

យ៉ាងណាមិញ ឪពុកម្តាយមានកាតព្វកិច្ចត្រូវតែទៅចុះសំបុត្រកំណើតឱ្យកូនបន្ទាប់ពី បានផ្តល់កំណើតឱ្យកូន ដែលមានរយៈពេល ៣០ថ្ងៃ បន្ទាប់ពីកូននោះបានកើត ដែលការចុះសំបុត្រកំណើតនោះ ត្រូវធ្វើនៅសាលាឃុំ ឬសង្កាត់ ដែលលំនៅដ្ឋាន របស់ឪពុក-ម្តាយស្ថិតនៅ។ កាលបើកូនមានអាយុត្រឹម ៦ឆ្នាំ ឬយ៉ាងទាបបំផុត៧០ខែឡើងទៅ ត្រូវនាំគេទៅចុះឈ្មោះចូលរៀនថ្នាក់ទី១នៃកម្មវិធីអប់រំចំណេះទូទៅនៅសាលារៀនណា ដែលមានអាជ្ញាប័ណ្ណអប់រំ។[32]

ឪពុកម្តាយមិនត្រឹមតែនាំកូនទៅរៀននោះទេ តែលោកទាំងពីរចាំបាច់ណាស់ត្រូវតែខិតខំឱ្យអស់ពីលទ្ធភាព ដើម្បីគាំទ្រការសិក្សារបស់កូន ហើយមិនត្រូវព្រងើយកន្តើយចំពោះការសិក្សារបស់កូនឡើយ។ នៅក្នុងវ័យកុមារ កូនគឺត្រូវការលើកទឹកចិត្តពីឪពុកម្តាយ ដើម្បីទទួលបានលទ្ធផលល្អក្នុងការសិក្សា។

### ១.៣.៥. ភាតព្វកិច្ចចំពោះបំណុល

បំណុលអាចកើតមានក្នុងរូបភាពពីរនៅក្នុងនីតិគ្រួសារ គឺកាតព្វកិច្ចចំពោះបំណុលគ្រួសារ និងកាតព្វកិច្ចចំពោះបំណុលផ្ទាល់ខ្លួន។

---

[30] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៧១។

[31] ក្រសួងយុត្តិធម៌, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ៥៖៣១។

[32] ច្បាប់អប់រំ, លេខនស/រកម/១២០៧/០៣២, ១៩ ធ្នូ ២០០៧, មាត្រា៣៦ កថាខណ្ឌ ២។

**កាតព្វកិច្ចចំពោះបំណុលគ្រួសារ** សំដៅលើបំណុលគ្រួសារ ដែលជាការបង្កើតនូវកាតព្វកិច្ចមួយដែលកើតឡើងដោយសារតែបំពេញតម្រូវការសម្រាប់ជីវភាពគ្រួសារ។ ដូចនេះការខ្ចីបំណុលដែលកើតឡើងដោយសារតែសហព័ទ្ធណាម្ខាង ឬ ទាំងសងខាង ដើម្បីមកបម្រើប្រយោជន៍ក្នុងគ្រួសារ នោះជាបំណុលគ្រួសារ។

**ឧទាហរណ៍៖** លោកស្រី **ខ** បានជំពាក់លុយអ្នកលក់គ្រឿងទេសចំនួន ២០០ដុល្លារ($) ដោយសារតែលោកស្រីទិញគ្រឿងទេសមកធ្វើម្ហូបនៅក្នុងផ្ទះ។

**កាតព្វកិច្ចចំពោះបំណុលផ្ទាល់ខ្លួន** មានលក្ខណៈផ្ទុយពីបំណុលគ្រួសារ ជាការបង្កើតនូវកាតព្វកិច្ចមួយដែល កើតឡើងដោយសារតែបំពេញតម្រូវការខ្លួនឯង។ ដូចនេះការខ្ចីបំណុល ដែលកើតចេញពីសហព័ទ្ធតែម្ខាង ដើម្បីបម្រើប្រយោជន៍ខ្លួនឯង មិនបានចាត់ចូលជាបំណុលគ្រួសារទេ។ ហើយកាតព្វកិច្ចនេះសហព័ទ្ធតែម្ខាងដែលបានជំពាក់បំណុលត្រូវមានកាតព្វកិច្ចសងនូវបំណុលនោះ ហើយសហព័ទ្ធម្ខាងទៀតក៏អាចជួយសងជំនួសបានប្រសិនបើមានលទ្ធភាព។

**ឧទាហរណ៍៖** លោក **ក** បានខ្ចីលុយគេចំនួន ៥០០$ យកទៅឲ្យនារីកំណាន់របស់ខ្លួន។ ការខ្ចីលុយរបស់លោក **ក** គឺសម្រាប់ជាប្រយោជន៍ខ្លួនឯង ដែលមិនមែនខ្ចីយកមកប្រើប្រាស់ក្នុងការរក្សាជីវភាពក្នុងគ្រួសារនោះទេ។

# ជំពូកទី ២. ទំនាក់ទំនងសហព័ទ្ធក្រោយបញ្ចប់ចំណងអាពាហ៍ពិពាហ៍

ថ្វីបើទំនាក់ទំនងនៃសិទ្ធិ និងកាតព្វកិច្ចមួយចំនួនត្រូវបានបញ្ចប់ក្រោយការរលត់នៃចំណងអាពាហ៍ពិពាហ៍ក្ដី ក៏នៅមានចំណុចគតិយុត្តមួយចំនួនទៀត ដែលនៅតែបន្តសម្រាប់ទំនាក់ទំនងសហព័ទ្ធ។ មូលហេតុនៃការបញ្ចប់ត្រូវបានស្ដែងឡើងតាមរយៈ ការលែងលះ ការបាត់ខ្លួន ឬមរណភាព របស់សហព័ទ្ធណាម្ខាងជាដើម។

## ២.១. អំពីការលែងលះ

ការលែងលះ គឺជាមូលហេតុមួយនៃការឈានទៅរកការបញ្ចប់ចំណងអាពាហ៍ពិពាហ៍របស់សហព័ទ្ធ។ លក្ខខណ្ឌ និងអានុភាពនៃការលែងលះ និងឆ្លុះបញ្ចាំងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនីមួយៗដែលមាន និងត្រូវបំពេញក្រោយការលែងលះ។

### ២.១.១. សញ្ញាណនៃការលែងលះ និង ការបញ្ចប់ប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិ

ចំណុចសង្ខេបស្ដីពីសញ្ញាណនៃការលែងលះ និងការបញ្ចប់ប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិនឹងត្រូវបានលើកមកបង្ហាញតាមចំណុចនីមួយៗខាងក្រោម៖

#### ២.១.១.១. សញ្ញាណនៃការលែងលះ

ចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ សំដៅដល់ទម្រង់នៃការចុះសំបុត្រអាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រីដោយផ្អែកតាមគោលការណ៍កំណត់ជាមូលដ្ឋានរបស់ច្បាប់។ ការបញ្ចប់ចំណងអាពាហ៍ពិពាហ៍អាចធ្វើទៅបាន ក៏អាស្រ័យដោយភាគីពាក់ព័ន្ធគោរពតាមគោលការណ៍ច្បាប់ជាធរមាន។ តួយ៉ាងតាមរយៈការអនុវត្ត និងគោរពតាម លិខិតបទដ្ឋានគតិយុត្ត សាលក្រម សាលដីកាសម្រេចរបស់តុលាការ ដោយសារការប្រកាសអំពីការបាត់ខ្លួន ឬដោយសារមរណភាពរបស់ភាគីណាម្នាក់ជាដើម។ ការលែងលះ សំដៅដល់ការផ្ដាច់ចំណងអាពាហ៍ពិពាហ៍រវាងប្ដី និងប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ ដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍បានត្រឹមត្រូវ នៅចំពោះមុខក្រុមប្រឹក្សាឃុំ-សង្កាត់ និងគោរពតាមលក្ខខណ្ឌច្បាប់ត្រឹមត្រូវ។[33] ការលែងលះតាមផ្លូវច្បាប់នេះទៀតសោត ក៏សំដៅដល់ការបញ្ចប់ចំណងនីតិសង្វាសរវាងសហព័ទ្ធជាស្ថាពរផងដែរ។

#### ២.១.១.២. សញ្ញាណនៃការបញ្ចប់ប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិ

ជាគោលការណ៍ក្រោយពេលលែងលះរួចហើយ សហព័ទ្ធត្រូវតែបញ្ចប់នូវដំណើរនៃចំណងអាពាហ៍ពិពាហ៍ ហើយអ្វីដែលពួកគេត្រូវធ្វើបន្ទាប់នោះ គឺសហការគ្នាធ្វើការចាត់ចែង និងបែងចែកទ្រព្យសម្បត្តិ និងកូនៗ(ករណីបើមាន)។ ក្នុងករណីដែលសហព័ទ្ធបានធ្វើការចុះបញ្ជីនៃកិច្ចសន្យា

[33] ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ក្រ, ១៧ កក្កដា ១៩៨៩, មាត្រា៣៨។

ទ្រព្យសម្បត្តិប្តីប្រពន្ធតាមលក្ខខណ្ឌច្បាប់ហើយនោះ ការបែងចែកទ្រព្យសម្បត្តិរបស់ពួកគេនឹងត្រូវអនុលោមតាមខ្លឹមសារដូចដែលបានចែងក្នុងកិច្ចសន្យានោះ។ ផ្ទុយមកវិញបើពុំមានការព្រមព្រៀងគ្នា រវាង សហព័ទ្ធ ឬការបែងចែកត្រឹមត្រូវផ្អែកតាមគោលការណ៍សមធម៌ទេ នោះគោលការណ៍ច្បាប់ជាពិសេសតាមរយៈយុត្តាធិការរបស់តុលាការ នឹងចូលមកអន្តរាគមន៍ម្តង។ ការបែងចែកនេះពិត ជាមានសារៈសំខាន់ណាស់ ក្នុងការផ្តាច់នូវទំនាក់ទំនងនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រវាងសហព័ទ្ធនីមួយៗ។

### ២.១.២. មូលហេតុនៃការលែងលះ និង ការបញ្ចប់ប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិ

ជាការពិតណាស់ ប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ បានកើតឡើងដោយផ្តើមចេញ និងផ្សាភ្ជាប់ដោយចំណងអាពាហ៍ពិពាហ៍ស្របតាមច្បាប់មួយ។ ចាប់តាំងពីការកកើតនៃចំណងអាពាហ៍ពិពាហ៍នេះ សិទ្ធិ និងកាតព្វកិច្ចរបស់សហព័ទ្ធទាំងសងខាងក្នុងការគ្រប់គ្រងចាត់ចែង និង ថែរក្សា នូវទ្រព្យសម្បត្តិរបស់ពួកគេក្នុងកំឡុងពេលអាពាហ៍ពិពាហ៍ ស្របតាមគោលការណ៍សុចរិតភាព និង ដោយភាពស្មោះត្រង់ផ្អែកតាមឆន្ទៈរបស់បុគ្គល។ យ៉ាងណាមិញ ភាគីទាំងពីរក៏អាចធ្វើការដាក់ពាក្យបណ្តឹងលែងលះទៅតុលាការបានផងដែរ ក្នុងករណីដែលភាគីទាំងសងខាង មានការព្រមព្រៀងគ្នាក្នុងការលែងលះ ដោយមានបំណងពិតប្រាកដក្នុងការរំលាយអាពាហ៍ពិពាហ៍។[34] បន្ថែមពីលើនេះទៀតមូលហេតុសំខាន់ៗមួយចំនួន ដែលជាមូលហេតុឈានទៅដល់ការលែងលះ ជាអាទិ៍ការបាត់ខ្លួនមរណភាពរបស់សហព័ទ្ធក្នុង ចំណងអាពាហ៍ពិពាហ៍ជា ដើម។[35]

### ២.១.៣. លក្ខខណ្ឌនៃការលែងលះ

ការលែងលះអាចប្រព្រឹត្តទៅបានអាស្រ័យដោយគូភាគី បានព្រមព្រៀងគ្នា ឬភាគីណាម្នាក់បានធ្វើឲ្យមានកំហុសតាមលក្ខខណ្ឌដែលច្បាប់កំណត់ ដែលជាហេតុនាំឲ្យអាពាហ៍ពិពាហ៍មិនអាចធ្វើបដិទានឡើងវិញបាន។

#### ២.១.៣.១. លក្ខខណ្ឌតាមច្បាប់

ចំណងអាពាហ៍ពិពាហ៍ដែលកើតឡើងតាមរយៈឆន្ទៈរបស់គូភាគី(បុរស ស្ត្រី) ព្រមព្រៀងគ្នាក្នុងនោះការលែងលះក៏ផ្តើមចេញពីឆន្ទៈរបស់គូភាគីផងដែរ ពោលគឺឆន្ទៈដែលគូភាគីមិនចង់រស់នៅជាមួយគ្នា និងមានឆន្ទៈបញ្ចប់ចំណងអាពាហ៍ពិពាហ៍របស់ពួកគេ។ ការលែងលះប្រព្រឹត្តទៅក្នុងរូបភាពពីរយ៉ាងគឺ ការដាក់ពាក្យបណ្តឹងសុំលែងលះ និងការលែងលះដោយមានការយល់ព្រមពី

---

[34] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៧៨។

[35] ឡាយ ហុកគេក និងសាង គឹមឈៀង, "ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ," (សារណាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៥), ទំព័រ ៣៧។

សហព័ទ្ធទាំងសងខាង។[36] លក្ខខណ្ឌតាមផ្លូវច្បាប់ដែលនាំឲ្យមានការលែងលះ ត្រូវបានចែងបញ្ញត្តិយ៉ាងជាក់លាក់ក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ជាអាទិ៍ ៖[37]

- ករណីសហព័ទ្ធណាម្នាក់បានប្រព្រឹត្តអំពើផិតទៅលើសហព័ទ្ធ៖ អំពើផិតនេះ សំដៅដល់ការរួមសវនកិច្ចរវាងបុរសដែលមានចំណងអាពាហ៍ពិពាហ៍ ពីមុនមិនទាន់រលាយជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬ ការរួមសវនកិច្ចរវាងស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍ ពីមុនមិនទាន់រលាយជាមួយបុរសដទៃក្រៅពីប្តីរបស់ខ្លួន។[38]

**ឧទាហរណ៍៖** លោក **ក** មានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយលោកស្រី **ខ**។ ក្រោយរៀបអាពាហ៍ពិពាហ៍បាន ៣ឆ្នាំ លោក **ក** បានប្រព្រឹត្តអំពើផិត ដោយទៅរួមសវនកិច្ចជាមួយកញ្ញា **គ** ដែលជាកំណាន់ចិត្តរបស់ខ្លួនជាច្រើនលើកច្រើនសារ។ ក្នុងករណីដែល លោកស្រី **ខ** រកឃើញភស្តុតាងច្បាស់លាស់ រួមទាំងទង្វើរបស់លោក **ក** ធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់ចំណងអាពាហ៍ពិពាហ៍នោះ លោកស្រី **ខ** អាចធ្វើការប្តឹងសហព័ទ្ធរបស់ខ្លួន គឺលោក **ក** លើបណ្តឹងព្រហ្មទណ្ឌ និងធ្វើការស្នើសុំលែងលះជាមួយលោក **ក** តាមផ្លូវតុលាការបាន។

- ករណីបោះបង់សហព័ទ្ធចោលដោយ គ្មានមូលហេតុ

**ឧទាហរណ៍៖** លោក **ក** មានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយលោកស្រី **ខ** នៅខេត្តសៀមរាប នាឆ្នាំ២០១១។ នៅឆ្នាំ២០១៣ លោក **ក** បានបោះបង់លោកស្រី **ខ** ដោយទុកឲ្យលោកស្រី **ខ** នៅផ្ទះតែម្នាក់ឯង ហើយលោក **ក** បានទៅធ្វើការនៅភ្នំពេញបាត់រហូតដល់បច្ចុប្បន្ន។ ក្នុងករណីដែល លោកស្រី **ខ** រកឃើញភស្តុតាងច្បាស់ថាសកម្មភាពលោក **ក** ផ្ទុយពីគោលបំណងនៃអាពាហ៍ពិពាហ៍រួមទាំងទង្វើរបស់លោក **ក** ធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់ចំណងអាពាហ៍ពិពាហ៍នោះ លោកស្រី **ខ** អាចធ្វើការស្នើសុំលែងលះជាមួយលោក **ក** ទៅតាមផ្លូវច្បាប់បាន។

- ករណីពុំដឹងថាសហព័ទ្ធស្លាប់ ឬរស់អស់រយៈពេលជាងមួយឆ្នាំ៖ ករណីនេះភាគីជាសហព័ទ្ធអាចធ្វើការដាក់បណ្តឹងលែងលះបាន។

**ឧទាហរណ៍៖** លោក **ក** ជាអ្នកជំនួញដែលធ្វើការវិនិយោគនៅបរទេស មានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយភរិយាលោកស្រី **ខ** នាឆ្នាំ២០០៨។ លុះដល់ឆ្នាំ២០១៥ លោក **ក** បានបាត់ខ្លួនដោយមិនត្រឡប់មកវិញ ក្រោយពីបានទៅធ្វើការវិនិយោគនៅក្នុងប្រទេសមួយនាទីប

---

[36] ដដែល, ទំព័រ៣៨។

[37] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៧៨។

[38] ច្បាប់ស្តីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ២១ តុលា ២០០៦, មាត្រា ៧។

អាហ្វ្រិក។ មកដល់ឆ្នាំ២០១៧ លោក **ក** បានបាត់ខ្លួនដោយមិនមានមូលហេតុ និង ដំណឹងអស់រយៈពេល ២ឆ្នាំមកហើយ។ ដូចនេះលោកស្រី **ខ** អាចធ្វើការដាក់ពាក្យបណ្តឹងលែងលះលោក **ក** បាន។

- ករណីដែលមានការរស់នៅបែកបាក់គ្នា ជាបន្តបន្ទាប់អស់រយៈពេល១ឆ្នាំ ដែលផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍

**ឧទាហរណ៍៖** លោកស្រី **ខ** មានអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយស្វាមីលោក **ក** នាអំឡុងឆ្នាំ២០១០។ ក្រោយរស់នៅជាមួយគ្នាមួយរយៈមក អ្នកទាំងពីរមានការមិនចុះសម្រុងនឹងគ្នា ហើយបានបំបែកលំនៅសង្វាសពីគ្នាអស់រយៈពេលជាងមួយឆ្នាំមកហើយ ជាហេតុនាំឲ្យអ្នកទាំងពីរអស់មនោសញ្ចេតនានឹងគ្នា។ ហេតុនេះលោកស្រី **ខ** អាចដាក់ពាក្យបណ្តឹងលែងលះទៅតុលាការដោយផ្អែកលើកម្មវត្ថុខាងលើ។[39]

- ករណីផ្សេងៗទៀត ដែលនាំឲ្យទំនាក់ទំនងនៃអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ និងពុំអាចធ្វើបដិទានឡើងវិញបាន។

**ឧទាហរណ៍៖** លោក **ក** រៀបអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយភរិយាលោកស្រី **ខ** នាឆ្នាំ២០១៥។ លោក **ក** ជាមនុស្សប្រមឹក ដែលតែងតែមានទំនាស់ពាក្យសម្តីជារឿយៗ ជាមួយលោកស្រី **ខ**។ លោកស្រី **ខ** មិនអាចនឹងស៊ូទ្រាំរស់នៅជាមួយលោក **ក** បានទេ។ ទំនាស់របស់លោក **ក** និងលោកស្រី **ខ** គឺពុំអាចធ្វើបដិទានបានឡើយ ទោះជាមានការផ្សះផ្សាជាច្រើនលើកច្រើនសារពីសំណាក់ម្តាយ និងមេឃុំដែលខ្លួនរស់នៅក្តី។ ហេតុនេះលោកស្រី **ខ** អាចដាក់ពាក្យបណ្តឹងលែងលះបាន។

ចំណុចចុងក្រោយខាងលើនេះ ហាក់មានការបកស្រាយយ៉ាងទូលំទូលាយតាមករណីជាក់ស្តែង ដោយហេតុថាករណីផ្សេងទៀតនេះមានច្រើនចំណុចដែលអាចឲ្យភាគីធ្វើការអះអាងបាន។ ផ្ទុយមកវិញ ទោះបីជាស្ថិតក្នុងលក្ខខណ្ឌខាងលើក៏ដោយតែបើមានការលែងលះនោះកើតឡើងដែលនាំឲ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬកូនមានភាពក្រលំបាកខ្លាំង ឬមានភាពឈឺចាប់ដែលពុំអាចទ្រទ្រង់បាន តុលាការក៏មានឆន្ទានុសិទ្ធិក្នុងការច្រានចោលការទាមទារការលែងលះនោះបានផងដែរ ដោយធ្វើការពិចារណាទៅតាមស្ថានភាពជាក់ស្តែង។ ក្នុងនោះតុលាការក៏អាចធ្វើការច្រានចោលដោយឆន្ទានុសិទ្ធិបានដែរ ក្នុងករណីនៃការលែងលះ ដែលសហព័ទ្ធនោះបានរស់នៅបែកបាក់គ្នាជាបន្តបន្ទាប់អស់រយៈពេល ១ឆ្នាំ ឬ ទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបែកបាក់ ឬ ផ្ទុយពីគោលបំណងនៃអាពាហ៍ពិពាហ៍ ដែលការទាមទារនោះមានការផ្ទុយនឹងភាពសុចរិត ដោយជន

[39] សាលក្រមលែងលះ, លេខ ៧៨១ "ឈ" ភ.ព.រ.រ, ៣០ មិថុនា ២០១៥។

ទាមទារឲ្យលែងលះនោះ ធ្វេសប្រហែសយ៉ាងខ្លាំងក្នុងការសហប្រតិបត្តិ និងជួយសង្គ្រោះចំពោះសហព័ទ្ធ។

**២.១.៣.២. ការព្រមព្រៀងរបស់គូភាគី**

ការលែងលះតាមការព្រមព្រៀងរបស់គូភាគី សំដៅដល់ភាគីដែលជាសហព័ទ្ធបានដាក់បណ្តឹងលែងលះទៅតុលាការ ដោយមានការព្រមព្រៀងគ្នាទាំងសងខាង។ ករណីនេះបានន័យថា ភាគីទាំងពីរដែលជាសហព័ទ្ធនឹងគ្នា យល់ថាពួកគេពុំអាចរួមរស់ក្នុងជីវិតអាពាហ៍ពិពាហ៍ជាមួយគ្នាតទៅទៀតបានទេ រួមទាំងបញ្ហាប្រឈមនានា ដែលជាចំណុចចាំបាច់ធ្វើឲ្យជីវភាពអាពាហ៍ពិពាហ៍របស់ពួកគេពុំអាចបន្តបាន។[40] យ៉ាងណាមិញសហព័ទ្ធត្រូវបង្ហាញពីគោលបំណង និងហេតុផលច្បាស់លាស់ទៅតុលាការ ដើម្បីសម្រេចលើបណ្តឹងលែងលះរបស់ពួកគេ។[41]

**ឧទាហរណ៍៖** លោក **ក** រៀបអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយភរិយាលោកស្រី **ខ** នាឆ្នាំ ២០១៦។ លោក **ក** និង លោកស្រី **ខ** យល់ថាពួកគេពុំមានពេលវេលាសម្រាប់គ្នា និងមានទំនាស់ពាក្យសម្តីជាញឹកញាប់។ ពួកគេទាំងពីរយល់ថាមិនអាចនឹងស៊ូទ្រាំរស់នៅជាមួយគ្នាបាន ហេតុនេះ លោក **ក** និង លោកស្រី **ខ** អាចដាក់ពាក្យបណ្តឹងលែងលះ ដើម្បីអាចឲ្យតុលាការចេញសេចក្តីសម្រេចបាន។

**២.១.៤. នីតិវិធីនៃការលែងលះ**

នីតិវិធីនៃការលែងលះនឹងលើកមកបង្ហាញពីចំណុចលម្អិត ដែលភាគីត្រូវបំពេញក្នុងដំណើរនៃនីតិវិធីក្នុងការលែងលះដូចប្លង់សិក្សាខាងក្រោម៖

**២.១.៤.១. នីតិវិធីនៃការលែងលះ ករណីមានការព្រមព្រៀងគ្នា**

ភាគីដែលមានបំណងធ្វើការលែងលះ ត្រូវតែដាក់ពាក្យសុំទៅលំនៅឋានប្តី ឬប្រពន្ធ។[42] ពាក្យស្នើសុំខាងលើ ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់។[43] យ៉ាងណាមិញពាក្យសុំផ្ទាល់មាត់ អ្នកដាក់ពាក្យស្នើសុំត្រូវធ្វើសេចក្តីថ្លែងការណ៍ចំពោះមុខក្រឡាបញ្ជី ហើយក្រឡាបញ្ជីត្រូវធ្វើសៀវភៅកំណត់ហេតុ និងចុះហត្ថលេខា ដែលកំណត់ហេតុនេះត្រូវចាត់ទុកថាជាពាក្យស្នើសុំ។ លិខិតពាក្យស្នើសុំត្រូវរៀបរាប់សរសេរនូវចំណុចដូចជា៖

[40] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៧៩។

[41] ដូច៣៥, ទំព័រ៣៩។

[42] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខនស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, មាត្រា ៩ កថាខណ្ឌ១ (ពីពេលនេះតទៅហៅថា ច្បាប់នីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹងឆ្នាំ២០១០)។

[43] ច្បាប់នីតិវិធីរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹងឆ្នាំ២០១០, មាត្រា២៦ កថាខណ្ឌ១។

- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកពាក្យស្នើសុំ និង ឈ្មោះ អាសយដ្ឋានរបស់អ្នកតំណាងដែលកំណត់ដោយច្បាប់ (អ្នកអាណាព្យាបាលទូទៅសម្រាប់បុគ្គលមានបញ្ហាស្មារតីជាអាទិ៍)។
- ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារ។ អ្នកដាក់ពាក្យត្រូវបង់ពាក្យដាក់ស្នើសុំ ចំនួន ៥,០០០រ។[44]

ក្រោយពីដាក់ពាក្យស្នើសុំហើយ តុលាការត្រូវធ្វើការវិនិច្ឆ័យដោយចេញជា ដីកាសម្រេច អំពីការលែងលះ។ ជាគោលការណ៍ ដើម្បីចេញដីកាសម្រេចនេះ តុលាការពុំចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ឡើយ។[45] យ៉ាងណាមិញតុលាការអាចធ្វើការសាកសួរអ្នកដាក់ពាក្យស្នើសុំ និងភាគីម្ខាងទៀតបាន។

### ២.១.៤.២. នីតិវិធីនៃការលែងលះ ករណីមានពាក្យបណ្ដឹងលែងលះ

ករណីគ្មានការឯកភាពគ្នាក្នុងការលែងលះ នោះភាគីដែលមានបំណងចង់ធ្វើការលែងលះ អាចធ្វើការលែងលះ ដោយមានការដាក់ពាក្យស្នើសុំទៅតុលាការដែលមានសមត្ថកិច្ច ដោយមានការឆ្លងកាត់នូវនីតិវិធីមួយចំនួន ដែលស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល និងក្រមរដ្ឋនីតិវិធីរដ្ឋប្បវេណី។

- **សមត្ថកិច្ចតុលាការ**

ការដាក់ពាក្យបណ្ដឹងនៃការលែងលះ អាចប្រព្រឹត្តទៅបាននៅតុលាការដែលមានសមត្ថកិច្ចជម្រះក្ដីពិសេសនោះ គឺសមត្ថកិច្ចផ្ដាច់មុខរបស់សាលាដំបូងនៃលំនៅឋានរបស់ភាគីនោះ ទំនាក់ទំនងឋានៈបុគ្គលដែលពាក់ព័ន្ធនឹងបណ្ដឹងនោះ ឬ លំនៅឋាននាពេលភាគីទទួលមរណភាព។ ករណីភាគីពុំស្ថិតក្នុងព្រះរាជាណាចក្រកម្ពុជា ឬ លំនៅឋានមិនពិតប្រាកដក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់សមត្ថកិច្ចសាលាជម្រះក្ដីតាមទីសំណាក់នៃបុគ្គលនោះ។ ឯករណីភាគីពុំមានទីសំណាក់ ឬ ទីសំណាក់មិនពិតប្រាកដ នោះសមត្ថកិច្ចត្រូវកំណត់តាមលំនៅឋានចុងក្រោយ។[46]

- **ការដាក់ពាក្យស្នើសុំ**

ភាគីដែលមានបំណងលែងលះអាចដាក់ពាក្យសុំលែងលះ ទៅក្រុមប្រឹក្សាឃុំ-សង្កាត់ នៅខាងលំនៅឋានដែលមានលក្ខខណ្ឌដូចសមត្ថកិច្ចតុលាការដែរ។ ក្នុងករណីនេះក្រុមប្រឹក្សាឃុំសង្កាត់អាចធ្វើការបញ្ចុះបញ្ចូលឲ្យសះជាគ្នាបានក្នុងអំឡុងពេល ១៥ថ្ងៃ ក្រោយទទួលបានពាក្យសុំ។ ប៉ុន្តែ

[44] ច្បាប់នីតិវិធីរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹងឆ្នាំ២០១០, មាត្រា២២ កថាខណ្ឌ១។

[45] ច្បាប់នីតិវិធីរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹងឆ្នាំ២០១០, មាត្រា២៨ កថាខណ្ឌ១។

[46] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១០ (ចាប់ពីពេលនេះទៅហៅថា ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦)។

បើការបញ្ចុះបញ្ចូលនោះពុំមានប្រសិទ្ធិភាព ត្រូវចាត់ទុកថាមានពាក្យបណ្ដឹងលែងលះគ្នានឹងត្រូវបញ្ជូនទៅតុលាការជាបន្ទាន់ដោយក្រុមប្រឹក្សាឃុំ-សង្កាត់។[47] សម្រាប់ការដាក់ពាក្យស្នើសុំខាងលើភាគីដើមចោទត្រូវតែបង់ពន្ធដាក់ពាក្យបណ្ដឹងចំនួន ៥៥០០០៛ (ប្រាំម៉ឺនប្រាំពាន់រៀល)។[48]

### ២.១.៤.៣. ទម្រង់នៃបណ្ដឹងលែងលះ

ទម្រង់នៃបណ្ដឹងលែងលះត្រូវអនុលោមតាម ក្រមនីតិវិធីរដ្ឋប្បវេណី ដែលទម្រង់នៃបណ្ដឹងនេះជាចំណុចចាំបាច់ដែលត្រូវមានក្នុងពាក្យបណ្ដឹង។ ការធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ជាភាពត្រឹមត្រូវ និង ចាំបាច់សម្រាប់ពាក្យបណ្ដឹង។ ដើមបណ្ដឹងត្រូវសរសេររៀបរាប់ជាអាទិ៍អំពី ឈ្មោះ និងអាសយដ្ឋានរបស់ភាគីជាសហព័ទ្ធ ខ្លឹមសារនៃសាលក្រមដែលសហព័ទ្ធ ជាដើមបណ្ដឹងចង់ទាមទារឲ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីធ្វើការបញ្ជាក់នូវការទាមទារ។ បន្ថែមពីនេះទៀតសហព័ទ្ធគប្បីសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់នូវអង្គហេតុ ដែលជាមូលហេតុនៃការទាមទារសុំបណ្ដឹងលែងលះ និងតាមចំណុចដែលត្រូវការបញ្ជាក់នូវភស្តុតាង។[49]

### ២.១.៤.៤. អ្នកមានសិទ្ធិប្ដឹងលែងលះ

ទោះបីជាស្ថិតក្នុងលក្ខខណ្ឌណាក៏ដោយភាគីនៃបណ្ដឹងលែងលះ គឺមានតែសហព័ទ្ធទាំងពីរតែប៉ុណ្ណោះ (ប្ដី និងប្រពន្ធ)។ ភាគីនៃបណ្ដឹង សំដៅដល់ជនទាំងឡាយណាដែលធ្វើការទាមទារឲ្យតុលាការដោះស្រាយវិវាទរបស់ខ្លួនតាមរយៈសាលក្រម ឬ សាលដីកា។ អនុលោមតាម ក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ភាគី ជាប្រធាននៃនីតិវិធីបណ្ដឹងរដ្ឋប្បវេណី ដែលតម្រូវឲ្យភាគីទាំងសងខាងចូលរួមស្ដាប់ អះអាង ពិនិត្យ និងដាក់ភស្តុតាងតទល់នៅក្នុងនីតិវិធីបណ្ដឹងបានរហូតដល់មានការចេញសាលក្រម។[50]

### ២.១.៤.៥. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

នៅក្នុងដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ តុលាការត្រូវរៀបចំនូវសេចក្ដីអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្ដីដែលគូភាគី មិនយល់ស្របគ្នា និងធ្វើការរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្ដីនោះ ដែលអាចឲ្យតុលាការធ្វើការវិនិច្ឆ័យឲ្យបានល្អិតល្អន់ ដើម្បីឈានទៅដល់នីតិវិធីនៃការទាញហេតុផលផ្ទាល់មាត់។[51] កាលបរិច្ឆេទនៃ

---

[47] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៨២ កថាខណ្ឌ២។

[48] ដូច៣, ទំព័រ៣៨៤ ។

[49] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៧៥។

[50] មាស វង្សសុគា និងឆន មួយគា, "អាពាហ៍ពិពាហ៍ និងការលែងលះ," (សារណាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៦), ទំព័រ ៥០។

[51] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១០៣។

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មិនចាំបាច់បើកជាសាធារណៈទេ ដោយហេតុថា កាលបរិច្ឆេទនៃនីតិវិធីត្រៀមទាញហេតុផលនេះ តុលាការគ្រាន់តែធ្វើការកំណត់នូវចំណុចវិវាទតាមរយៈការរៀបចំអះអាងរបស់សហព័ទ្ធអំពីភស្តុតាង ដែលត្រូវត្រួតពិនិត្យតែប៉ុណ្ណោះ ដោយមានការកត់ជាកំណត់ហេតុដោយក្រឡាបញ្ជី។[52]

ចំណុចសំខាន់នៅក្នុងកំណត់ហេតុ ស្តីពីនីតិវិធីត្រៀមសម្រាប់ទាញហេតុផលត្រូវកត់ត្រានូវចំណុចសំខាន់នានាជាអាទិ៍ សញ្ញាណនៃរឿងក្តី ឈ្មោះចៅក្រម និងក្រឡាបញ្ជីដែលត្រូវចុះហត្ថលេខាលើកំណត់ហេតុនោះ។[53] បន្ថែមពីនោះទៀត បើសហព័ទ្ធប្តឹងតវ៉ាចំពោះសេចក្តីកត់ត្រានៅក្នុងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះ ក្រឡាបញ្ជីត្រូវបញ្ចូលកំណត់ត្រាស្តីពីសេចក្តីប្តឹងនោះទៅក្នុងកំណត់ហេតុបន្ថែមទៀត។[54]

### ២.១.៤.៦. នីតិវិធីនៃការទាញហេតុផលផ្ទាល់មាត់

នៅក្នុងនីតិវិធីនេះ តម្រូវឲ្យសហព័ទ្ធធ្វើសេចក្តីថ្លែងការណ៍ អំពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល។[55] សហព័ទ្ធគ្រាន់តែធ្វើសេចក្តីថ្លែងការណ៍នៃនីតិវិធីត្រៀមទាញហេតុផលនេះគ្រប់គ្រាន់ទៅហើយ ឯការអះអាងអង្គហេតុ ការរៀបចំចំណុចវិវាទ និងការពិនិត្យភស្តុតាងស្ថិតក្នុងនីតិវិធីនៃការទាញហេតុផលផ្ទាល់មាត់។ យ៉ាងណាមិញ មិនមានការដាក់កំហិតដាច់ខាតណាមួយ ឲ្យសហព័ទ្ធដាច់ខាតត្រូវតែជាអ្នកអះអាងនោះទេ។ ម៉្យាងវិញទៀត រាល់សកម្មភាពបណ្តឹងដែលធ្វើឡើងក្នុងនីតិវិធីត្រៀមសម្រាប់ទាញហេតុផល សុទ្ធតែមានការកត់ត្រានៅក្នុងកំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ ទាញហេតុផលរួចទៅហើយ។ ដូចនេះសេចក្តីថ្លែងការណ៍អាចធ្វើឡើងដោយសង្ខេប ដោយលើកឡើងពីការអះអាងអំពីអង្គហេតុ ការដាក់ភស្តុតាងលទ្ធផលនៃការពិនិត្យភស្តុតាង លទ្ធផលនៃការរៀបចំចំណុចវិវាទដែលបានធ្វើឡើងក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះ។[56]

## ២.១.៥. ការចាត់ចែងរក្សាការពារ

ជាគោលការណ៍តុលាការដែលបានទទួលបណ្តឹងលែងលះគ្នា របស់គូភាគីអាចចេញដីកាសម្រេចបង្គាប់ឲ្យធ្វើការចាត់ចែងរក្សាការពារចំពោះ ការបំបែកលំនៅឋាន ការគ្រប់គ្រងកូន ការគ្រប់គ្រងទ្រព្យសម្បត្តិ អាហារកាតព្វកិច្ចរបស់សហព័ទ្ធ បន្ទុកសោហ៊ុយអាពាហ៍ពិពាហ៍ និង

[52] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ១០៩។

[53] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ១១០។

[54] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ១១២។

[55] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា ១១២ (កថាខណ្ឌ១)។

[56] ដូច៥០, ទំព័រ៥៦។

សោហ៊ុយចិញ្ចឹមបីបាច់កូនជាអាទិ៍ តាមពាក្យស្នើសុំរបស់គូភាគី ឬតាមឆន្ទានុសិទ្ធិរបស់ខ្លួនបាន។[57] យោងតាម អត្ថន័យខាងលើបានសបង្ហាញឲ្យឃើញថា ការចាត់ចែងរក្សាការពារ ជាវិធានមួយដ៏ចាំបាច់ក្នុងកិច្ចការរក្សាការពារក៏ ដូចជាបង្ការនូវហានិភ័យ ដែលអាចរារាំងដល់ការអនុវត្តសាលក្រមរបស់តុលាការ។

ម្យ៉ាងទៀតការចាត់ចែងរក្សាការពារនេះ ក៏ជាវិធានការមួយធានាដល់ការរក្សាការពារនូវទ្រព្យសម្បត្តិដែលមានរបស់សហព័ទ្ធ ដើម្បីធានាឲ្យជីវភាពរស់នៅក្នុងគ្រួសារ អាចបន្តទៅទៀតបាន។

**ឧទាហរណ៍៖** លោក **ក** បានរៀបអាពាហ៍ពិពាហ៍ ជាមួយលោកស្រី **ខ** កាលពីឆ្នាំ២០១៣ ។ គិតមកត្រឹមឆ្នាំ ២០១៨ អ្នកទាំងពីរមាន កូនចំនួន ៣ នាក់។ លោក **ក** និង លោកស្រី **ខ** តែងមានការឈ្លោះប្រកែកគ្នាជាញឹកញាប់ និង រស់នៅប្រកបដោយភាពរកាំរកូស។ លោក **ក** បានចាកចេញពីផ្ទះទៅនៅផ្ទះម្ដាយរបស់ខ្លួន។ លោកស្រី **ខ** មានការគ្រាំចិត្តជាខ្លាំង និងមានបំណងលែងលះជាមួយលោក **ក**។ យ៉ាងណាមិញលោកស្រី **ខ** ពុំមានមុខរបរ ឬ ការងារអ្វីមួយជាក់លាក់ឡើយជាហេតុនាំឲ្យមានបញ្ហារារាំងជាខ្លាំងដល់ជីវភាពរស់នៅរបស់ខ្លួន។ ដូចនេះលោកស្រី **ខ** អាចស្នើសុំទៅតុលាការនូវដីកាសម្រេចរក្សាការពារទៅតុលាការ ដើម្បីស្នើសុំសិទ្ធិគ្រប់គ្រងកូនបណ្ដោះអាសន្ន (រក្សាសិទ្ធិនេះរហូតដល់មានការសម្រេចចាត់ចែងពីតុលាការ) ព្រមទាំងអាចស្នើសុំឲ្យលោក **ក** បង់ប្រាក់ជាបណ្ដោះអាសន្ន ដើម្បីធានាដល់ការចិញ្ចឹមបីបាច់កូន។

### ២.១.៦. សេចក្ដីសម្រេចរបស់តុលាការ

តុលាការ នឹងធ្វើការចេញសាលក្រម ដើម្បីបញ្ជាក់សេចក្ដីសម្រេចរបស់ខ្លួនក្រោយពីធ្វើការវិនិច្ឆ័យ។ ក្នុងអំឡុងពេល២សប្ដាហ៍ គិតចាប់ពីថ្ងៃសម្រេចសាលក្រមលើការលែងលះ តុលាការត្រូវបញ្ជូនសាលក្រមទៅឲ្យគូភាគី។[58] យ៉ាងណាមិញផ្លូវច្បាប់បានបើកឲ្យគូភាគី ប្ដឹងឧទ្ធរណ៍ទៅតុលាការបានក្នុងអំឡុងពេល ១ខែ គិតចាប់ពីថ្ងៃដែលទទួលបានការបញ្ជូនលិខិតសាលក្រម។[59] រឿងក្ដីនៃការលែងលះនេះ តុលាការមិនអាចចេញសាលក្រមកំបាំងមុខបានឡើយ ពោលគឺសាលក្រមដែលចេញដោយតុលាការ គឺជាសាលក្រមធម្មតាដែលមិនអាចអនុញ្ញាតឲ្យមានការប្ដឹងទាស់បានទេ។[60]

---

[57] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៨៣។

[58] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១៩០, ក្រមនីតិវិធីរដ្ឋប្បវេណី។

[59] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា២៦៤ កថាខណ្ឌ១។

[60] ដូច៣, ទំព័រ៣៨៥។

- **សាលក្រមចំពោះមុខ៖**

ការប្រកាសសាលក្រម ត្រូវធ្វើឡើងតាមកាលបរិច្ឆេទ នៅក្នុងសវនាការជាសាធារណៈដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ ជាអ្នកអានសេចក្តីសម្រេចបញ្ចប់ ដោយផ្អែកលើច្បាប់ដើមនៃមូលសាលក្រម។ ចៅក្រមប្រឹក្សា អាចអានជំនួសប្រធានក្រុមប្រឹក្សាបាន ករណីប្រធានក្រុមប្រឹក្សាមានធុរៈ។ យ៉ាងណាមិញ ការអានជំនួសនេះពុំមានឥទ្ធិពលលើការផ្លាស់ប្តូរនៃសេចក្តីសម្រេចរបស់សាលក្រមឡើយ។[61]

- **សាលក្រមកំបាំងមុខ៖**

នៅពេលដែលសហព័ទ្ធចុងចម្លើយអវត្តមាន ដោយគ្មានមូលហេតុត្រឹមត្រូវ ឬ ពុំបានជូនដំណឹងទៅតុលាការទេ នោះតុលាការអាចសម្រេចក្នុងការប្រកាសសាលក្រមបាន។[62] ផ្ទុយមកវិញ តុលាការមិនអាចចេញសាលក្រមកំបាំងមុខបានឡើយ បើសហព័ទ្ធមិនបានបង្ហាញខ្លួន ព្រោះតែមិនបានទទួលការកោះហៅស្របតាមផ្លូវច្បាប់ ឬ មានមូលហេតុណាមួយសមរម្យដែលមិនអាចបង្ហាញខ្លួនបាន ឬ អាចបណ្តាលមកពីគ្រោះមហន្តរាយធម្មជាតិ ឬ កាលៈទេសៈផ្សេងៗទៀតដែលពុំអាចជៀសបាន។[63]

ជាចុងក្រោយ តុលាការនឹងធ្វើការប្រកាសសាលក្រមលើបណ្តឹងលែងលះគ្នាបាន ដែលធ្វើការបញ្ជាក់នូវលទ្ធផលអាច ឬមិនអាចលែងលះគ្នាបាន។

- **ករណីលែងលះគ្នាបាន៖** តុលាការបានរកឃើញថា ការលែងលះគ្នានោះកើតឡើងដោយឆន្ទៈពិតប្រាកដរបស់គូភាគី និង ដោយពុំមានការគំរាមកំហែង ឬបង្ខិតបង្ខំពីនរណាម្នាក់ឡើយនោះ គឺកើតចេញពីឆន្ទៈពិតប្រាកដ ក្នុងគោលបំណងបញ្ចប់ចំណងអាពាហ៍ពិពាហ៍របស់ពួកគេ។
- **ករណីតុលាការយល់ឃើញថាមិនអាចលែងលះ៖** ករណីដែលចៅក្រមយល់ឃើញថា ការលែងលះរបស់សហព័ទ្ធនឹងបណ្តាលឲ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធណាម្ខាង ឬ កូនមានភាពលំបាកខ្លាំង ឬ មានការឈឺចាប់ដែលពុំអាចនឹងទ្រទ្រង់បាន ឬ ដោយស្ថានភាពនានាទាំងឡាយនោះតុលាការអាចសម្រេចច្រានចោលការទាមទារការលែងលះគ្នាបាន។ ប៉ុន្តែការច្រានចោលនេះត្រូវធ្វើដោយមានការពិចារណាច្បាស់លាស់ សមហេតុផល គិតគូរយ៉ាងល្អិនល្អន់ប្រកបដោយសច្ចភាព និងយុត្តិធម៌។

[61] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា១៨៨។

[62] ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា២០១។

## ២.២. អានុភាពនៃការលែងលះ

ការលែងលះ សំដៅដល់ការបញ្ចប់ចំណងអាពាហ៍ពិពាហ៍ស្របច្បាប់របស់គូស្វាមី ភរិយា (សហព័ទ្ធ)។ ការលែងលះនេះ ជាមូលហេតុនាំឲ្យមានការរួចផុតពីកាតព្វកិច្ចទាំងឡាយ ក្នុងកំឡុងពេលអាពាហ៍ពិពាហ៍។ យ៉ាងណាមិញ បើទោះបីជាមានការបញ្ចប់ចំណងអាពាហ៍ពិពាហ៍ក៏ដោយ ក៏សហព័ទ្ធនៅជាប់កាតព្វកិច្ចមួយទៀត តាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ និងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ផងដែរនោះ គឺអាហារកាតព្វកិច្ចពីសហព័ទ្ធម្ខាងទៀត។

### ២.២.១. អានុភាពនៃការលែងលះទាក់ទងនឹងនាមត្រកូលសហព័ទ្ធ

ប្តី ឬប្រពន្ធដែលបានធ្វើការប្តូរនាមត្រកូលថ្មី ដោយអាពាហ៍ពិពាហ៍ អាចប្រើនាមត្រកូលដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍បាន ឬ អាចប្រើនាមត្រកូលដែលបានប្រើនៅពេលលែងលះគ្នាក៏បាន។[64]

**ឧទាហរណ៍៖** លោក **ច័ន្ទ ភក្កដា** បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងលោកស្រី **ពុធ មិថុនា**។ ក្រោយរៀបអាពាហ៍ពិពាហ៍លោកស្រី **ពុធ មិថុនា** បានប្តូរត្រកូលលោកស្រីដោយដាក់តាមត្រកូលរបស់លោក **ភក្កដា** ជាស្វាមីវិញ នោះ គឺពី **ពុធ មិថុនា** ទៅលោកស្រី **ច័ន្ទ មិថុនា** វិញ។ ក្រោយរៀបអាពាហ៍ពិពាហ៍បាន ៥ឆ្នាំ អ្នកទាំងពីរបានធ្វើការលែងលះគ្នា។ ត្រង់ចំណុចនេះផ្លូវច្បាប់បានបើកឲ្យលោកស្រី **មិថុនា** ក្នុងការជ្រើសរើសនូវជម្រើសនៃការប្រើប្រាស់នាមត្រកូលខ្លួនបានពោលគឺ រក្សាឈ្មោះក្រោយអាពាហ៍ពិពាហ៍ **ច័ន្ទ មិថុនា** ដដែល ឬ ត្រលប់ទៅប្រើនាមត្រកូលដើមរបស់ខ្លួនថា **ពុធ មិថុនា** វិញ។

### ២.២.២. អានុភាពនៃការលែងលះចំពោះកូន

ទោះបីជាមិនមានការស្នើសុំពីគូភាគីក៏ដោយ ក៏តុលាការត្រូវកំណត់ពីអ្នកមានអំណាចមេបាដោយផ្អែកតាមឆន្ទានុសិទ្ធិ។[65] ជាគោលការណ៍ការកំណត់អ្នកមានអំណាចមេបាលើកូន គឺផ្អែកតាមការពិភាក្សារបស់គូភាគី(សហព័ទ្ធ)។[66] ចំណុចនេះផ្លូវច្បាប់បានបើកយ៉ាងទូលាយ ដល់គូភាគីក្នុងការពិភាក្សាគ្នា ថាអ្នកណាជាអ្នកដែលមានសិទ្ធិគ្រប់គ្រង និងមានអំណាចមេបាទៅលើកូនៗរបស់ពួកគេ។ ក្នុងករណីដែលការពិភាក្សាមិនបានជោគជ័យទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបា ដោយផ្អែកលើផលប្រយោជន៍របស់កូន។[67] លក្ខខណ្ឌពិសេសមួយ ករណីដែលការលែងលះ

[64] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៨១។

[65] ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខនស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០, មាត្រា ២២ កថាខណ្ឌ១ (ចាប់ពីពេលនេះទៅហៅថា ច្បាប់ស្តីពីឋានៈបុគ្គលឆ្នាំ២០១០)។

[66] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៣៧ កថាខណ្ឌ១។

[67] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៣៧ កថាខណ្ឌ៣។

កើតឡើងអំឡុងពេលដែលម្តាយមិនទាន់សម្រាលកូន (គភ៌) នោះម្តាយ គឺជាអ្នកដែលមានអំណាចមេបាលើកូនដែលកើតមកនោះ។ យ៉ាងណាមិញ ក្រោយកំណើតកូន បើផ្អែកតាមការពិភាក្សារបស់គូភាគី នោះឪពុកក៏អាចក្លាយជាអ្នកមានអំណាចមេបាលើកូនផងដែរ។[68] បន្ថែមពីនេះទៀត បើការពិភាក្សាមិនបានសម្រេចក្រោយកំណើតរបស់កូននោះទេ នោះតុលាការអាចនឹងចូលមកអន្តរាគមន៍សម្រេចសេចក្តី តាមពាក្យស្នើសុំរបស់ឪពុកកូនដែលកើតមក។[69]

យ៉ាងណាមិញសម្រាប់ភាគីដែលមិនមានអំណាចមេបាលើកូន គាត់មានសិទ្ធិចូលជួប និងប្រាស័យទាក់ទងកូន និងមានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងមើលថែរក្សាកូន។[70] ក្នុងករណីមិនអាចធ្វើការពិភាក្សាបានទេ តុលាការជាអ្នកកំណត់ការទាមទាររបស់ឪពុក ឬម្តាយ ដោយផ្អែកលើផលប្រយោជន៍របស់កូនជាអាទិភាព។ តុលាការអាចយកមូលហេតុជាច្រើនមកធ្វើជាមូលដ្ឋានក្នុងការសម្រេចសេចក្តីដូចជា ទំនាក់ទំនងរវាងកូន និងឪពុកម្តាយដែលរស់នៅជាមួយគ្នា អាយុ ស្ថានភាព សុខភាព បំណង របស់កូនក៏ដូចជាគូភាគីព្រមទាំងស្ថានភាពផ្លូវចិត្តរបស់គ្រប់គូភាគីទាំងអស់ ដើម្បីជាគ្រឹះក្នុងការវិនិច្ឆ័យ។ ទន្ទឹមនឹងនេះដែរ ក្រមរដ្ឋប្បវេណីបានកំណត់ តម្រូវឲ្យភាគីម្ខាងបង់នូវសោហ៊ុយជាចាំបាច់ទៅតាមខែនីមួយៗ ក្នុងកំឡុងពេលជាក់លាក់មួយទៅតាមស្ថានភាព និងការយល់ឃើញផ្អែកតាមឆន្ទានុសិទ្ធិរបស់តុលាការ។[71]

គួរឲ្យកត់សម្គាល់ផងដែរថា ទាក់ទងនឹងការសម្រេចសេចក្តីខាងលើតុលាការត្រូវធ្វើការថ្លឹងថ្លែងដោយពិចារណាទៅលើយោបល់របស់កូនដែលមានការសមស្របទៅតាមអាយុ និងសភាពចាស់ទុំរបស់កូន។[72] បន្ថែមពីនេះទៀត ទោះបីជាតុលាការបានសម្រេចសេចក្តីពីការកំណត់អ្នកមានអំណាចមេបា ការចូលជួប និងការប្រាស្រ័យទាក់ទងជាមួយកូន ឬ កំណត់សោហ៊ុយចាំបាច់ដើម្បីថែរក្សាកូនរួចហើយក្តីក៏សេចក្តីសម្រេចនេះនៅតែអាចជាកម្មវត្ថុនៃការផ្លាស់ប្តូរបានដែរ។[73]

### ២.២.៣. អានុភាពនៃការលែងលះ និងបែងចែកទ្រព្យសម្បត្តិករណីមានកិច្ចសន្យាទ្រព្យសម្បត្តិ ឬ ព្រមព្រៀងគ្នា

កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ សំដៅដល់កិច្ចសន្យាដែលបានចែងពីទំនាក់ទំនងទ្រព្យសម្បត្តិរបស់ខ្លួននៅមុន ឬ ក្រោយពេលអាពាហ៍ពិពាហ៍ ដែលពុំមានខ្លឹមសារផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិ

[68] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៣៧ កថាខណ្ឌ២។

[69] ដូចខ, ទំព័រ៣៨៦។

[70] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៤០។

[71] ដូចខ, ទំព័រ៣៨៧។

[72] ច្បាប់ស្តីពីឋាន:បុគ្គលឆ្នាំ២០១០, មាត្រា២២ កថាខណ្ឌ៤។

[73] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៣៩, មាត្រា១០៤០ កថាខណ្ឌ៥។

ទាមទារអាហារកាតព្វកិច្ច និងភាគបម្រុង។[74] ជាគោលការណ៍ ក្រមរដ្ឋប្បវេណីបានឲ្យតម្លៃលើសិទ្ធិស្វ័យភាពនៃបុគ្គលឯកជន ពោលគឺគោរពនូវសេរីភាពនៃឆន្ទៈស្វ័យសម្រេចរបស់បុគ្គលឯកជនក្នុងការដោះស្រាយវិវាទរដ្ឋប្បវេណីជាទូទៅ។[75]

ជាការពិតករណីសហព័ទ្ធបានកំណត់យ៉ាងជាក់លាក់អំពីប្រព័ន្ធនៃទ្រព្យសម្បត្តិក្នុងគ្រួសាររបស់ខ្លួន ដោយមានចែងក្នុងកិច្ចសន្យាជាពិសេស នោះគ្រប់យ៉ាងនៃការបែងចែកទ្រព្យសម្បត្តិនោះត្រូវអនុលោមតាមខ្លឹមសារដែលបានចែងកំណត់ក្នុងកិច្ចសន្យានោះ។ យ៉ាងណាមិញ បើសហព័ទ្ធពុំមានវិវាទនឹងគ្នាលើការបែងចែកទ្រព្យសម្បត្តិពោល គឺគ្រប់ភាគីធ្វើការពិភាក្សាគ្នាដោយជោគជ័យ នោះពួកគេក៏ពុំត្រូវការជាចាំបាច់នូវ ការចូលអន្តរាគមន៍ពីតុលាការនោះទេ។ បន្ថែមពីនេះភាគីត្រូវរក្សាគោលជំហរនៃស្មារតីនៃក្រមរដ្ឋប្បវេណីកម្ពុជាផងដែរនោះ គឺគោលការណ៍យុត្តិធម៌ក្នុងការបែងចែកភាគនៃទ្រព្យសម្បត្តិ។

### ២.២.៤. អានុភាពនៃការលែងលះ និងចំណែងចែកទ្រព្យសម្បត្តិតាមផ្លូវច្បាប់

ក្រោយពីបានលែងលះគ្នាហើយ អានុភាពនៃការលែងលះពិតជាមានសារៈសំខាន់ណាស់ក្នុងការចែកចំណែកទ្រព្យសម្បត្តិរបស់សហព័ទ្ធប្រកបតាមគោលការណ៍សមធម៌។ បើធ្វើការប្រៀបធៀបទៅនឹងក្រមរដ្ឋប្បវេណីចាស់ឆ្នាំ ១៩២០ វិញហាក់មិនមានភាពស្មើភាពគ្នាសោះឡើយសម្រាប់ការបែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធ។ ក្នុងនោះករណីដែលការលែងលះកើតចេញពីកំហុសរបស់ប្រពន្ធ នោះនាងនឹងមិនត្រូវបានចំណែកនៃទ្រព្យរួមឡើយ ពោលគឺត្រឹមផ្នែកនៃទ្រព្យដោយឡែកដែលនៅសល់របស់នាងប៉ុណ្ណោះ ទោះជាទំហំបរិច្ចាគរបស់នាងមានច្រើន ឬក៏ការចាយវាយខ្ជីខ្ជារបស់ប្តីក៏ដោយ។[76] បន្ថែមពីនេះទៀតច្បាប់កម្ពុជានាសម័យនោះថែមទាំងរឹតត្បិតលើប្រពន្ធស្ទើរគ្រប់លក្ខខណ្ឌ ឯបុរសជាប្តីវិញពុំសូវមានលក្ខខណ្ឌរឹតត្បិតទេ ថែមទាំងអាចយកភរិយាដើម និងចុងបានទៀតផង។[77] លក្ខខណ្ឌទាំងនេះបានបង្ហាញពីភាពពុំស្មើសិទ្ធិគ្នារវាងបុរស និងស្ត្រីនាសម័យកាលនោះ ក៏ដូចជាផ្ទុត់គំនិតនៃសង្គមក្នុងការឲ្យតម្លៃលើស្ត្រីខ្មែរ។

ក្នុងករណីដែលសហព័ទ្ធដែលបានលែងលះពុំអាចពិភាក្សាគ្នា ក្នុងការបែងចែកទ្រព្យសម្បត្តិបានទេនោះ ក្រមរដ្ឋប្បវេណីនឹងចូលធ្វើការអន្តរាគមន៍ដោះស្រាយ។ ក្នុងនោះដែរខ្លឹមសារជា

---

74 ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៦៩។

75 ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦, មាត្រា៣។

76 ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ១៩២០, មាត្រា ២៥៣។

77 ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ១៩២០, ចំពូក២ (អំពីអាពាហ៍ពិពាហ៍)។

គោលនៃក្រមរដ្ឋប្បវេណីបានកំណត់បែងចែកឲ្យសហព័ទ្ធនីមួយៗ ត្រូវទទួលបាននូវទ្រព្យសម្បត្តិមួយចំនួនក្រោយការលែងលះដូចជា៖

**២.២.៤.១. អំពីទ្រព្យសម្បត្តិដោយឡែករបស់សហព័ទ្ធ**

ទ្រព្យសម្បត្តិដោយឡែក សំដៅដល់ទ្រព្យសម្បត្តិដែលសហព័ទ្ធនីមួយៗ មានមុនពេលរៀបអាពាហ៍ពិពាហ៍ ឬ ទទួលបានតាមរយៈប្រទានកម្ម សន្តតិកម្ម អច្ច័យទាន ឬ តម្លៃតបដែលបានចាត់ចែងទ្រព្យសម្បត្តិខាងលើក្នុងអំឡុងពេលអាពាហ៍ពិពាហ៍របស់ខ្លួន។[78] ហេតុដូចនេះសហព័ទ្ធដែលលែងលះ នឹងទទួលបាននូវចំណែកនៃទ្រព្យដោយឡែករបស់ខ្លួនទាំងស្រុង។[79]

យ៉ាងណាមិញបើនិយាយឲ្យទូលំទូលាយ និងធ្វើការប្រៀបធៀបទ្រព្យដោយឡែកទៅនឹងក្រមរដ្ឋប្បវេណីប្រទេសបារាំង ត្រង់មាត្រា១៤០៤ ដែលបានចាត់ទុកទ្រព្យផ្ទាល់ដែលមានពីធម្មជាតិដែលវាត្រូវបានធ្វើលទ្ធកម្មក្នុងអំឡុងពេលអាពាហ៍ពិពាហ៍នៅក្នុងសុពលភាពដែលមានជាអាទិ៍៖

- សម្លៀកបំពាក់ និងគ្រឿងសម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន
- សំណងព្យសនកម្មលើបូរណភាពខាងរាងកាយ និងផ្លូវចិត្ត
- ឥណទេយ្យ និងសោធនអាហារកិច្ច។[80]

**ឧទាហរណ៍៖** លោក **មករា** និងលោកស្រី **កុម្ភៈ** បានរៀបអាពាហ៍ពិពាហ៍នឹងគ្នាកាលពីឆ្នាំ២០១៥។ ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍អ្នកស្រី **រាជនី** ជាម្ដាយលោកស្រី **កុម្ភៈ** បានផ្ដល់ជាអំណោយរថយន្តម៉ាក ឡិចសឹស៥៧០ សេរីឆ្នាំ ២០១៣ មួយគ្រឿងដល់កូនស្រីរបស់គាត់នាឆ្នាំ២០១៦ និងក្រោយពេលមរណភាពរបស់អ្នកស្រី **រាជនី** នាឆ្នាំ២០១៦ លោកស្រី **កុម្ភៈ** បានទទួលនូវសន្តតិកម្មជាដីឡូត៍ចំនួន ៣ ទីតាំងនៅឯជាយរាជធានីភ្នំពេញ និងថវិកា ១លានដុល្លារ បន្ថែមទៀត។ ក្រោយមកដោយរស់នៅមិនចុះសម្រុងនឹងគ្នានៅដើម ឆ្នាំ២០១៨ លោក **មករា** និងលោកស្រី **កុម្ភៈ** បានលែងលះគ្នា។ តាមលក្ខខណ្ឌច្បាប់ខាងលើលោកស្រី **កុម្ភៈ** នឹងទទួលបានទាំងស្រុងនូវចំណែកនៃរថយន្ត ម៉ាកឡិចសឹស ៥៧០ សេរីឆ្នាំ២០១៣ មួយគ្រឿង ដីឡូត៍ចំនួន ៣ ទីតាំង និងថវិកា ១លានដុល្លារ ដែលសុទ្ធសឹងទទួលបានពីអំណោយ(ប្រទានកម្ម) និងសន្តតិកម្មរបស់អ្នកស្រី **រាជនី** ដែលជាម្ដាយរបស់ខ្លួន។

**២.២.៤.២. អំពីទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ**

ទ្រព្យសម្បត្តិរួម សំដៅដល់ទ្រព្យសម្បត្តិទាំងឡាយណាដែលសហព័ទ្ធតែម្ខាង ឬ ទាំងសងខាងរកបានក្នុងកំឡុងពេលអាពាហ៍ពិពាហ៍ដែលខុសពីចំណុចកំណត់នៃលក្ខខណ្ឌទ្រព្យដោយ

[78] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៧២។

[79] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៨០ (កថាខណ្ឌ២ ចំណុច ក)។

[80] ស្រី វណ្ណធី, *នីតិបេតិកភណ្ឌ និងគ្រួសារ*, បោះពុម្ពលើកទី១ (ភ្នំពេញ, ២០១២), ៣៦។

ឡែក។[81] យ៉ាងណាមិញបន្ថែមពីទ្រព្យដោយឡែកខាងលើសហព័ទ្ធក៏នឹងទទួលបាននូវចំណែកមួយភាគពីរ នៃទ្រព្យសម្បត្តិរួមរបស់ពួកគេទៀតផង។[82]

**ឧទាហរណ៍៖** លោក **មករា** និងលោកស្រី **កុម្ភៈ** បានរៀបអាពាហ៍ពិពាហ៍នឹងគ្នាកាលពីឆ្នាំ២០០០។ ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍អ្នកទាំងពីរបានខិតខំរកស៊ី និងរកបានទ្រព្យមួយចំនួនក្នុងអំឡុងពេលអាពាហ៍ពិពាហ៍រួមមាន ដីស្រែ បី កន្លែងនៅខេត្តកំពត មាស៊ីនកិនស្រូវ មួយគ្រឿង ម៉ាស៊ីនបូមទឹក មួយគ្រឿង ម៉ូតូហុងដាឆ្នាំ ២០១០ មួយគ្រឿង រទេះគោ មួយ និងប្រាក់សុទ្ធចំនួន ៦,០០០,០០០ រៀល។ ក្រោយពីមានការឈ្លោះប្រកែកគ្នា និងមានភាពរកាំរកូសអ្នកទាំងពីរ ក៏សម្រេចចិត្តលែងលះ។ ដូចនេះ ផ្អែកតាមលក្ខខណ្ឌនៃច្បាប់អ្នកទាំងពីរនឹងទទួលបានចំណែកម្នាក់ពាក់កណ្តាលលើទ្រព្យសម្បត្តិរួមរបស់អ្នកទាំងពីរ។[83]

### ២.២.៤.៣. អំពីបំណុលរួមរបស់សហព័ទ្ធ

ទាក់ទងនឹងបញ្ហាបំណុល ដែលសហព័ទ្ធទាំងសងខាងបានជំពាក់តតិយជនក្នុងកំឡុងពេលអាពាហ៍ពិពាហ៍ សហព័ទ្ធមានសិទ្ធិក្នុងការព្រមព្រៀងគ្នាធ្វើការសងបំណុលបាន។ យ៉ាងណាមិញ តុលាការនៅតែមានឆន្ទានុសិទ្ធិក្នុងការសម្រេចសេចក្តី នៅពេលដែលការពិភាក្សាមិនបានសម្រេច ឬ ក៏អាចឲ្យសហព័ទ្ធធ្វើការទទួលខុសត្រូវពាក់កណ្តាលម្នាក់។

### ២.២.៤.៤. លក្ខខណ្ឌជាមូលដ្ឋាននៃការវិនិច្ឆ័យរបស់តុលាការ

ម៉្យាងវិញទៀត តុលាការក៏មានឆន្ទានុសិទ្ធសម្រេចលើការបែងចែកទ្រព្យរួម ដោយផ្អែកលើស្ថានភាពផ្សេងៗទៀតតាមរយៈការទាមទាររបស់សហព័ទ្ធណាម្ខាងដូចជា៖[84]

- **ទំហំនៃការបរិច្ចាគរបស់សហព័ទ្ធនីមួយៗ**

**ឧទាហរណ៍៖** បុរសជាប្តីបានខិតខំប្រកបការងារផង និងឆ្លៀតពេលមើលថែកូន រួមទាំងរៀបចំធ្វើការងារផ្ទះផង។ ឯនារីជាប្រពន្ធតែងតែលេងល្បែងជាប្រចាំ និងពុំសូវធ្វើការងារផ្ទះឡើយ ថែមទាំងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិក្នុងគ្រួសារអស់ជាច្រើនសន្ធឹកសន្ធាប់។ ផ្អែកតាមករណីនេះ តុលាការអាចយកមូលហេតុខាងលើមកវិនិច្ឆ័យ ដោយបែងចែកទ្រព្យរួមទៅឲ្យសហព័ទ្ធជាប្តីនៅចំនួនមួយសមរម្យតាមរយៈទំហំនៃការបរិច្ចាគរបស់គាត់។

[81] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៧៣។

[82] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៨០ (កថាខណ្ឌ២ ចំណុច ខ វាក្យខណ្ឌ១)។

[83] សាលក្រមលែងលះ, លេខ ២០ (ង), ០៣ សីហា ២០១៥។

[84] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៨០ (កថាខណ្ឌ២ ចំណុច ខ វាក្យខណ្ឌ២)។

- **ទំហំនៃការបរិច្ចាគរបស់សហព័ទ្ធនីមួយៗចំពោះលទ្ធកម្មនូវទ្រព្យសម្បត្តិ**

**ឧទាហរណ៍៖** បុរស ជាប្តីបានដកលុយដែលជាទ្រព្យសម្បត្តិដោយឡែករបស់គាត់ បូករួមនឹងទ្រព្យសម្បត្តិដែលប្តីប្រពន្ធគាត់រកបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ទៅទិញរថយន្តមួយគ្រឿង។ ដូចនេះផ្អែកតាមលទ្ធកម្មនៃការរួមចំណែករបស់ប្តី តុលាការអាចនឹងពិចារណាបែងចែកចំណែករបស់ប្តីលើរថយន្តជាកម្មសិទ្ធិនោះធំជាងប្រពន្ធបាន។

- **ការថែរក្សា ឬការបង្កើនទ្រព្យសម្បត្តិ**

**ឧទាហរណ៍៖** ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍បុរស ជាប្តីបានខិតខំធ្វើការងារ និងបានសន្សំលុយទិញដីមួយកន្លែង ហើយបុរសជាប្តីនោះតែងតែទៅមើលថែរក្សា និងចូលរួមសម្អាតជាប្រចាំ។ ដូចនេះផ្អែកតាមការរួមចំណែករបស់ប្តីក្នុងការមើលថែរក្សា និងសម្អាតដីនោះតុលាការអាចនឹងពិចារណាបែងចែកចំណែករបស់ប្តីលើដីធ្លីជាកម្មសិទ្ធិនោះធំជាងប្រពន្ធបាន។

- **កម្រិតជីវភាពរស់នៅអំឡុងពេលអាពាហ៍ពិពាហ៍**

**ឧទាហរណ៍៖** លោកស្រី **សោភា** បានរៀបអាពាហ៍ពិពាហ៍ជាមួយលោក **សន្ធា** ប៉ុន្តែលោកស្រី **សោភា** ជាកូនកំព្រា និងពុំមានទ្រព្យដោយឡែកសោះឡើយ។ ឯលោក **សន្ធា** ជាអ្នកមានទ្រព្យធន់ និងបានផ្គត់ផ្គង់ជីវភាពលោកស្រី **សោភា** ក្នុងកម្រិតមួយស៊ីវិល័យ និងសំបូរបែប។ ករណីដែលអ្នកទាំងពីរមានបំណងលែងលះ តុលាការអាចយកស្ថានភាពនៃកម្រិតជីវភាព និងការរួមចំណែករបស់លោក **សន្ធា** ធ្វើជាមូលដ្ឋាន ដោយបែងចែកចំណែកនៃទ្រព្យសម្បត្តិឲ្យលោក **សន្ធា** ឲ្យបានច្រើនជាងលោកស្រី **សោភា** ។

- **អាយុ ស្ថានភាពផ្លូវចិត្ត និងផ្លូវកាយ**

**ឧទាហរណ៍៖** អ្នកស្រី **ដាលី** មានអាយុ ៧០ឆ្នាំ និងមានជំងឺទឹកនោមផ្អែម ដែលទាមទារឲ្យមានការព្យាបាលជាប្រចាំ។ ហេតុនេះករណីស្វាមីអ្នកស្រីមានបំណងលែងលះនោះ តុលាការនឹងយក ស្ថានភាពសុខភាពរបស់អ្នកស្រី **ដាលី** ជាមូលដ្ឋានក្នុងការកំណត់ចំណែកមួយច្រើនជាងស្វាមីរបស់អ្នកស្រី។

- **វិជ្ជាជីវៈ**

**ឧទាហរណ៍៖** លោក **តារា** គឺជាទន្តពេទ្យដែលមានឧបករណ៍បរិក្ខារពេទ្យទំនើបៗដើម្បីប្រកបវិជ្ជាជីវៈរបស់ខ្លួន អ្នកទាំងពីរពុំមានទ្រព្យអ្វីធំដុំគួរឲ្យកត់សម្គាល់ឡើយ។ ដូចនេះ ករណីដែលមានការលែងលះ តុលាការអាចបែងចែកទ្រព្យសម្បត្តិជាឧបករណ៍បរិក្ខារទំនើបៗនោះឲ្យទៅលោក

**តារា** ជាប្តី ហើយទ្រព្យសម្បត្តិផ្សេងៗទៀតទៅប្រពន្ធ ដែលនាំឲ្យប្តីទទួលបានចំណែកមួយច្រើនជាងប្រពន្ធរបស់ខ្លួន។

- **ប្រាក់ចំណូល**

**ឧទាហរណ៍៖** អ្នកស្រី **សុខុម** មានមុខរបរជានាយិកាប្រតិបត្តិក្រុមហ៊ុនអចលនវត្ថុមួយដែលមានតម្លៃរាប់លានដុល្លារ និងរកចំណូលបានសន្ធឹកសន្ធាប់ចូលក្នុងគ្រួសារតាមរយៈប្រាក់កម្រៃពីការងាររបស់គាត់។ អ្នកស្រីមានបំណងចង់លែងលះជាមួយស្វាមីអ្នកស្រី ក្រោយរស់នៅជាមួយគ្នាមិនចុះសម្រុង។ ដូចនេះ តុលាការអាចប្រើប្រាស់ហេតុផលខាងលើដើម្បីឲ្យអ្នកស្រី **សុខុម** បានចំណែកច្រើនជាងស្វាមីរបស់អ្នកស្រី។

- **លទ្ធភាពនៃការធ្វើការការងាររបស់ភាគីនីមួយៗ**

**ឧទាហរណ៍៖** លោក **ផល្លា** បានជួបនឹងគ្រោះថ្នាក់ចរាចរណ៍ជាហេតុធ្វើឲ្យលោកពិការ និងអលទ្ធភាពក្នុងការធ្វើការងារ។ ក្រោយមកលោក និងភរិយាមានបំណងចង់លែងលះក្រោយមានភាពប្រេះឆាគ្នាក្នុងជីវិតអាពាហ៍ពិពាហ៍ ដែលនាំឲ្យតុលាការយកស្ថានភាពរបស់លោក **ផល្លា** ធ្វើជាហេតុផលកំណត់បែងចែកឲ្យលោក **ផល្លា** ទទួលបានទ្រព្យមួយចំណែកច្រើនជាង ភរិយារបស់លោក។

- **ផលប្រយោជន៍របស់កូន**

**ឧទាហរណ៍៖** លោក **សីហា** ជាសហព័ទ្ធជាមួយអ្នកស្រី **កញ្ញា** បានរៀបអាពាហ៍ពិពាហ៍នាឆ្នាំ ២០០៩។ ក្រោយចំណងអាពាហ៍ពិពាហ៍អ្នកទាំងពីរសល់នូវទ្រព្យសម្បត្តិមួយចំនួន ដូចជា ម៉ូតូកង់បី ១គ្រឿង ដែលលោក **សីហា** ប្រើប្រាស់ក្នុងការប្រកបរបររត់ឌុប និងថវិកា ២០លានរៀល រួមទាំងកូនភ្លោះដែលជាអនីតិជនចំនួនពីរនាក់ មានអាយុ ៨ឆ្នាំ។ ក្រោយពេលលែងលះកូនៗទាំងពីរបានយល់ព្រមរស់នៅជាមួយឪពុករបស់ពួកគេ។ ដូចនេះផ្អែកតាមផលប្រយោជន៍របស់កូន តុលាការអាចប្រគល់ម៉ូតូកង់បីនោះឲ្យទៅលោក **សីហា** ដើម្បីប្រកបរបរចិញ្ចឹមកូនៗរបស់គាត់ ឬចំណែកលើសណាមួយនៃទ្រព្យសម្បត្តិដែលនៅសល់។

### ២.២.៥. អំពីអាហារកាតព្វកិច្ចរបស់សហព័ទ្ធ

អាហារកាតព្វកិច្ច ជាលក្ខខណ្ឌមួយយ៉ាងសំខាន់ក្នុងការរក្សាទ្រទ្រង់ កម្រិតជីវភាពរស់នៅរបស់សហព័ទ្ធម្ខាងណាម្នាក់ ឬកូនៗក្រោយពេលមានការបញ្ចប់ចំណងអាពាហ៍ពិពាហ៍។ ក្នុងនោះផងដែរ និយមន័យ និងលក្ខខណ្ឌនៃអាហារកាតព្វកិច្ចនឹងត្រូវលើកមកបង្ហាញនៅចំណុចសិក្សាខាងក្រោម៖

**២.២.៥.១. និយមន័យអាហារកាតព្វកិច្ច**

ត្បិតតែច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩ បាននិរាករណ៍ក្រោយការចូលជាធរមាន នៃក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧ ហើយក្តី ក៏នៅក្នុងច្បាប់នេះសល់មាត្រាមួយចំនួនដែលមិនទាន់ និរាករណ៍នោះគឺ ចំណុចមួយចំនួនទាក់ទងនឹងអាហារកាតព្វកិច្ច។[85] យ៉ាងណាមិញពាក្យវាក្យស័ព្ទក្នុងច្បាប់ចាស់ឆ្នាំ១៩៨៩ បានប្រើនូវពាក្យ "**អាហារកិច្ច**" ដែលមានភាពខុសគ្នាបន្តិចពីក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដែលបានប្រើនូវពាក្យវាក្យស័ព្ទ "អាហារកាតព្វកិច្ច"។

អនុលោមតាមសទ្ធានុក្រមផ្នែករដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានឲ្យនិយមន័យលើពាក្យ "**អាហារកាតព្វកិច្ច**" ថាជាកិច្ចដែលត្រូវបំពេញតាមច្បាប់ ឬតាមសេចក្តីសម្រេចរបស់តុលាការដែលតម្រូវឲ្យបុគ្គលម្នាក់ ឬច្រើននាក់ផ្តល់នូវប្រាក់ ឬទ្រព្យដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅដល់បុគ្គលផ្សេងទៀត ដែលមានទំនាក់ទំនងជាញាតិនឹងគ្នា។[86]

**២.២.៥.២. ទំហំ និងលំដាប់នៃជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច**

ញាតិ ក្លាយជាជនដែលត្រូវមាននូវករណីយកិច្ចត្រូវផ្គត់ផ្គត់អាហារកាតព្វកិច្ចតាមទំហំ និងលំដាប់ដូចជា[87]៖

ទី១ ញាតិដែលរស់នៅជាមួយគ្នា

ទី២ ញាតិលោហិតខ្សែផ្ទាល់

ទី៣ បងប្អូនបង្កើត

ទន្ទឹមនឹងជនដូចដែលបានរៀបរាប់ខាងលើ ក្នុងករណីពិសេសតុលាការក៏អាចឲ្យញាតិនៅក្នុងថ្នាក់ទី៣ ទទួលបន្ទុកត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចបានដែរ។ យ៉ាងណាមិញទោះបីជាអាពាហ៍ពិពាហ៍ត្រូវបានរលាយដោយសារមរណភាពរបស់សហព័ទ្ធម្ខាងក៏ដោយ ក៏ចំណុចខាងលើត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអាហារកាតព្វកិច្ចរវាងសហព័ទ្ធដែលនៅរស់ និងញាតិរបស់សហព័ទ្ធដែលបានទទួលមរណភាព។ រាល់ស្ថានភាពផ្លាស់ប្តូរទាំងឡាយ តុលាការអាចលុបចោលនូវសេចក្តីសម្រេចនោះបាន។

**២.២.៥.៣. អាហារកាតព្វកិច្ចក្រោយលែងលះ**

ក្នុងករណីលែងលះគ្នា សហព័ទ្ធដែលជាភាគីគ្មានកំហុសហើយខ្វះខាតអាចស្នើសុំអាហារកាតព្វកិច្ចពីភាគីម្ខាងទៀតបាន ហើយភាគីម្ខាងទៀតត្រូវជួយឧបត្ថម្ភទៅតាមលទ្ធភាពរបស់ខ្លួន។

---

[85] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខនស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១, មាត្រា៧៨។

[86] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, សទ្ធានុក្រមផ្នែករដ្ឋប្បវេណី, ទំព័រ២៨។

[87] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៤០ (កថាខណ្ឌ១)។

យ៉ាងណាមិញ កម្រិតអាហារកិច្ចនេះត្រូវសម្រេចតាមការយល់ព្រមរបស់គូភាគីទាំងសងខាង ឬ បើភាគីមិនឯកភាពគ្នាទេនោះ តុលាការនឹងចូលខ្លួនជាអ្នកសម្រេចសេចក្តី។ ទោះជាយ៉ាងណាក៏ដោយ បើសហព័ទ្ធដែលបានទទួលអាហារកាតព្វកិច្ចបានរៀបអាពាហ៍ពិពាហ៍ថ្មី ជននោះនឹងមិនមានសិទ្ធិទទួលអាហារកាតព្វកិច្ចទៀតដែរ។[88]

បន្ថែមពីនេះទៀតតុលាការក៏មានឆន្ទានុសិទ្ធិ ក្នុងការកែប្រែដោយមានការបង្កើន ឬ បន្ថយកម្រិតអាហារកាតព្វកិច្ចបានតាមសំណូមពររបស់ភាគីម្ខាងណាម្នាក់។ យ៉ាងណាមិញការបង្កើន ឬ បន្ថយកម្រិតអាហារកិច្ចនោះត្រូវធ្វើឡើងតាមលទ្ធភាពនៃភាគីដែលផ្តល់អាហារកាតព្វកិច្ច និងតាមសេចក្តីត្រូវការនៃភាគីដែលទទួលអាហារកាតព្វកិច្ច។ តម្លៃនៃអាហារកាតព្វកិច្ចនេះទៀតសោតត្រូវកំណត់ការផ្តល់ឲ្យជាសាច់ប្រាក់ ឬជារបស់។[89]

### ២.២.៥.៤. អាហារកាតព្វកិច្ចចំពោះសហព័ទ្ធ

គេសង្កេតឃើញមានរូបភាពពីរនៃការផ្តល់អាហារកាតព្វកិច្ចនោះគឺ តាមរយៈការព្រមព្រៀងរបស់គូភាគី ឬតាមផ្លូវតុលាការ។

➢ **អាហារកាតព្វកិច្ចករណីមានការព្រមព្រៀងគ្នា**

ឋានៈជាសហព័ទ្ធក៏នឹងត្រូវបានបញ្ចប់ស្របតាមផ្លូវច្បាប់ ក្រោយពីមានការបញ្ចប់នូវចំណងអាពាហ៍ពិពាហ៍ ឬលែងលះ។ ទោះបីជាយ៉ាងនេះក្តី ក៏អាហារកាតព្វកិច្ចដែលបានបំពេញក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ក៏អាចបន្តទៀតបានដែរក្រោយពីមានការលែងលះ។ ករណីនេះច្រើនកើតឡើងករណីដែលមានការលែងលះហើយ សហព័ទ្ធណាម្ខាងមានស្ថានភាពខ្វះខាតខាងផ្នែកជីវភាពបានស្នើសុំទៅតុលាការ ឲ្យសហព័ទ្ធម្ខាងទៀតដែលមានលទ្ធភាពល្អប្រសើរជាងខ្លួនផ្គត់ផ្គង់អាហារកាតព្វកិច្ចឲ្យខ្លួន។ យ៉ាងណាមិញអាហារកាតព្វកិច្ចនេះ នឹងត្រូវបានបញ្ចប់ក្រោយពីសហព័ទ្ធដែលទទួលបានការផ្គត់ផ្គង់បានរៀបអាពាហ៍ពិពាហ៍ថ្មី។

➢ **អាហារកាតព្វកិច្ចករណីគ្មានការព្រមព្រៀងគ្នា**

ជាគោលការណ៍ ការផ្តល់អាហារកាតព្វកិច្ចទៅកាន់សហព័ទ្ធដែលខ្វះខាត តុលាការអាចសម្រេចកែប្រែដោយបន្ថយ ឬ បន្ថែម ចំនួននៃការផ្តល់បាន តាមសំណូមពររបស់សហព័ទ្ធណាម្នាក់។ យ៉ាងណាមិញ ការសម្រេចសេចក្តីនេះក៏អាស្រ័យទៅតាមលទ្ធភាពរបស់សហព័ទ្ធដែលផ្គត់ផ្គង់ផងដែរ។ ករណីនេះ តុលាការមានភារៈកិច្ចក្នុងការស៊ើបអង្កេតឲ្យបានជាក់លាក់ពីចំណូលប្រចាំខែរបស់

---

[88] ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩,មាត្រា៧៦។

[89] ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩,មាត្រា៧៧។

សហាព័ទ្ធដែលជាអ្នកផ្ដត់ផ្គង់នោះ។ កង្វះខាតជាទូទៅដែលតុលាការយកមកធ្វើជាមូលដ្ឋានក្នុងការសម្រេចរួមមានជាអាទិ៍ សមត្ថភាពរកប្រាក់នៃសហាព័ទ្ធដែលទទួលបានការផ្គត់ផ្គង់ អាយុ សុខភាព និងកម្រិតជីវភាពជាទូទៅរបស់សហាព័ទ្ធនោះ។

### ២.២.៥.៥. កម្រិត ឬ របៀបនៃការផ្គត់ផ្គង់អាហារកាតព្វកិច្ច

ដោយឡែករបៀប ឬ កម្រិតនៃការផ្គត់ផ្គង់អាហារកាតព្វកិច្ចនេះត្រូវធ្វើឡើង ដោយការកំណត់របស់តុលាការ ដោយគិតពិចារណាទៅលើសេចក្តីត្រូវការចាំបាច់ក្នុងជីវភាពរស់នៅរបស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច លទ្ធភាពទ្រព្យធនរបស់ជន ដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច និងស្ថានភាពផ្សេងៗទៀតទាំងអស់។

### ២.២.៥.៦. ការផ្លាស់ប្តូរ ឬ លុបចោលទំនាក់ទំនងនៃអាហារកាតព្វកិច្ច

ប្រសិនបើមានស្ថានភាពផ្លាស់ប្តូរ ក្រោយពីបានពិភាក្សា ឬក្រោយពីមានការសម្រេចសេចក្តីចំពោះជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចជាក់លាក់ ឬជនដែលទទួលអាហារកាតព្វកិច្ចជាក់លាក់ ឬ កម្រិត ឬរបៀបនៃការផ្គត់ផ្គង់អាហារកាតព្វកិច្ចភាគី អាចផ្លាស់ប្តូរទំនាក់ទំនងនៃអាហារកាតព្វកិច្ចតាម រយៈការពិភាក្សាគ្នាបាន។ យ៉ាងណាមិញ បើការពិភាក្សាដែលបានកំណត់នោះ មិនបានសម្រេច ឬបើពុំអាចពិភាក្សាបានទេ ភាគីអាចធ្វើការទាមទារឲ្យតុលាការធ្វើការលុបចោល ឬ ផ្លាស់ប្តូរការពិភាក្សា ឬ ការសម្រេចសេចក្តីដែលធ្វើមុនបាន។ [90]

### ២.២.៥.៧. ការហាមឃាត់នូវការចាត់ចែងសិទ្ធិទាមទារអាហារកាតព្វកិច្ច

ភាគីជាម្ចាស់សិទ្ធដែលទទួលបាននូវអាហារកាតព្វកិច្ច ពុំអាចយកសិទ្ធិនោះមកធ្វើជាកម្មវត្ថុនៃអនុប្បទាន ប្រទានកម្ម ឬការបង្កើតសិទ្ធិប្រាតិភោគសម្រាប់តតិយជន ឬជំនួញផ្សេងៗទៀតបានឡើយ ដែលសិទ្ធិទាមទារអាហារកាតព្វកិច្ច គឺជាសិទ្ធិផ្តាច់មុខរបស់បុគ្គលដែលត្រូវការចាំបាច់នូវអាហារកាតព្វកិច្ច។[91]

### ២.២.៥.៨. អំពីអាហារកាតព្វកិច្ចចំពោះកូន

អាហាកាតព្វកិច្ច ចំពោះកូនពិតជាមានសារៈសំខាន់ណាស់ក្នុងការទ្រទ្រង់ជីវិតរស់នៅប្រចាំថ្ងៃរបស់កូនៗ និងឲ្យពួកគេទទួលបានការអប់រំទៅថ្ងៃមុខ ទោះសហាព័ទ្ធបានបញ្ចប់ចំណងអាពាហ៍ពិពាហ៍ក៏ដោយ។

[90] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ១១៨៣ កថាខណ្ឌ១ និង២។

[91] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ១១៨៥។

- **អាហារកាតព្វកិច្ចករណីមានការព្រមព្រៀងគ្នា**

ទោះបីជា សហព័ទ្ធដែលបានលែងលះគ្នាហើយក៏ដោយ ក៏ពួកគេមានកាតព្វកិច្ចក្នុងការចិញ្ចឹមបីបាច់ថែរក្សា ជួយផ្គត់ផ្គង់ ផ្តល់ជាសោហ៊ុយអប់រំ ដល់កូនៗរបស់ពួកគេទៅតាមលទ្ធភាពរបស់ខ្លួន។ ករណីដែលមិនមានការព្រមព្រៀងពីសំណាក់គូភាគីទេនោះ តុលាការអាចសម្រេចសេចក្តីឲ្យសហព័ទ្ធដែលមិនបានយកកូនទៅចិញ្ចឹម ធ្វើការបង់ជាអាហារកាតព្វកិច្ចដល់កូនៗរបស់គេ ការធ្វើបែបនេះជាគោលការណ៍ក្នុងការរក្សាទំនាក់ទំនងសហព័ទ្ធដែល មិនបាននៅជិតកូនកុំឲ្យឃ្លាតគ្នាឆ្ងាយពេក។[92]

- **អាហារកាតព្វកិច្ចករណីគ្មានការព្រមព្រៀងគ្នា**

បើគ្មានការព្រមព្រៀងណាមួយច្បាស់លាស់របស់សហព័ទ្ធ ក្រោយពេលលែងលះទេនោះ តុលាការត្រូវធ្វើការពិនិត្យលើស្ថានភាពជីវភាព និងប្រាក់ចំណូលរបស់សហព័ទ្ធ ហើយសេចក្តីសម្រេចរបស់តុលាការត្រូវស្របទៅតាមលទ្ធភាពរបស់គូភាគី និងត្រូវផ្តល់ឲ្យកូនៗរបស់ពួកគេរហូតដល់គ្រប់វ័យនីតិភាព។ ករណីដែល សហព័ទ្ធជាឪពុក ឬម្តាយដែលជាអ្នកមានអំណាចមេបា បានបំពានសិទ្ធិអំណាចក្នុងនាមជាអ្នកមានអំណាចមេបា ឬ ធ្វេសប្រហែសក្នុងការបំពេញករណីយកិច្ចរបស់ខ្លួន ដោយឲ្យកូនធ្លាក់ក្នុងភាពយ៉ាប់យឺន ឬ ពាលាអាវ៉ាសែ ឬ ដោយពុំបានគិតគូពីផលប្រយោជន៍របស់កូន ឬ ពុំបានអប់រំទូន្មានប្រៀនប្រដៅកូន ឬ ពុំបានផ្គត់ផ្គង់កូនក្នុងការទទួលបានការអប់រំ ឬ ការគ្រប់គ្រងរបស់អ្នកមានអំណាចមេបានោះ ធ្វើឲ្យប៉ះពាល់ដល់អនាគតកូន នោះអ្នកដែលមិនមានសិទ្ធិអំណាចមេបាលើកូន អាចដាក់ពាក្យបណ្តឹងទៅកាន់តុលាការស្នើសុំយកកូននោះមកចិញ្ចឹមវិញបាន។ តុលាការក៏អាចធ្វើការប្រកាសព្យួរ ឬ ដកហូតអំណាចមេបាតាមការស្នើសុំនោះបាន ឬ តាមការទាមទាររបស់ញាតិទាំង ៤ថ្នាក់របស់កូន មេឃុំ-ចៅសង្កាត់ នាយកនៃមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាព ឬ ដោយតំណាងអយ្យការបាន។[93]

### ២.២.៥.៩. ទណ្ឌកម្មនៃការមិនផ្គត់ផ្គង់អាហារកាតព្វកិច្ច

លក្ខណៈពិសេសនៃអាហារកាតព្វកិច្ចនោះ គឺការចងដោយចំណងគតិយុត្ត ពោលគឺជនទាំងឡាយ ដែលមិនបានបង់អាហារកាតព្វកិច្ចតាមសេចក្តីសម្រេចរបស់តុលាការទេនោះ នឹងត្រូវប្រឈមមុខ នឹងបទល្មើសព្រហ្មទណ្ឌ កាលបើរកឃើញភស្តុតាងបញ្ជាក់ថាជនដែលត្រូវផ្តល់អាហារកាតព្វកិច្ចនោះ មានភាពមិនស្មោះត្រង់។[94]

---

[92] ដូច៥០, ៦២។

[93] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៤៨។

[94] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារឆ្នាំ១៩៨៩, មាត្រា៧៨។

ករណីដែលសហព័ទ្ធដែលទទួលខុសត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច មិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនទៅតាមសេចក្តីសម្រេចរបស់តុលាការក្នុងអំឡុងពេល ២ខែយ៉ាងតិច ទៅឲ្យអតីតសហព័ទ្ធម្ខាងទៀតនោះ ឬ កូនជាអនីតិជន សហព័ទ្ធដែលជាប់កាតព្វកិច្ចនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែដល់ ១ឆ្នាំ និង ពិន័យជាប្រាក់ពី ១ សែនរៀល ដល់ ២ លានរៀល។[95]

## ២.២.៦. បញ្ហាចោទក្នុងការបែងចែកទ្រព្យសម្បត្តិក្រោយពេលលែងលះ

មានបញ្ហាចោទជាច្រើនដែលកើតមានឡើងសម្រាប់ភាគីសហព័ទ្ធ និងកូនៗរបស់ពួកគេដែលជាបញ្ហាប្រឈមទាក់ទងនឹងជីវភាពរស់នៅរបស់ពួកគេ។

### ២.២.៦.១. បញ្ហាចោទលើសហព័ន្ធ និងកូនៗ

ថ្វីបើសហព័ទ្ធអាចធ្វើការលែងលះដោយអនុវត្តទៅតាមនីតិវិធីច្បាប់ក៏ពិតមែន ប៉ុន្តែបញ្ហាចោទជាច្រើនដែលនាំឲ្យមានភាពស្មុគស្មាញសម្រាប់សហព័ទ្ធ។ តួយ៉ាងគម្លាតញាតិភាពរបស់សហព័ទ្ធ ជាមួយនឹងកូនៗរបស់ពួកគេ និងបញ្ហានៃការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធណាម្ខាង ឬការអនុវត្តរបស់អាហារកាតព្វកិច្ចជាដើម។ ការកំណត់អ្នកមានអំណាចមេបាពិតជាមានសារៈសំខាន់ណាស់ក្នុងការរក្សាជីវភាពរស់នៅរបស់កូននៃសហព័ទ្ធដែលបានលែងលះ តែបញ្ហាប្រឈមទាក់ទងនឹងអនាគត កង្វះខាតការអប់រំ និង បញ្ហាផ្លូវចិត្តរបស់កូនៗរមែងកើតមានឡើងក្រោយពេលឪពុកម្តាយរបស់ពួកគេបានលែងលះគ្នា។

### ២.២.៦.២. បញ្ហាចោទលើការអនុវត្តជាក់ស្តែង

ការអនុវត្តន៍នៃនីតិវិធីផ្លូវច្បាប់ទាក់ទងនឹងបញ្ហារឿងក្តីរដ្ឋប្បវេណី ត្រូវបានយកមកអនុវត្តន៍ដោយ អនុលោមតាមក្រមរដ្ឋប្បវេណី ជាច្បាប់សារធាតុ និងក្រមនីតិវិធីរដ្ឋប្បវេណី ដែលជាច្បាប់នីតិវិធីរួមនឹងច្បាប់ទាក់ទងមួយចំនួនទៀតផងដែរ។ យ៉ាងណាមិញភាគច្រើននៃច្បាប់ទាំងនេះ ត្រូវបានសង្កេតឃើញថាយកគំរូ និងកែសម្រួលតាមច្បាប់នៃប្រទេសជប៉ុនដែលជាប្រទេសជឿនលឿនមួយក្នុងតំបន់អាស៊ី ក៏ដូចជាក្នុងពិភពលោក។ បញ្ហាក្នុងការអនុវត្តជាក់ស្តែងនៅកម្ពុជាបានលេចឡើងទាក់ទងទៅនឹងស្ថានភាពសេដ្ឋកិច្ច វប្បធម៌ និងការយល់ដឹងរបស់ប្រជាជនកម្ពុជា ពោលគឺនៅមានកម្រិតនៅឡើយ។ ស្ថានភាពការយល់ដឹងលើបញ្ហាច្បាប់របស់ប្រជាជនពិតជាមានសារៈសំខាន់ណាស់ក្នុងដំណើរប្រព្រឹត្តទៅនៃច្បាប់។

ជាទូទៅក្នុងការរៀបចំអាពាហ៍ពិពាហ៍របស់ប្រជាជនកម្ពុជានៅតាមស្រុកស្រែចម្ការ ភាគច្រើន និងមួយចំនួននៅតាមទីប្រជុំជនតែងប្រារព្ធឡើង ទៅតាមប្រពៃណីទំនៀមទម្លាប់តែប៉ុណ្ណោះ

[95] ក្រមព្រហ្មទណ្ឌ, លេខនស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៣២៥។

ពេលគឺពុំបានបំពេញលក្ខខណ្ឌច្បាប់ដោយចុះសំបុត្រអាពាហ៍ពិពាហ៍នោះឡើយ។ វាមានភាពស្មុគស្មាញជាខ្លាំង ទៅដល់ឋានៈរបស់បុគ្គល ក្នុងនាមជាសហព័ទ្ធស្របច្បាប់ ជាពិសេសលើបញ្ហាមរតក។ បន្ថែមពីនេះទៀតការលែងលះបានក្លាយជាបញ្ហាចោទមួយ ដោយទាមទារឲ្យភាគីត្រូវចូលរួមសវនាការនៅឯតុលាការ ដែលផ្ទុយពីការរៀបអាពាហ៍ដែលត្រូវប្រព្រឹត្តទៅនៅឯមូលដ្ឋាន ឃុំ-សង្កាត់តែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀតតុលាការសាលាដំបូងមានតែនៅទីរួមខេត្ត ឯសាលាឧទ្ធរណ៍ និងតុលាការកំពូល មានតែមួយប៉ុណ្ណោះ ដែលជាហេតុបង្កឲ្យមានភាពលំបាក និងចុះសោហ៊ុយធ្វើដំណើរសម្រាប់ភាគីនៃវិវាទអាពាហ៍ពិពាហ៍ក្នុងការទទួលបាននូវភាពយុត្តិធម៌។

## ២.៣. អំពីការបាត់ខ្លួន

ការប្រកាសអំពីការបាត់ខ្លួននេះ ជាមូលហេតុចាំបាច់មួយសម្រាប់ធ្វើជាមូលដ្ឋានក្នុងការចាត់ចែងទ្រព្យសម្បត្តិក្នុងគ្រួសារ ដើម្បីធានាស្ថេរភាពនៃដំណើរប្រព្រឹត្តទៅក្នុងគ្រួសារ។ ក្នុងនោះមានលក្ខខណ្ឌ និងនីតិវិធីជាច្រើនដែលតម្រូវឲ្យសហព័ទ្ធគោរព និងអនុវត្តន៍តាម។

### ២.៣.១. លក្ខខណ្ឌនៃការប្រកាសអំពីការបាត់ខ្លួនជាទូទៅ

ករណីដែលបុគ្គល (អាចសហព័ទ្ធម្ខាង) ណាម្នាក់អវត្តមាននៅរស់ ឬទទួលមរណភាពក្នុងអំឡុងពេល ៥ឆ្នាំ នោះតុលាការអាចធ្វើការប្រកាសថាបុគ្គលនោះបានបាត់ខ្លួន។ យ៉ាងណាមិញការប្រកាសនោះទៀតសោតត្រូវធ្វើឡើងតាមពាក្យស្នើសុំរបស់សហព័ទ្ធ អ្នកដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាលឪពុកម្តាយ ឬអ្នកផ្សេងទៀត ដែលមានផលប្រយោជន៍សំខាន់តាមផ្លូវច្បាប់ដែលទាក់ទងនឹងការប្រកាសអំពីការបាត់ខ្លួននោះ។[96] ត្រង់ចំណុចនេះផ្លូវច្បាប់បានបញ្ញត្តិបង្ហាញពីអាទិភាពនៃសិទ្ធរបស់សហព័ទ្ធក្នុងការស្នើសុំប្រកាសអំពីការបាត់ខ្លួនរបស់សហព័ទ្ធម្ខាងទៀត។

### ២.៣.២. លក្ខខណ្ឌនៃការប្រកាសអំពីការបាត់ខ្លួនករណីពិសេស

យ៉ាងណាមិញករណីដែលបុគ្គលបានចូលក្នុងតំបន់ដែលមានសង្គ្រាម ឬមានវត្តមានក្នុងនាវាដែលបានលិច ឬបុគ្គលដែលបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងទៀតដែលអាចនាំឲ្យទទួលមរណភាព ហើយបុគ្គលទាំងនោះពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាពក្នុងកំឡុងពេលត្រឹមតែ ១ ឆ្នាំប៉ុណ្ណោះ ក្រោយពីចប់សង្គ្រាម ក្រោយពីនាវាបានលិច ឬក្រោយពីគ្រោះថ្នាក់ផ្សេងទៀតនោះ បានកន្លងផុតទៅ បុគ្គលទាំងនោះក៏ស្ថិតក្នុងលក្ខខណ្ឌនៃការប្រកាសបាត់ខ្លួនផងដែរ។[97]

[96] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៤១ កថាខណ្ឌ១។

[97] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៤១ កថាខណ្ឌ២។

### ២.៣.៣. ការដាស់តឿនជាសាធារណៈ

ទន្ទឹមនឹងការចូលលក្ខខណ្ឌទាំងឡាយខាងលើ ការប្រកាសអំពីការបាត់ខ្លួននេះដាច់ខាតអាចប្រព្រឹត្តទៅបានដោយឆ្លងកាត់នូវនីតិវិធីនៃការដាស់តឿនជាសាធារណៈ។[98] ចំណុចនេះបានន័យថា ករណីបុគ្គលណាម្នាក់ត្រូវបានធ្វើការប្រកាសបាត់ខ្លួនហើយ មិនបានផ្សព្វផ្សាយជាសាធារណៈនោះការប្រកាសស្តីពីការប្រកាសបាត់ខ្លួននោះក៏គ្មានអានុភាពដែរ។

### ២.៣.៤. អានុភាពនៃការប្រកាសអំពីការបាត់ខ្លួន

អានុភាពនៃការប្រកាសបាត់ខ្លួនពិតជាមានភាពទាក់ទងជាចំបាច់ ទៅដល់ទំនាក់ទំនងនៃចំណងគតិយុត្តសម្រាប់ភាគីសហព័ទ្ធ(២.៣.៤.១) និងសិទ្ធិលើការគ្រប់គ្រងលើទ្រព្យសម្បត្តិ (២.៣.៤.២) ជាដើម។

#### ២.៣.៤.១. អានុភាពចំពោះទំនាក់ទំនងគតិយុត្ត

រាល់បុគ្គលទាំងឡាយណាដែលបានប្រកាសពីការបាត់ខ្លួនហើយ ដោយមិនដឹងថាបុគ្គលដែលអវត្តមាននោះ បានទទួលមរណភាព ឬនៅរស់ តាមការកំណត់ខាងលើនោះ ដោយផុតវេលាកំណត់ភ្ជាប់ដោយលក្ខខណ្ឌដែលមានរយៈពេល ១ ឬ ៥ ឆ្នាំនោះ បានកន្លងផុតទៅ អ្នកដែលត្រូវបានប្រកាសថាបានបាត់ខ្លួននោះ ត្រូវបានចាត់ទុកថាបានទទួលមរណភាព។ ការកំណត់នេះធ្វើឡើង តែចំពោះទំនាក់ទំនងនៃគតិយុត្តជុំវិញលំនៅឋាន ឬ ទីសំណាក់កន្លងមករហូតដល់ពេលនោះ។[99] ក្នុងនោះអានុភាពនៃការប្រកាសអំពីការបាត់ខ្លួនក៏មានអានុភាពដល់ការរលត់សិទ្ធិ និងកាតព្វកិច្ចរវាងសហព័ទ្ធ ដែលអាចបើកផ្លូវឲ្យសហព័ទ្ធម្ខាងទៀតរៀបអាពាហ៍ពិពាហ៍ថ្មីបាន។

បន្ថែមពីលើនេះទៀតករណីដែលសហព័ទ្ធម្ខាងបានប្រកាសពីការបាត់ខ្លួនជាស្ថាពរ ដោយតុលាការហើយនោះ ហើយសហព័ទ្ធម្ខាងទៀតបានរៀបអាពាហ៍ពិពាហ៍ជាថ្មី ទោះជាមានការវិលត្រឡប់មកក្រោយពេលការប្រកាសបាត់ខ្លួននោះ ក៏ដោយក៏អានុភាពនៃអាពាហ៍ពិពាហ៍ថ្មីមិនត្រូវបានរលាយឡើយ។ គេអាចនិយាយបានម៉្យាងទៀតបានថា អាពាហ៍ពិពាហ៍មុនជាមួយនឹង សហព័ទ្ធដែលត្រូវបានតុលាការធ្វើការប្រកាសអំពីការបាត់ខ្លួនជាស្ថាពរនោះ នឹងត្រូវរលាយជាស្ថាពរដោយអាពាហ៍ពិពាហ៍ថ្មីរបស់សហព័ទ្ធ។[100]

---

[98] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៤២។

[99] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧,មាត្រា៤៣។

[100] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៤៤ (កថាខណ្ឌ៤)។

### ២.៣.៤.២. អានុភាពចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ

ករណីដែលសហព័ទ្ធណាម្ខាង ត្រូវបានតុលាការចេញដីការសម្រេចអំពីការប្រកាសបាត់ខ្លួន ហើយនោះ សហព័ទ្ធនោះត្រូវបានសន្មតថាបានទទួលមរណភាព។ ដូចគ្នានេះផងដែរ ផ្លូវច្បាប់បាន បើកឲ្យមានការចូលអន្តរាគមន៍នៅក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិគ្រួសារនោះគឺ ការអនុវត្តតាមបទ ប្បញ្ញត្តិនៃសន្តតិកម្មដែលនឹងមានរៀបរាប់ខាងក្រោម។ ដូចនេះសហព័ទ្ធម្ខាងទៀតដែលជាប្តី ឬ ប្រពន្ធនឹងទទួលបានសិទ្ធិ និងកាតព្វកិច្ចតាមផ្លូវច្បាប់ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិក្នុងគ្រួសារ ក៏ដូច ជាគ្រប់គ្រងមួយចំណែកទៀតតាមផ្លូវច្បាប់នៃទ្រព្យសម្បត្តិរបស់សហព័ទ្ធដែលត្រូវបានប្រកាសអំពី ការបាត់ខ្លួន។

ទោះបីជាបុគ្គលដែលត្រូវបានប្រកាសជាស្ថាពរអំពីការបាត់ខ្លួន បានត្រឡប់មកវិញក៏ដោយ ក៏បុគ្គលដែលទទួលបានទ្រព្យសម្បត្តិដោយចំពោះ ដោយសារអានុភាពនៃការប្រកាសអំពីការបាត់ ខ្លួនរួមទាំងមិនបានដឹងថាការប្រកាសបាត់ខ្លួននោះផ្ទុយពីការពិត នោះបុគ្គលដែលទទួលបានទ្រព្យ សម្បត្តិនោះត្រូវមានករណីយកិច្ចសងត្រឹមតែកម្រិតនៃផលប្រយោជន៍តែប៉ុណ្ណោះ។[101] ចំណុចនេះ ចង់សំដៅដល់បុគ្គលដែលបានទទួលទ្រព្យសម្បត្តិតាមចំណែកមរតក ពីបុគ្គលដែលត្រូវបាន ប្រកាសពីការបាត់ខ្លួនអាចប្រើប្រាស់ ឬចាត់ចែងលើទ្រព្យសម្បត្តិមរតកទាំងនោះបាន ទៅតាមតម្រូវ ការជាក់ស្តែងជាចាំបាច់។

ប៉ុន្តែការដែលត្រឡប់មកវិញរបស់បុគ្គលដែលត្រូវបានប្រកាសបាត់ខ្លួននោះ ជាហេតុធ្វើឲ្យ បុគ្គលដែលទទួលបានប្រយោជន៍នោះសងត្រឹមភាគនៃទ្រព្យសម្បត្តិដែលនៅសល់ប៉ុណ្ណោះ។ ករណីដែលភាគនៃទ្រព្យសម្បត្តិបានទទួលនោះអស់ហើយ ភាគីដែទទួលបានសិទ្ធិគ្រប់គ្រងលើ ទ្រព្យសម្បត្តិនោះ ត្រូវសងត្រឹមតែភាគដែលបានប្រើសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃប៉ុណ្ណោះ ដោយ គិតថាភាគដែលខ្លួនបានជៀសវាងក្នុងការចំណាយទ្រព្យរបស់ខ្លួន គឺដោយសារយកទ្រព្យសម្បត្តិ ដែលខ្លួនបានទទួលមកចំណាយជំនួស ជាភាគដែលខ្លួននៅតែបានទទួលផលប្រយោជន៍។[102]

វាពិតជាមានសារៈសំខាន់ណាស់ក្នុងការកំណត់អ្នក ដែលមានសិទ្ធិចាត់ចែងលើទ្រព្យ សម្បត្តិរបស់សហព័ទ្ធក្រោយពីបានប្រកាសជាស្ថាពរស្តីពីការបាត់ខ្លួន។ ម្យ៉ាងទៀតវាក៏ជា ប្រយោជន៍សម្រាប់ តតិយជនជាម្ចាស់បំណុលផងដែរ ក្នុងការទទួលបាននូវសិទ្ធិរបស់ខ្លួនក្នុងនាម ជាម្ចាស់បំណុល ដើម្បីទទួលបាននូវដំណោះស្រាយមួយសមរម្យ ពោលគឺកាតព្វកិច្ចសាមគ្គីរបស់ សហព័ទ្ធ ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន។

---

101 ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៩ (កថាខណ្ឌ២)។

102 ក្រសួងយុត្តិធម៌, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ១៖៣៧-៣៨។

**ឧទាហរណ៍៖** លោក **ប្រាជ្ញា** បានបាត់ខ្លួនក្រោយពីបំពេញបេសកកម្មនៅឯប្រទេសកូរ៉េ ដោយលោកបានជិះលើសាឡាងដែលបានលិច ដោយមិនដឹងថាស្លាប់ ឬរស់ ពោលគឺបាត់ដំណឹងអស់រយៈពេល ជាងមួយឆ្នាំមកហើយ។ ដូចនេះលោកស្រី **ប្រសិទ្ធិ** ដែលជាសហព័ទ្ធអាចដាក់ពាក្យស្នើសុំតុលាការ ដើម្បីសេចក្តីសម្រេចប្រកាសអំពីការបាត់ខ្លួនលោក **ប្រាជ្ញា** ជាប្តី។ ទន្ទឹមនឹងនេះ លោកស្រី ប្រសិទ្ធិ អាចធ្វើការចាត់ចែង ឬប្រើប្រាស់នូវទ្រព្យសម្បត្តិរួមសហព័ទ្ធទៅតាមតម្រូវការជាក់ស្តែងក្នុងគ្រួសារដោយផ្អែកតាមគោលការណ៍សុចរិត និងស្មោះត្រង់។

## ២.៤. អំពីមរណភាពរបស់សហព័ទ្ធ

មរណភាពរបស់សហព័ទ្ធណាម្នាក់ គឺជាលក្ខខណ្ឌដ៏ចាំបាច់មួយក្នុងការចាប់ផ្តើមបើកសន្តតិកម្មរបស់បុគ្គលនោះ។

### ២.៤.១. និយមន័យសន្តតិកម្ម និង សន្តតិជន

**សន្តតិកម្ម** សំដៅដល់ការផ្ទេរនូវសិទ្ធ និងករណីយកិច្ចរបស់មតកជនទៅឲ្យសន្តតិជនម្នាក់ ឬច្រើនអ្នកតាមរយៈឆន្ទៈ ឬតាមផ្លូវច្បាប់។[103] ចំណែកឯពាក្យ **សន្តតិជន** សំដៅដល់ ជនទាំងឡាយដែលទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនតាមរយៈសន្តតិជន។[104]

### ២.៤.២. ប្រភេទសន្តតិកម្ម

ប្រភេទសន្តតិកម្មត្រូវបានបែងចែកជាពីរគឺ សន្តតិកម្មតាមច្បាប់(២.៤.២.១) និងសន្តតិកម្មតាមមតកសាសន៍(២.៤.២.២)។

#### ២.៤.២.១. សន្តតិកម្មតាមច្បាប់

សន្តតិកម្មតាមច្បាប់សំដៅលើ សន្តតិកម្មដែលផ្តល់ឲ្យសន្តតិជនដោយពុំមានការរៀបចំជាលិខិតយថាភូត លិខិតសម្ងាត់ ឬលិខិតឯកជនជាអាទិ៍ ដោយមតកជន និងពុំមានការចូលរួមពីសារការី ឬសាក្សីឡើយ។ សន្តតិកម្មតាមច្បាប់នេះ សំដៅដល់ការយកបទប្បញ្ញត្តិដែលចែងក្នុងច្បាប់ជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា មកអន្តរាគមន៍ក្នុងការយកមកធ្វើជាមូលដ្ឋានក្នុងការបែងចែកទ្រព្យមរតកដល់សន្តតិជន។

#### ២.៤.២.២. សន្តតិកម្មតាមមតកសាសន៍

សន្តតិកម្មតាមមតកសាសន៍សំដៅដល់ សន្តតិកម្មដែលធ្វើឡើងដោយឆន្ទៈមតកជន ក្នុងការផ្តល់ទ្រព្យជាមកឲ្យសន្តតិជន ឬតតិយជនជាដើម។ យ៉ាងណាមិញបុគ្គលដែលអាចធ្វើមតកសាសន៍

[103] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, សន្ទានុក្រមផ្នែករដ្ឋប្បវេណី លេខ១៤៣។

[104] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, សន្ទានុក្រម លេខ១៤៤។

បានដាច់ខាតត្រូវតែជានីតិជន ឬ អនីតិជនដែលទទួលបានអត្តាធីនភាពរួចផុតពីរបបអាណាព្យាបាលសម្រាប់អនីតិជន ដែលម្ចាស់បណ្តាំនោះ ត្រូវមានសមត្ថភាពគ្រប់គ្រាន់នៅពេលធ្វើមតកសាសន៍។[105] សន្តតិកម្មតាមមតកសាសន៍ទាមទារឲ្យមានលក្ខខណ្ឌទម្រង់ជាចាំបាច់ដើម្បីឲ្យមានសុពលភាព។ រាល់មតកសាសន៍ដែលគ្មានការចុះកាលបរិច្ឆេទ ត្រូវចាត់ទុកថាមានសុពលភាពលុះត្រាតែមតកសាសន៍នោះ មិនផ្ទុយនឹងមតកសាសន៍ផ្សេងទៀតដែលបានធ្វើដោយម្ចាស់បណ្តាំដូចគ្នានេះ។ តែបើករណីមតកសាសន៍ដែលគ្មានការចុះកាលបរិច្ឆេទ មានចំនួនច្រើននឹងមានខ្លឹមសារផ្ទុយគ្នា នោះអានុភាពនៃមតកសាសន៍នោះនឹងត្រូវកាត់បន្ថយគ្នា។[106]

### ➢ មតកសាសន៍ដោយលិខិតយថាភូត

ចំណែកឯមតកសាសន៍ដែលធ្វើឡើងដោយលិខិតយថាភូត តម្រូវឲ្យធ្វើឡើងដោយម្ចាស់បណ្តាំ នៅចំពោះមុខសារការី រួមជាមួយវត្តមានសាក្សីយ៉ាងតិច ២ រូប ដែលម្ចាស់បណ្តាំត្រូវប្រាប់ដោយផ្ទាល់មាត់នូវខ្លឹមសារនៃមតកសាសន៍នោះនៅចំពោះមុខសារការី។ ក្រោយមកសារការីត្រូវសរសេរនូវ អត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំជាលាយល័ក្ខណ៍អក្សរ ហើយត្រូវសូត្រឲ្យម្ចាស់បណ្តាំ និងសាក្សីចូលរួមស្តាប់។ ក្រោយពិនិត្យឃើញពីភាពត្រឹមត្រូវទាំងអស់នៃមតកសាសន៍នោះហើយ គ្រប់ភាគីពាក់ព័ន្ធ និងសារការីត្រូវចុះហត្ថលេខា រួមទាំងសរសេរ ថ្ងៃ ខែ ឆ្នាំលើមតកសាសន៍នោះផងដែរ។[107]

### ➢ មតកសាសន៍ដោយលិខិតឯកជន

មតកសាសន៍ដោយលិខិតឯកជននេះជាមតកសាសន៍ ដែលធ្វើឡើងដោយម្ចាស់បណ្តាំសរសេរពាក្យបណ្តាំទាំងអស់ និងចុះកាលបរិច្ឆេទ ដោយខ្លួនឯង រួមទាំងមានហត្ថលេខាលើលិខិតនោះផងដែរ។ ករណីដែលលិខិតមតកសាសន៍ដោយលិខិតឯកជននេះត្រូវបានអ្នកដទៃសរសេរ ឬសរសេរដោយប្រើប្រាស់ម៉ាស៊ីន ដូចជាអង្គុលីលេខ ជាអាទិ៍ ឬ មានការលុប ឬ ការបន្ថែម ឬ ការកែប្រែផ្សេងទៀតនៅក្នុងលិខិតនោះ (ករណីដែលម្ចាស់បណ្តាំពុំបានបង្ហាញនូវកន្លែងហើយសរសេរបន្ថែមនូវមូលហេតុនៃការកែប្រែនោះ ឬ មិនបានចុះហត្ថលេខា) នឹងត្រូវចាត់ទុកជាមោឃៈ និងពុំមានអានុភាពឡើយ ។[108]

---

[105] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៦៨ កថាខណ្ឌ១ និងមាត្រា១១៦៩ កថាខណ្ឌ១។

[106] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧០ កថាខណ្ឌ២។

[107] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៣។

[108] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៤ ។

➤ **មតកសាសន៍ដោយលិខិតសម្ងាត់**

មតកសាសន៍ដោយលិខិតសម្ងាត់នេះត្រូវធ្វើឡើងតាមទម្រង់ដូចជា[109]៖

- ការចុះហត្ថលេខារបស់ម្ចាស់បណ្តាំលើលិខិតនោះ
- ម្ចាស់បណ្តាំដាក់លិខិតក្នុងស្រោមបិទជិត ដោយមានចុះហត្ថលេខា ឬ សរសេរសញ្ញាសម្គាល់ ឬ មធ្យោបាយផ្សេងទៀតដែលអាចវិនិច្ឆ័យបានអំពីការបានបើក ឬ មិនបានបើកស្រោមលិខិតនោះ នៅមាត់ស្រោមលិខិតនោះ
- ម្ចាស់បណ្តាំបានដាក់នូវលិខិតបិទជិត នៅចំពោះមុខសារការីម្នាក់ រួមទាំងសាក្សី ២ នាក់ រួមទាំងធ្វើសេចក្តីថ្លែងការណ៍ថា លិខិតនេះជាលិខិតមតកសាសន៍របស់ខ្លួន ហើយបើមានជនណាម្នាក់ក្រៅពីខ្លួនបានសរសេរ ត្រូវធ្វើសេចក្តីថ្លែងការអំពីឈ្មោះ និង លំនៅឋានរបស់ជនដែលបានសរសេរនោះ
- សារការីត្រូវចុះ ថ្ងៃ ខែ ឆ្នាំ ដែលសាមីខ្លួនបានដាក់លិខិតនោះ និងសរសេរសេចក្តីថ្លែងការណ៍របស់ម្ចាស់បណ្តាំ នៅលើលិខិតបិទជិតនោះ និងចុះហត្ថលេខាជាមួយគ្នានឹងសាក្សី និងម្ចាស់បណ្តាំ។

## ២.៤.៣. សិទ្ធិ និងករណីយកិច្ចរបស់សហព័ទ្ធដែលបានទទួលក្រោយមរណភាពរបស់សហព័ទ្ធម្ខាងទៀត

ការបញ្ចប់អាពាហ៍ពិពាហ៍ក៏អាចធ្វើទៅបានដោយមិនមានពាក្យបណ្តឹងពីភាគី(សហព័ទ្ធ) ក៏បានដែរ នោះគឺតាមរយៈមរណភាពរបស់សហព័ទ្ធម្ខាងណាម្នាក់។ អ្វីដែលជាគោលការណ៍ច្បាប់ក្នុងចំណងអាពាហ៍ពិពាហ៍ គឺការស្ម័គ្រចិត្តរួមរស់នៅជាមួយគ្នារវាងបុរស និងនារី។ ហេតុនេះហើយមិនមានមូលហេតុណាមួយជាគោលការណ៍គតិយុត្ត ដែលជាហេតុនាំឲ្យមានសុពលភាពនៃចំណងអាពាហ៍ពិពាហ៍ទៀតដែរ កាលបើមានភាគីណាម្នាក់ទទួលមរណភាព។

យ៉ាងណាមិញចំណុចនៃការបាត់ខ្លួនខាងលើ ក៏ត្រូវបានផ្លូវច្បាប់សន្មតចូលលក្ខខណ្ឌការទទួលមរណភាពផងដែរ។ ករណីដែលមានមរណភាព ឬការបាត់ខ្លួនរបស់សហព័ទ្ធណាម្នាក់នោះ មូលហេតុនៃការបញ្ចប់នូវចំណងអាពាហ៍ពិពាហ៍ត្រូវបានកើតឡើង ដែលនាំឲ្យមានការបញ្ចប់នូវប្រព័ន្ធនៃការគ្រប់គ្រងទ្រព្យសម្បត្តិផងដែរ។ មរណភាព ឬ ការបាត់ខ្លួនរបស់សហព័ទ្ធបានក្លាយទៅជាមូលហេតុមួយក្នុងការបែងចែកទ្រព្យសម្បត្តិរួម និងទ្រព្យសម្បត្តិដោយឡែក។ បន្ថែមពីនេះទៀត

[109] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៧៥ កថាខណ្ឌ១។

ការបើកសន្តតិកម្មរបស់សហព័ទ្ធត្រូវបានចាប់ផ្តើមឡើងក្រោយមរណភាពរបស់មតកជនដែលមាន ពីរប្រភេទ គឺសន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមបណ្តាំ។

### ២.៤.៣.១. សន្តតិកម្មរបស់សហព័ទ្ធ

សហព័ទ្ធរបស់មរតជន ត្រូវបានផ្លូវច្បាប់កំណត់ឲ្យក្លាយជាសន្តតិជនជានិច្ច។[110] ចំណុចត្រង់នេះ ផ្លូវច្បាប់បានផ្តល់អាទិភាពជាដាច់ខាតឲ្យសហព័ទ្ធរបស់សន្តតិជន ទទួលបាននូវចំណែកទ្រព្យសម្បត្តិរបស់សន្តតិជនជាសហព័ទ្ធរបស់ខ្លួន។ តែបើនិយាយត្រឡប់ថយក្រោយមកវិញ សម្រាប់សហព័ទ្ធ ក្នុងការចុះបញ្ជីអាពាហ៍ពិពាហ៍ គឺពិតជាមានសារៈសំខាន់ណាស់ក្នុងការកំណត់នូវឋានៈមួយយ៉ាងជាក់លាក់ ពោលគឺជាសហព័ទ្ធស្របតាមផ្លូវច្បាប់ និងមានតែមួយគត់។[111] បន្ថែមពីនេះទៀត ករណីមានបុគ្គលដទៃទៀត ក្រៅពីសហព័ទ្ធត្រូវជាសន្តតិជនដែរនោះ សហព័ទ្ធត្រូវមានលំដាប់ស្មើគ្នានឹងលំដាប់នៃបុគ្គលនោះ។[112]

### ២.៤.៣.២. ចំណែកនៃមរតករបស់សហព័ទ្ធជាមួយញាតិរបស់សហព័ទ្ធម្ខាងទៀត

➢ **ករណីដែលមានតែសហព័ទ្ធ និងបច្ឆាញាតិផ្ទាល់ជាសន្តតិជន**

ករណីដែលមតកជនមានតែសហព័ទ្ធ និងបច្ឆាញាតិផ្ទាល់ (កូន) ជាសន្តតិជននោះសហព័ទ្ធ និង កូនៗនីមួយៗរបស់មតកជន នឹងត្រូវបានទទួលចំណែកមតិកស្មើៗគ្នា។ ការផ្តល់ចំណែកមរតកឲ្យស្មើគ្នារវាងសហព័ទ្ធ និងកូនៗរបស់មតកជនបានបង្ហាញពីតម្លៃនៃសហព័ទ្ធដែលបានចូលរួមទាំងសិទ្ធិ និងកាតព្វកិច្ចក្នុងការទ្រទ្រង់ថែរក្សានូវជីវភាពគ្រួសារទាំងមូល។[113]

**ឧទាហរណ៍៖** លោក **ក** មានលោកស្រី **ខ** ជាសហព័ទ្ធ និង កូន ៣ នាក់ **គ ឃ** និង **ខ**។ ដូចនេះ មរតកដែល លោកស្រី **ខ** និង កូនទាំងបី **គ ឃ** និង **ខ** ទទួលបានគឺ ១ភាគ៤ នៃចំណែកមរតកសរុបរបស់លោក **ក**។

➢ **ករណីដែលមានតែសហព័ទ្ធ ឪពុក និងម្តាយជាសន្តតិជន**

ករណីពិសេសមួយទៀតដែលសន្តតិជនមានតែ សហព័ទ្ធ ឪពុក និងម្តាយរបស់មតកជនជាសន្តតិជន នោះចំណែកមរតករបស់សន្តតិជនត្រូវជា ១ភាគ៣ និង ២ភាគ៣ ទៀតជារបស់ឪពុក

---

[110] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៦១ កថាខណ្ឌ១។

[111] ច្បាប់ស្តីពីឯកពន្ធភាពឆ្នាំ២០០៦, មាត្រា៣ វាក្យខណ្ឌ១។

[112] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៦១ កថាខណ្ឌ២។

[113] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៦២ កថាខណ្ឌ(ក)។

ម្តាយរបស់សន្តតិជន។ ប៉ុន្តែ ករណីដែលមតកជនមានតែឪពុក ឬ ម្តាយនោះ ឪពុក ឬ ម្តាយ និង សហព័ទ្ធនោះទទួលបានចំណែកមរតកស្មើៗគ្នា។

**ឧទាហរណ៍៖** លោក **ក** មានលោកស្រី **ខ** ជាសហព័ទ្ធ ឪពុក **គ** និងម្តាយ **ឃ**។ ដូចនេះ មរតកដែល លោកស្រី **ខ** នឹងទទួលបានគឺ ១ភាគ៣ នៃចំណែកមរតកសរុបរបស់លោក **ក**។ ចំណែកឯឪពុក **គ** និងម្តាយ **ឃ** ទទួលបានគឺ ២ភាគ៣ ។ ប៉ុន្តែបើលោក **ក** មានលោកស្រី **ខ** ជាសហព័ទ្ធ និងឪពុក **គ** (ម្តាយ **ឃ** បានស្លាប់មុនមតកជន) ឬ ម្តាយ **ឃ** (ឪពុក **គ** បានស្លាប់មុនមតកជន) នោះចំណែកមរតកអ្នកទាំងសហព័ទ្ធ និងឪពុក ឬ ម្តាយ (ដែលនៅរស់) នឹងទទួលបានចំណែកមរតកស្មើៗគ្នា។[114]

❖ **ករណីដែលមានតែសហព័ទ្ធ និងបុព្វញាតិផ្ទាល់ក្រៅពីឪពុក ម្តាយរបស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសបុគ្គលទាំងនោះជាសន្តតិជន**

លក្ខណៈពិសេសត្រង់ចំណុចនេះបានផ្តល់អទិភាពជាសំខាន់ដល់សហព័ទ្ធ ក្នុងការទទួលបានចំណែកមរតក ខណៈដែលមតកជនពុំមានសន្តតិជនជាកូន ឬ ឪពុក ម្តាយ ដោយផ្តល់ឲ្យសហព័ទ្ធនូវចំណែក ១ភាគ២ នៃទ្រព្យសម្បត្តិសរុបរបស់មតកជន។ ចំណែកឯ បុព្វញាតិផ្ទាល់ក្រៅពីឪពុក ម្តាយរបស់មតកជន ឬ បងប្អូនបង្កើតរបស់មតកជន ឬ អ្នកទទួលសន្តតិកម្មជំនួសបុគ្គលទាំងនោះជា សន្តតិជននោះ ពួកគេនឹងទទួលបានចំណែកមរតកត្រឹមកម្រិត ១ភាគ២ នៃទ្រព្យសម្បត្តិមរតកសរុបតែប៉ុណ្ណោះ។[115]

**ឧទាហរណ៍៖** លោក **ក** មានលោកស្រី **ខ** ជាសហព័ទ្ធ និង ប្អូនស្រីបង្កើតចំនួន ៣ នាក់ **គ ឃ** និង **ង**។ ត្រង់បញ្ញត្តិនេះបានកំណត់ផ្តល់ចំណែកមរតក ១ភាគ២ ឲ្យទៅសហព័ទ្ធលោកស្រី **ខ** និងសល់ចំណែក ១ភាគ២ ទៀតជារបស់សហសន្តតិជន៣អ្នកផ្សេងទៀតជាប្អូនស្រីបង្កើតលោក **ក** តាមសមាមាត្រស្មើៗគ្នានៃទ្រព្យសម្បត្តិមរតកសរុបដែលនៅ។

### ២.៤.៣.៣. សិទ្ធិនៃចំណែកមរតករបស់សហព័ទ្ធក្នុងភាគបម្រុង

ភាគបម្រុង គឺជារបបធានាមួយផ្នែកនៃចំណែកមតិកដែលកំណត់ដោយច្បាប់ ចំពោះសន្តតិ-ជនដែលកំណត់ដោយច្បាប់។ ថ្វីត្បិតតែមតជន មានសេរីភាពក្នុងការធ្វើមតកសាសន៍ក៏ដោយ ក៏របបនៃភាគបម្រុងនេះអាចអនុញ្ញាតឲ្យសន្តតិជនដែលកំណត់ដោយច្បាប់ ធ្វើការបដិសេធនូវសេរីភាពមួយនេះបាន។[116] លក្ខខណ្ឌនៃការកំណត់ភាគបម្រុង ត្រូវគណនាដោយយកទ្រព្យសម្បត្តិ

114 ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៦២ កថាខណ្ឌ(ខ)។

115 ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៦២ កថាខណ្ឌ(គ)។

116 ក្រសួងយុត្តិធម៌, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី* (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០០៩), ៦៖៨៨។

ដែលមតកជនមាននៅពេលចាប់ផ្តើមធ្វើសន្តតិកម្ម បូកតម្លៃនៃផលប្រយោជន៍ពិសេស (ចំណែកមតិករបស់អ្នកដែលបានទទួលផលប្រយោជន៍ពិសេស) និងតម្លៃនៃទ្រព្យសម្បត្តិប្រទានកម្ម (ប្រទានកម្មដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង) ហើយដកចំនួនប្រាក់សរុបនៃកាតព្វកិច្ចចេញ។[117]

ក្រៅពីសិទ្ធិដែលមានលើចំណែកនៃទ្រព្យរួម ទ្រព្យដោយឡែក និងទ្រព្យជាមរតក ដើម្បីជាកិច្ចការពារផលប្រយោជន៍ដល់ការរក្សាជីវភាពរស់នៅរបស់សហព័ទ្ធ ផ្លូវច្បាប់នៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់នូវការធានាសិទ្ធិទទួលបានប្រយោជន៍មួយទៀតនោះ គឺផ្នែកនៃភាគបម្រុង។

តួយ៉ាងបច្ឆាញាតិផ្ទាល់ ឬឪពុកម្តាយ ឬជីដូនជីតា និងសហព័ទ្ធរបស់មតកជនអាចធ្វើនូវលទ្ធកម្មនៃទ្រព្យសម្បត្តិដែលអាចនឹងទទួលបាន មួយភាគបី នៃទ្រព្យរបស់មតកជន។ ករណីដែលសន្តតិជនមានតែ ឪពុកម្តាយ ឬជីដូនជីតាតែប៉ុណ្ណោះ ឬទទួលបាន មួយភាគពីរ ក្នុងករណីផ្សេងពីករណីខាងលើ។[118] បន្ថែមពីនេះទៀតករណីអ្នកមានសិទ្ធិលើភាគបម្រុងមានចំនួនច្រើនអ្នក ដែលជាហេតុនាំឲ្យពួកគេនឹងទទួលបានចំណែកតាមសមាមាត្រនៃចំនួនសន្តតិជនដែលមានចំណែកលើភាគបម្រុង។[119]

**ឧទាហរណ៍៖** ក្នុងករណីដែលមតកជនមានកូនតែម្នាក់ និងមានតែសហព័ទ្ធរបស់មតកជនជាសន្តតិជននោះភាគបម្រុងសម្រាប់អ្នកទាំងនោះត្រូវជា ១ភាគ២ នៃចំណែកទ្រព្យមតិករបស់មតកជន។ រីឯចំណែកនៃភាគបម្រុងរបស់សន្តតិជនម្នាក់ៗត្រូវបានចំណែកនៃ ១ភាគ២ នៃចំណែកទ្រព្យសម្បត្តិរបស់មតកជននោះចែកជាពីរទៀត (សន្តតិជន២នាក់) ឬស្មើនឹង ១ភាគ៤ នៃទ្រព្យមតិកសរុប។

### ២.៤.៣.៤. ករណីយកិច្ចសហព័ទ្ធចំពោះមតកជន

ទន្ទឹមនឹងការទទួលបាននៃសិទ្ធិលើទ្រព្យសម្បត្តិមួយចំនួនរបស់សហព័ទ្ធហើយនោះ ភាគីដែលជាសហព័ទ្ធនៅរស់រមែងបំពេញនូវករណីយកិច្ចមួយចំនួនជាអាទិ៍៖

- **ការទទួលករណីយកិច្ចលើបំណុល**

ថ្វីបើសហព័ទ្ធទទួលបាននូវសិទ្ធិលើទ្រព្យសម្បត្តិរបស់មតកជនហើយក្តី ក៏ត្រូវទទួលព្រមគ្នាផងដែរ នូវករណីយកិច្ចលើបំណុល (បើមាន) ដើម្បីធ្វើការបែងចែកចំណែកនៃករណីយកិច្ចនោះទៅឲ្យតតិយជន ឬភាគីពាក់ពន្ធ័ទៅតាមចំណែកសមាមាត្ររបស់សន្តតិជនម្នាក់ៗ។[120] ក្នុងករណីដែល

[117] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១២៣១។

[118] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១២៣០ (១)។

[119] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១២៣០ (កថាខណ្ឌ២)។

[120] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៤៧ (កថាខណ្ឌ១)។

សិទ្ធិ ឬ ករណីយកិច្ចមិនអាចបែងចែកបានតាមលក្ខខណ្ឌនៃសិទ្ធិ ឬករណីយកិច្ចនោះត្រូវទទួលបន្ត ដោយអវិភាគីយ៍ (ចំណែកដែលមិនអាចបំបែកបាន)។[121]

**ឧទាហរណ៍៖** ក្នុងករណីដែលមតកជនមានទ្រព្យមរតក ១០០លានរៀល និងទ្រព្យអកម្ម (បំណុល) ចំនួន២០លានរៀល។ ទន្ទឹមនឹងការទទួលបានទ្រព្យមរតក (១០០លានរៀល) តាមសមាមាត្រហើយនោះ សហព័ទ្ធ ក៏ដូចជាសន្តតិជន ឬសហសន្តតិជន ដទៃទៀតត្រូវរួមចំណែកតាមសមាមាត្រក្នុងការអនុវត្តនូវកាតព្វកិច្ចលើបំណុល (២០លានរៀល) នោះផងដែរ។

➢ **ករណីយកិច្ចលើការរៀបចំបុណ្យសព**

យ៉ាងណាមិញប្រទេសកម្ពុជា គឺជាប្រទេសមួយដែលមានការគោរពនូវបទដ្ឋាន ប្រពៃណី សាសនា ទំនៀមទម្លាប់មួយយ៉ាងខ្ជាប់ខ្ជួន។ ទន្ទឹមនឹងការទទួលបានចំណែកលើមរតកហើយ សហព័ទ្ធ រួមជាមួយនឹងសន្តតិជន ឬ សហសន្តតិជនត្រូវសហការគ្នាដោយសាមគ្គីក្នុងការរៀបចំបុណ្យសពទៅតាមប្រពៃណីទំនៀមទម្លាប់របស់មតកជន។ ម៉្យាងវិញទៀតករណីដែល ទំនៀមទម្លាប់មិនច្បាស់លាស់នោះ តុលាការត្រូវកំណត់ជនដែលត្រូវទទួលបន្តនូវសិទ្ធិ។[122]

➢ **ករណីយកិច្ចធ្វើសំបុត្រមរណភាព**

វាជាលក្ខខណ្ឌចាំបាច់ណាស់ ក្នុងការធ្វើសំបុត្រមរណភាពដោយក្នុងនោះ សហព័ទ្ធ ឬ សហសន្តតិជនពាក់ព័ន្ធត្រូវស្នើទៅអាជ្ញាធរមូលដ្ឋាន ឬរាយការណ៍ជូនមន្ត្រីអត្រានុកូលដ្ឋាននៃសាលាឃុំ-សង្កាត់ នៃទីកន្លែងរស់នៅរបស់មតកជនជាចាំបាច់ ដើម្បីស្នើសុំបញ្ជាក់សំបុត្រមរណភាពសម្រាប់មតកជន។ អត្ថប្រយោជន៍នៃសំបុត្រមរណភាព ដើម្បីឲ្យដឹងពីមូលហេតុនៃមរណភាពរបស់បុគ្គល រោគវិនិច្ឆ័យរបស់អ្នកស្លាប់ របាយការណ៍ប្រជាសាស្ត្ររបស់ប្រទេសជាតិ ការរៀបអាពាហ៍ពិពាហ៍ថ្មី(ដោយស្របច្បាប់) និងការទទួលបានសិទ្ធិ និងករណីយកិច្ចលើមរតកដោយស្របច្បាប់ ដែលត្រូវធ្វើឡើងរយៈពេល១៥ថ្ងៃក្រោយមរណភាព។[123]

121 ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៥៨ (កថាខណ្ឌ១)។

122 ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១១៥៧ (កថាខណ្ឌ២)។

123 ខ្មែរនគរ, *"ចូរនិយាយពីអត្ថប្រយោជន៍នៃសំបុត្រកំណើត? សំបុត្រអាពាហ៍ពិពាហ៍? សំបុត្រមរណភាព?,"* *ខ្មែរនគរ*, ១៧ មករា ២០១៨, https://www.khmernokor.com/question-answers?page=3 (បានចូលទស្សនាចុងក្រោយ ២២ ខែមិថុនា ឆ្នាំ២០១៨)។

# សេចក្តីសន្និដ្ឋាន

តាមរយៈការបកស្រាយ និងសិក្សាស្រាវជ្រាវលើប្រធានបទ "**ទំនាក់ទំនងសហព័ទ្ធក្នុងនីតិគ្រួសារ**" រួចមក ប្រធានបទខាងលើបានឆ្លុះបង្ហាញឲ្យឃើញយ៉ាងច្បាស់ពីទំនាក់ទំនងនៃសិទ្ធិ និងកាតព្វកិច្ចរបស់សហព័ទ្ធ ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ រួមទាំងសិទ្ធិ និងកាតព្វកិច្ចរបស់ពួកគេចំពោះ កូនៗផងដែរ។ ម្យ៉ាងទៀត សិទ្ធិ និងកាតព្វកិច្ចរបស់សហព័ទ្ធ ក្រោយការលែងលះ ឬ បញ្ចប់អាពាហ៍ពិពាហ៍ក៏ត្រូវបានលើកយកមកបង្ហាញបកស្រាយផងដែរ។ តាមផ្លូវច្បាប់ ការចុះសំបុត្រអាពាហ៍ពិពាហ៍ និងគោរពតាមគោលការណ៍ដែលមានចែងដោយច្បាប់ជាធរមាន ពិតជាមានសារៈសំខាន់ណាស់ក្នុងការរក្សានូវសិទ្ធិ កាតព្វកិច្ច និងករណីយកិច្ច ដែលសហព័ទ្ធមានចំពោះគ្នាទៅវិញទៅមក។ បើនិយាយផ្ទុយមកវិញ ការរៀបអាពាហ៍ពិពាហ៍ដែលពុំបានចុះបញ្ជីអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមលក្ខខណ្ឌនៃច្បាប់ទេនោះ បុរស និងស្ត្រីនោះពុំត្រូវបានច្បាប់ទទួលស្គាល់ឡើយ និងបានក្លាយជាអនីតិសង្វាសជន ដែលនឹងមិនបានទទួលការការពារតាមផ្លូវច្បាប់ ឬអត្ថប្រយោជន៍ផ្សេងៗដូចសហព័ទ្ធឡើយ។

បើនិយាយពីការគ្រប់គ្រងទ្រព្យសម្បត្តិវិញ សហព័ទ្ធមានសិទ្ធិក្នុងការជ្រើសរើសនោះ គឺការគ្រប់គ្រងប្រព័ន្ធទ្រព្យតាមកិច្ចសន្យា ឬ តាមច្បាប់។ ភាពខុសគ្នានៃការគ្រប់គ្រងប្រព័ន្ធទ្រព្យសម្បត្តិទាំងពីរខាងលើ គេសង្កេតឃើញការគ្រប់គ្រងប្រព័ន្ធទ្រព្យសម្បត្តិតាមផ្លូវច្បាប់ហាក់មានភាពស្មើគ្នាចំពោះ សិទ្ធិ និងកាតព្វកិច្ចសហព័ទ្ធក្នុងប្រព័ន្ធនីតិទ្រព្យសម្បត្តិ ស្របតាមគោលការណ៍នៃរដ្ឋធម្មនុញ្ញនោះ គឺ សិទ្ធិស្មើគ្នា រវាងបុរស និងស្ត្រី។ បើក្រឡេកទៅមើលការគ្រប់គ្រងទ្រព្យសម្បត្តិតាមកិច្ចសន្យាវិញ ហាក់មានការចងជើងភាគីម្ខាង និងកម្រិតសិទ្ធិមួយចំនួន ក្នុងការប្រើប្រាស់អាស្រ័យផល និងចាត់ចែងទ្រព្យសម្បត្តិក្នុងគ្រួសារ។ ទោះបីជាយ៉ាងនេះក្តី ផ្លូវច្បាប់នៅតែមានការបើកផ្លូវយ៉ាងទូលំទូលាយដល់ការសម្រេចចិត្តរបស់គូភាគី ពោលគឺគោលការណ៍ស្វ័យភាពនៃការសម្រេចចិត្តរបស់គូភាគីនៃចំណងអាពាហ៍ពិពាហ៍ (សហព័ទ្ធ)។

ថ្វីបើការគ្រប់គ្រងប្រព័ន្ធទ្រព្យនៅកម្ពុជាតាមរយៈកិច្ចសន្យាត្រូវបានផ្លូវច្បាប់ទទួលហើយក្តី ក៏គេសង្កេតឃើញ ការអនុវត្តន៍នៅមានកម្រិតនៅឡើយ។ បញ្ហាចោទគឺស្ថិតនៅត្រង់កម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋ ដោយហេតុថាកម្ពុជាជាប្រទេសមួយស្ថិតក្នុងលំដាប់នៃប្រទេសកំពុងអភិវឌ្ឍ ដែលទើបរួចផុតពីសង្គ្រាម និងទទួលបានការរួបរួមជាតិនៅឆ្នាំ១៩៩៨ប៉ុណ្ណោះ។ ទាំងនេះហើយដែលធ្វើឲ្យការប្រព្រឹត្តទៅនៃការគ្រប់គ្រងច្បាប់នៅកម្ពុជានៅមានកម្រិត ដែលពុំទាន់ឈានទៅដល់ប្រព័ន្ធនៃការគ្រប់គ្រងមួយ ដែលដូចបណ្តាប្រទេសអភិវឌ្ឍមួយចំនួនឡើយ។

# អនុសាសន៍

ក្រោយពីបានធ្វើការស្រាវជ្រាវ និងបកស្រាយលើប្រធានបទ "**ទំនាក់ទំនងសហព័ទ្ធក្នុងនីតិគ្រួសារ**" រួចមក យើងសង្កេតឃើញ ប្រធានបទខាងលើបានបង្ហាញនូវគុណប្រយោជន៍ជាខ្លាំងពោល គឺជាគន្លឹះគតិយុត្តក្នុងការស្វែងយល់ពីស្ថានភាពរស់នៅ សិទ្ធិ កាតព្វកិច្ច និងករណីយកិច្ចរបស់សហព័ទ្ធនៅក្នុងសង្គមកម្ពុជា។ អ្វីដែលគួរឲ្យកត់សម្គាល់ និងធ្វើការកត់ចំណាំនោះ គឺស្ថានភាពនៃការយល់ដឹងអំពីគោលការណ៍នៃការអនុវត្តច្បាប់ និងនីតិវិធីនៃការអនុវត្តច្បាប់ របស់ប្រជាពលរដ្ឋកម្ពុជាដែលនៅមានកម្រិតនៅឡើយ។ ដូចដឹងស្រាប់ហើយកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍមួយ ដូចនេះស្ថានភាពចេះដឹងរបស់ប្រជាពលរដ្ឋស្ថិតក្នុងកម្រិតទាបជាងបណ្តាប្រទេសអភិវឌ្ឍមួយចំនួន។

ថ្វីបើប្រទេសកម្ពុជាជាប្រទេសដែលកំពុងអភិវឌ្ឍក្តី តែប្រទេសនេះមានប្រព័ន្ធច្បាប់មួយដែលសម្បូរបែបមិនចាញ់ប្រទេសអភិវឌ្ឍប៉ុន្មាននោះទេ។ ទន្ទឹមនឹងភាពសម្បូរបែបនៃប្រព័ន្ធច្បាប់នេះផងដែរ គេសង្កេតឃើញកង្វះខាតមួយចំនួន ដែលកើតឡើងក្នុងដំណើរប្រព្រឹត្តទៅនៃការអនុវត្តច្បាប់។ ដោយស្ថានភាពចេះដឹងរបស់ប្រជាជនកម្ពុជាហាក់នៅមានកម្រិតនៅឡើយ ជាហេតុនាំឲ្យការបំពេញបែបបទនៃនីតិវិធីច្បាប់ហាក់នៅមានភាពចន្លោះប្រហោងច្រើន។ ជាក់ស្តែងប្រជាពលរដ្ឋនៅតាមទីជនបទបានបំពេញបែបបទនៃការរៀបអាពាហ៍ពិពាហ៍ តែទៅតាមប្រពៃណីទំនៀមទម្លាប់តែប៉ុណ្ណោះ។ ផ្ទុយមកវិញពួកគាត់មិនបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នានោះទេ ដែលជាភាពខ្វះខាតនៃលក្ខខណ្ឌច្បាប់ក្នុងការចងជាសិទ្ធិ និងកាតព្វកិច្ចសម្រាប់ភាគីប្តីប្រពន្ធទាំងពីរ។ ភាពយល់ដឹងនៃប្រជាពលរដ្ឋជាមូលហេតុចម្បងមួយ ក្នុងដំណើរការរីកចម្រើននៃច្បាប់ និងឈានទៅរកគោលការណ៍នីតិរដ្ឋ។

ក្នុងនាមជាប្រជាពលរដ្ឋខ្មែរ និងជានិស្សិតច្បាប់ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាប្រជាពលរដ្ឋកម្ពុជានឹងខិតខំ ព្យាយាមស្វែងយល់លើគ្រប់ទិដ្ឋភាពច្បាប់ជាពិសេស តាមរយៈការអាន ស្តាប់ និងទស្សនានូវវិធីអប់រំទាក់ទងនឹងការអនុវត្តន៍ច្បាប់ តាមបណ្តាប្រព័ន្ធផ្សព្វផ្សាយនានាឲ្យបានច្រើនជាងមុន និងចូលរួមឲ្យបានផុសផុលក្នុងសិក្ខាសាលានានាដែលទាក់ទងនឹងវិស័យច្បាប់។ ទន្ទឹមនឹងនេះផងដែរ រាជរដ្ឋាភិបាល តាមរយៈក្រសួងអប់រំ យុវជន និងកីឡាគួរតែបន្ថែម មុខវិជ្ជាមួយទៀតដែលទាក់ទងនឹងមូលដ្ឋានគ្រឹះនៃច្បាប់ នៅក្នុងប្រព័ន្ធអប់រំចំណេះដឹងទូទៅ មធ្យមសិក្សាទុតិយភូមិដើម្បីពង្រឹកភាពយល់ដឹងជាមូលដ្ឋានរបស់សិស្សានុសិស្សនៅកម្រិតវិទ្យាល័យ។ បន្ថែមពីនេះទៀតក្រសួងយុត្តិធម៌ ក៏ដូចជាក្រសួងពាក់ព័ន្ធគួរតែពង្រីកការផ្សព្វផ្សាយរបស់ខ្លួននៅទូទាំងប្រទេស និងនៅតាមទីជនបទស្រុកស្រែចម្ការដើម្បីបញ្ជ្រាបការយល់ដឹងរបស់ប្រជាពលរដ្ឋនៅទូទាំងប្រទេស៕

# ឯកសារយោង


❖ **ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត**

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣។
- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស, ១០ ធ្នូ ១៩៤៨។
- ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ១៩២០។
- ក្រមនីតិវិធីរដ្ឋប្បវេណី, លេខនស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦។
- ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។
- ក្រមព្រហ្មទណ្ឌ, លេខនស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។
- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ក្រ, ១៧ កក្កដា ១៩៨៩។
- ច្បាប់ស្តីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ២១ តុលា ២០០៦។
- ច្បាប់ស្តីពីការអប់រំ, លេខនស/រកម/១២០៧/០៣២, ១៩ ធ្នូ ២០០៧។
- ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខនស/រកម/០៦១០/០០៨, ០៨ មិថុនា ២០១០។
- ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខនស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។
- ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១។

❖ **សាលដីកា/សាលក្រម**

- សាលក្រមលែងលះ, លេខ ៧៨១ "ឈ" ភ.ព.រ.វ, ៣០ មិថុនា ២០១៥។
- សាលក្រមលែងលះ, លេខ ២០ (ង), ០៣ សីហា ២០១៥។

❖ **សៀវភៅដែលបានបោះពុម្ពផ្សាយ**

- ក្រសួងយុត្តិធម៌. ២០០៩. *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី.* ភាគ១. ភ្នំពេញ៖ ក្រសួងយុត្តិធម៌។
- ក្រសួងយុត្តិធម៌. ២០០៩. *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី.* ភាគ៥. ភ្នំពេញ៖ ក្រសួងយុត្តិធម៌។
- ក្រសួងយុត្តិធម៌. ២០០៩. *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី.* ភាគ៦. ភ្នំពេញ៖ ក្រសួងយុត្តិធម៌។
- ញឹក វុធ្ធី. *មេរៀននីតិវិធីរដ្ឋប្បវេណី.* ភ្នំពេញ។
- រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត, *នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ* (ភ្នំពេញ៖ រោងពុម្ពជោគជ័យ, ២០១៧)។
- ស្រី វណ្ណធី.២០១២. *នីតិបេតិកភណ្ឌ និងគ្រួសារ*, បោះពុម្ពលើកទី១. ភ្នំពេញ។

❖ **សារណាបញ្ចប់ការសិក្សា**

➢ បាន លក្ខិណា និងរ៉ាត់ រ៉ាទី.២០១៧. ទំនាក់ទំនងទ្រព្យសម្បត្តិនៃសហព័ទ្ធ និងអនីតិសង្វាស. សារណាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

➢ មាស វង្សសុគា និងឆន មួយគា.២០១៦. អាពាហ៍ពិពាហ៍ និងការលែងលះ. សារណាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

➢ ឡាយ ហុកតេក និងសាង គឹមឈៀង. ២០១៥. ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់សហព័ទ្ធ. សារណាថ្នាក់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

❖ **គេហទំព័រ**

➢ ខ្មែរនគរ. ២០១៨. ចូរនិយាយពីអត្ថប្រយោជន៍នៃសំបុត្រកំណើត? សំបុត្រអាពាហ៍ពិពាហ៍? សំបុត្រមរណភាព?. *ខ្មែរនគរ*, ១៧ មករា, https://www.khmernokor.com/ question-answers?page=3 (បានចូលទស្សនាចុងក្រោយ ២២ ខែមិថុនា ឆ្នាំ២០១៨)។

➢ អ៊ុន រិទ្ធី. ២០១៨. ផ្សព្វផ្សាយប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធជាលើកដំបូង. *AKP*, ២៤ កុម្ភៈ, http://www.akp.gov.kh/kh/archives/77159 (ចូលទស្សនាចុងក្រោយ ២២ ខែមិថុនា ឆ្នាំ២០១៨)។

➢ LookingTODAY. ២០១៨. នៅជប៉ុន បើចង់រៀបការស្របច្បាប់ ទាល់តែប្តីប្រពន្ធ មាននាមត្រកូលដូចគ្នា. *LookingTODAY,* 08 មករា, https://www.lookingtoday.com/art/24592.html (ចូលទស្សនាចុងក្រោយ ២៤ មិថុនា ឆ្នាំ២០១៨)។